ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ឆ្មាំព្រៃឈើ និងប្លង់គោលស្រុកអន្លង់វែង

◆ ជនជាតិជងខ្លួនភ្នំនៅស្រុកវាលវែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣៤ ខែមិថុនា ឆ្នាំ២០១៩

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ២៣៤ ខែមិថុនា ឆ្នាំ២០១៩

## មាតិកា


**សំបុត្រ**

◆ ឆ្នាំព្រៃឈើ និងបួងគោលស្រុកអន្លង់វែង................................១

**ផ្នែកឯកសារ**

◆ ភោគ អ៊ុម ខ្សែបណ្ដាញ សេ.អ៊ី.អា ........................................ ៥

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ មជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា ៖ កន្លែងតម្កល់ឯកសារ ......... ៨

◆ ភូមិភាគបូព៌ាផ្សារភ្ជាប់អតីតកាល និងបច្ចុប្បន្ន.........................១២

◆ សន្និសីទស្ដីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ..................... ១៥

◆ ថ្នាក់រៀនស្ដីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ............ ១៧

◆ និស្សិតមកពីសាកលវិទ្យាល័យកាតូលិកអូស្ត្រាលី ................... ១៩

◆ វេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រនៅវិទ្យាល័យតេជោសែនត្រពាំងតាវ ... ២១

◆ ជនជាតិជងខ្នងភ្នំនៅស្រុកវាលវែង....................................២៣

◆ បទពិសោធន៍របស់អ្នករស់រានជីវិត បានធ្វើឲ្យសិស្សានុសិស្ស..... ២៦

◆ ការចងចាំពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមតាមរយៈ ........ ២៨

◆ «ឆ្នាំព្រៃ» ជួយជំរុញទឹកចិត្តប្រជាពលរដ្ឋក្នុងខេត្តឧត្តរមានជ័យ ...៣១

◆ រឿងរ៉ាវរន្ធត់ពីម្ដាយខ្ញុំ .......................................................... ៣៤

◆ ជីវិតក្នុងព្រៃរបស់អតីតយោធាខ្មែរក្រហម ........................... ៣៨

**ផ្នែកច្បាប់**

◆ អង្គជំនុំជម្រះសាលាដំបូង................................................... ៤០

**វេទិកាពិភាក្សាសាធារណៈ**

◆ យុត្តិធម៌នៅក្នុងតុលាការខ្មែរក្រហមតាមរយៈ ........................ ៤២

◆ សាស្ត្រាចារ្យ មីលតុល អស្សូន ចែករំលែកបទពិសោធន៍..........៤៧

◆ ការចងចាំអំពីរបបខ្មែរក្រហម បង្ហាញអំពីភាពរឹងមាំ..............៤៩

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ សាច់ញាតិរបស់ខ្ញុំដែលបែកគ្នាក្នុងរបបខ្មែរក្រហម ................ ៥២

◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម .............៥៥

◆ អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ ...............................................៥៨





សម្ភារ និងឧបករណ៍ប្រើប្រាស់របស់ជនភៀសខ្លួនខ្មែរ
នៅជំរំភៀសខ្លួនម៉ូរ៉ុង ទីក្រុងបាតាអាន ប្រទេសហ្វីលីពីន


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ៣៧៥ ព.មប្រក
ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



***ស្នេរលេខនេះ៖*** *ផាត ចាន់សុនិតា, មិន សាណាស, ព្រុំ គិតម៉ាន់, សួត វិចិត្រ, សុខ វណ្ណៈ, ភួង សុគន្ធ, វ៉ាន់ ថាន់ពៅដារ៉ា និង ឡុង ដានី,* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *ហូ ថុនា, អ៊ុន សុដាវី និង ដារ៉ារដ្ឋ មេត្តា* ***អ្នកបកប្រែ៖*** *អ៊ុន សុដាវី* ***និពន្ធនាយកទូទៅ៖*** *សោម ប៊ុនថន* ***ជំនួយការនិពន្ធនាយក៖*** *ហូ ថុនា* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គឹម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វ៉ើង*



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ឆ្នាំព្រៃឈើ និងឫងគោលស្រុកអន្លង់វែង

នៅវេលាម៉ោង៨ល្ងាចក្នុងថ្ងៃទី២១ខែមិថុនាឆ្នាំ២០១៩ នឹងមានការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» នៅវេទិកាអុំទូក ទល់មុខសាលាខេត្តឧត្តរមានជ័យ។ រឿង «ឆ្នាំព្រៃ» នឹងលើកទឹកចិត្តមនុស្សគ្រប់គ្នាឲ្យស្វែងយល់ពីប្រវត្តិសាស្ត្រ និងតម្លៃនៃការថែរក្សាព្រៃឈើ។ ខ្សែភាពយន្តឯកសារនេះ នឹងបង្ហាញពីជីវិតសត្វព្រៃ ធនធានធម្មជាតិ និងព្រៃឈើនៅតំបន់ព្រៃសហគមន៍ ក្នុងខេត្តឧត្តរមានជ័យ។ តំបន់អន្លង់វែងនេះ គឺជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម ស្ថិតនៅភាគជើងនៃប្រទេសកម្ពុជា ហើយក៏ជាតំបន់ដែលទទួលបានសន្តិភាពចាប់ផ្តើមជាលើកដំបូងនៅប្រទេសកម្ពុជា។

រឿង «ឆ្នាំព្រៃ» បានលើកឡើងពីគំនិតផ្តួចផ្តើម និងការខិតខំប្រឹងប្រែងរបស់ព្រះសង្ឃមួយអង្គព្រះនាម ប៊ុន សាលួត ដែលជាមេគណៈសង្ឃក្នុងខេត្តឧត្តរមានជ័យក្នុងការដឹកនាំការងារអភិរក្សព្រៃឈើ ដែលនៅសេសសល់នៅក្នុងខេត្តឧត្តរមានជ័យ។ ការបង្ហាញអំពីព្រៃឈើ និងតំបន់អន្លង់វែងមិនត្រឹមតែជាគោលបំណងមួយរបស់ភាពយន្តឯកសារនេះតែប៉ុណ្ណោះទេ ក៏ប៉ុន្តែដើម្បីលុបបំបាត់ និងកែច្នៃភាពសាហាវឃោរឃៅរបស់របបខ្មែរក្រហមឲ្យទៅជាស្មារតីជាតិរួមគ្នាថ្មីមួយ ដែលមានយូរលង់ដំណាលគ្នាទៅនឹងការកកើតព្រៃឈើនៅតំបន់នេះដែរ។ «ឆ្នាំព្រៃ» គឺជាខ្សែភាពដែលមានសុទិដ្ឋិនិយម ហើយនឹងការជឿជាក់លើយុវវ័យជំនាន់ក្រោយដែល



ព្រះសង្ឃនិមន្តចូលរួមទស្សនាការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» នៅសួនច្បារវិមានឯករាជ្យក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។

នឹងយកគំរូតាមព្រះតេជគុណ ប៊ុន សាលួត ដែលជាការប្ដេជ្ញា និងមានស្មារតីជាតិក្នុងការអភិរក្សវប្បធម៌ និងធនធានធម្មជាតិរបស់កម្ពុជា។ «ឆ្នាំព្រៃ» នឹងនាំអ្នកទស្សនាផ្សារភ្ជាប់ខ្លួនទៅនឹងជីវចម្រុះនៃព្រៃឈើ។ ព្រៃឈើដែលងាយរងគ្រោះនេះត្រូវបានអនុញ្ញាតជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជា ឲ្យរក្សាទៅជាព្រៃអភិរក្ស ដែលត្រូវបានដាក់ឈ្មោះជាផ្លូវការថា «ព្រៃសហគមន៍សង្ឃរុក្ខវ័ន»។

ព្រះតេជគុណ ប៊ុន សាលួត គឺជាប្រធានសហគមន៍បានមានសង្ឃដីកាថា ព្រៃសហគមន៍សង្ឃរុក្ខវ័នមានទំហំសរុប ៣០,២៥៦ ហិចតា លាតសន្ធឹងក្នុងស្រុកចំនួនបី រួមមាន ស្រុកសំរោង ស្រុកចុងកាល់ និងស្រុកអន្លង់វែង។ ព្រៃនេះត្រូវបានចាត់ចូលជាព្រៃដែលទទួលបានការពារតាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ស្រុកទាំងបីខាងលើនេះ ក៏មាននៅក្នុងប្លង់គោលដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាសមាជិកអន្តរក្រសួង។ គំនិតនៃប្លង់គោលស្រុកអន្លង់វែងនេះគឺដើម្បីកែប្រែស្រុកអន្លង់វែងឲ្យទៅជាទីក្រុងសន្តិភាព ការបង្កើតថ្មី និងភាពរុងរឿងនៅតាមបណ្ដោយព្រំដែនភាគខាងជើងដែរ។ ក្នុងដំណាក់កាលទីមួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការជាមួយអន្តរក្រសួងដើម្បីបង្កើតប្លង់គោលស្រុកអន្លង់វែងឡើង រួមជាមួយនឹងដំណើរការអប់រំ ការផ្សព្វផ្សាយពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការអភិរក្សតំបន់ប្រវត្តិសាស្ត្រទាំង១៤កន្លែង រួមមាន ៖ ១) កន្លែងបូជាសព ប៉ុល ពត, ២) កន្លែងកាត់ទោស ប៉ុល ពត, ៣) ផ្ទះ តាម៉ុក (លើខ្នងភ្នំដងរែក), ៤) កន្លែងកែច្នៃគ្រាប់កាំភ្លើងលើភ្នំ២០០, ៥) ផ្ទះ ប៉ុល ពត និង ខៀវ សំផន, ៦) ឃ្លាំងដាក់សម្ភារៈជើងភ្នំ, ៧) កន្លែងបូជាសព សុន សេន, ៨) ស្រែគំរូ, ៩) ទីតាំងការដ្ឋានដឹកជញ្ជូន តាម៉ុក (ឃ្លាំងកណ្ដាល), ១០) បឹងអន្លង់វែង, ១១) ផ្ទះតាម៉ុក ៖ សារមន្ទីរតាម៉ុក, ១២) អតីតមន្ទីរពេទ្យ តាម៉ុក, ១៣) អតីតសាលារៀន តាម៉ុក និង ១៤) ស្ពាន តាម៉ុក។ មជ្ឈមណ្ឌលឯកសារបានកំណត់ទីតាំងប្រវត្តិសាស្ត្រសំខាន់ៗចំនួន១៤កន្លែង នៅតាមផ្លូវចាប់ពីអន្លង់វែងរហូតដល់កំពូលភ្នំដងរែក។

ប្រវត្តិសាស្ត្របានផ្ដល់អត្ថន័យយ៉ាងច្រើនសម្រាប់ទីតាំងទាំងនេះ ហើយសូម្បីប្រវត្តិសាស្ត្រអន្ធការនេះក៏ផ្ដល់តម្លៃបានដែរ។ ប្រវត្តិសាស្ត្រខ្មែរក្រហមគឺជាអ្វីមួយដែលធ្វើឲ្យអន្លង់វែងមានលក្ខណៈពិសេសជាងកន្លែងដទៃទៀត។ បញ្ហាប្រឈមគឺថាត្រូវចាប់យកខ្លឹមសារសំខាន់នៃតំបន់នេះ ដោយមិនចាំបាច់ជាប់ផុងនៅក្នុងអតីតកាលដ៏អន្ធការឡើយ។ គោលដៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺបង្កើតតំបន់មួយ ដោយមិនចាំបាច់លុបបំបាត់ចោលនូវការចងចាំអំពើហិង្សា និងការប៉ះទង្គិចផ្លូវចិត្តឡើយ ក៏ប៉ុន្តែត្រូវប្រែក្លាយតំបន់នេះពីទីតាំងនៃឈឺចាប់ឲ្យទៅជាទីតាំងនៃការបង្កើតជីវិតថ្មី។ តាមវិធីនេះ ប្រវត្តិសាស្ត្រអន្ធការអាចក្លាយទៅជាអនាគតដ៏ត្រចះត្រចង់មួយ។









ទីកន្លែងនៃការប្រព្រឹត្តអំពើ ហិង្សាទៅលើស្ត្រី ដែលប្រពន្ធ និងកូនស្រីរបស់ សុន សេន ត្រូវបានរំលោភ និងសម្លាប់ អាចប្រែទៅជាមជ្ឈមណ្ឌលស្ត្រីសម្រាប់បណ្តុះបណ្តាល និង ពិគ្រោះយោបល់។ ឃ្លាំងដែលធ្លាប់ស្តុកទុកគ្រាប់មីនអាច ប្រែក្លាយទៅជាទីកន្លែងដែលប្រជាជន អាចផលិតឈើច្រត់ រទេះរុញ និងកង់ជាដើម។ តាមមធ្យោបាយនេះ ទីកន្លែងដែល ធ្វើឲ្យមនុស្សរបួស និងពិការ អាចក្លាយទៅជាទីកន្លែងដែល ផ្តល់ការងារដល់ប្រជាជនតាមការលើកកម្ពស់ជនពិការឲ្យដើរ បានឡើងវិញ និងស្តារសង្គមទៀតផង។

តាមរយៈការរចនាប្លង់គោលនេះ យើងនឹងបង្កើតបាន ទីតាំងប្រកបដោយសោភ័ណ្ឌភាពដែលមិនអាចបំភ្លេចបាននៅ ក្នុងសហគមន៍អន្លង់វែង។ ការប្រើប្រាស់ធនធានធម្មជាតិ សណ្ឋានដី ព្រៃឈើ ភ្នំ ស្ទឹង បឹងបួរ ដោយគំនិតច្នៃប្រឌិត នឹងជួយរក្សានូវលំនឹងពីការសឹករេចរឹល និងជួយអភិវឌ្ឍន៍ តំបន់នេះយូរអង្វែង។ ប្លង់គោលនេះ ក៏ជាយុទ្ធសាស្ត្រចម្បង ជួយការពារព្រំដែនភាគខាងលិច ទប់ស្កាត់ជម្លោះព្រំដែន និង ទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីក្នុងបឹងប្រវត្តិសាស្ត្រអន្លង់វែង និងតំបន់ប្រវត្តិសាស្ត្រដែលទទួលបានការអភិរក្សផ្សេងទៀត។

ព្រះតេជគុណ ប៊ុន សាលួត ដែលជាមេគណៈខេត្តឧត្តរមានជ័យ មានសង្ឃដីកាបន្ថែមទៀតថា តំបន់ព្រៃសហគមន៍ សង្ឃរុក្ខវ័ន គឺជាព្រៃសេសសល់ចុងក្រោយនៃខេត្តឧត្តរមាន ជ័យ។ កាលពីមុនតំបន់ព្រៃសង្ឃរុក្ខវ័ន ត្រូវបានទន្ទ្រាន និង កាប់ឈើលក់ទៅឲ្យឈ្មួញ ធ្វើឲ្យព្រៃឈើនៅតំបន់នេះចាប់ ផ្តើមរេចរឹលបន្តិចម្តងៗ ហើយជម្រកសត្វព្រៃក៏បានបាត់បង់ ជាបណ្តើរៗដែរ។ ដូច្នេះព្រះអង្គក៏ស្ម័គ្រចិត្តចូលបម្រើការងារ ថែរក្សាព្រៃនេះ និងបានបំពេញឯកសារទៅស្ថាប័នពាក់ព័ន្ធ ក្រសួង និងរដ្ឋាភិបាល ដើម្បីសុំសិទ្ធិការពារ ថែរក្សា និង អភិរក្សតំបន់ព្រៃសហគមន៍នេះ ចាប់តាំងពីឆ្នាំ២០០១មក។ ព្រះអង្គបង្កើតកម្មវិធីផ្សេងៗតាមបែបសាសនា រួមមាន ការ រៀបចំពិធីបុណ្យទាន ការបំបួសដើមឈើដើម្បីអប់រំ និង ណែនាំប្រជាជនក្នុងសហគមន៍អំពីសារសំខាន់នៃព្រៃឈើ។ សព្វថ្ងៃ ព្រះអង្គសង់ទីស្នាក់ការចំនួន៧កន្លែងសម្រាប់ឃ្លាំ មើលព្រៃឈើ ដោយទីស្នាក់ការនីមួយៗមានកម្លាំងយាម ល្បាតចំនួន៣-៤នាក់ រួមមាន ទាំងព្រះសង្ឃដែរ។

ទោះបីជាជួបបញ្ហាប្រឈមទាក់ទងនឹងការបំពេញការ ងារកន្លងមក ក៏ព្រះអង្គមិនដែលមានចិត្តរុញរា ឬចង់បញ្ឈប់ សកម្មភាពរបស់ព្រះអង្គដែរ ព្រោះព្រះអង្គស្រឡាញ់ធម្មជាតិ និងចង់អភិរក្សតំបន់សហគមន៍ព្រៃសង្ឃរុក្ខវ័នឲ្យក្លាយទៅជា តំបន់ទេសចរណ៍ចម្រុះ ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ មកពីគ្រប់ទីកន្លែងឲ្យចូលមកដើរកម្សាន្តនៅក្នុងព្រៃនេះ។ ជិត២០ឆ្នាំកន្លងមកនេះ ព្រះអង្គបានខិតខំអភិរក្សតំបន់សហ គមន៍ព្រៃសង្ឃរុក្ខវ័ននេះ ហើយជាលទ្ធផល សហគមន៍ព្រៃ សង្ឃរុក្ខវ័នក៏បានផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែល រស់នៅ និងអាស្រ័យផលពីអនុផលព្រៃឈើក្នុងតំបន់នេះ







ចំនួន៩ភូមិ ស្មើនឹង៨ជិតមួយរយគ្រួសារ។ ជាពិសេស តំបន់សហគមន៍ព្រៃសង្ឃរុក្ខវ័ននេះ ក៏បានផ្តល់ជាទីជម្រកដល់សត្វព្រៃជាច្រើនសន្ធឹកសន្ធាប់ដែរ។ ព្រះអង្គសង្ឃមថា ប្រជាជនកម្ពុជានឹងមានការយល់ដឹងច្រើនអំពីសារសំខាន់នៃព្រៃឈើ ព្រោះព្រៃឈើនិងមនុស្សត្រូវតែមានទំនាក់ទំនងនិងអាស្រ័យផលគ្នាទៅវិញទៅមក។ ព្រៃសហគមន៍សង្ឃរុក្ខវ័ន នឹងត្រូវបានការពារ និងថែរក្សាដោយយកចិត្តទុកដាក់ដើម្បីរក្សាទុកជាសម្បត្តិធម្មជាតិសម្រាប់កូនចៅជំនាន់ក្រោយ។

កាលពីមុន ព្រៃសហគមន៍សង្ឃរុក្ខវ័ន ក៏ធ្លាប់ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមខ្មែរក្រហមដែរ។ យោធា កម្មាភិបាលខ្មែរក្រហម និងប្រជាជនដែលរត់គេចខ្លួនពីការវាយប្រហារពីសំណាក់កងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅឆ្នាំ១៩៧៩ បានរត់មកប្រមូលផ្តុំគ្នា និងរស់នៅក្នុងព្រៃនេះ។ ខ្មែរក្រហមបានកេណ្ឌប្រជាជនរាប់ម៉ឺននាក់ចូលមករស់នៅក្នុងព្រៃនេះ និងនៅលើជួរភ្នំដងរែក (លាតសន្ធឹងពីខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ) ឲ្យចូលជាយោធាដើម្បីវាយប្រយុទ្ធតទល់នឹងរដ្ឋាភិបាល។ តំបន់នេះមានទីតាំងភូមិសាស្ត្រអំណោយផលសម្រាប់ក្រុមខ្មែរក្រហមលាក់ខ្លួន ព្រោះសម្បូរណ៍ទៅដោយព្រៃឈើក្រាស់ៗ និងជួរភ្នំវែងអន្លាយ។ នៅអំឡុងពេលនោះ ខ្មែរក្រហមក៏បានកាប់ឈើពីក្នុងព្រៃនេះដើម្បីយកមកសាងសង់ផ្ទះសម្រាប់យោធា សង់មូលដ្ឋានទ័ព ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។ ក្រោយមក យោធាខ្មែរក្រហមបានចាប់ផ្តើមកាប់ព្រៃឈើកាន់តែច្រើនក្នុងគោលបំណងដោះដូរស្បៀងគ្រឿងឧបភោគ និងសម្ភារប្រើប្រាស់ ជាមួយឈ្មួញថៃ ដែលបណ្តាលឲ្យព្រៃឈើជាច្រើននៅតាមព្រំដែនកម្ពុជា-ថៃរួមមាន ស្រុកអន្លង់វែង ស្រុកសំរោង និងស្រុកចុងកាល់ បាត់បង់ជាបន្តបន្ទាប់។

ក្រោយមក ដោយសារតម្រូវការឈើ និងការជួញដូរឈើកាន់តែច្រើនឡើងធ្វើឲ្យព្រៃនៅក្នុងតំបន់ព្រៃសហគមន៍នេះទទួលរងគ្រោះកាន់តែខ្លាំង តាមរយៈការកាប់រំលំ ទោះបីមានវិធានការការពារជាបន្តបន្ទាប់ពីអាជ្ញាធរ និងរដ្ឋាភិបាលក៏ដោយ។

ព្រៃឈើបានផ្តល់ផលប្រយោជន៍ជាច្រើនដល់មនុស្ស និងជម្រកសត្វព្រៃ។ ព្រៃឈើមានតួនាទីយ៉ាងសំខាន់ក្នុងការជួយថែរក្សាដំណើរការប្រព័ន្ធអេកូឡូស៊ី និងជួយកាត់បន្ថយឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដូចជា ទឹកជំនន់ ខ្យល់ព្យុះ និងស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស។ ព្រៃឈើ គឺជាសម្បត្តិធម្មជាតិដ៏មានតម្លៃ ដែលទំនាក់ទំនងជាមួយនឹងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងសត្វ ដូច្នេះទាមទារឲ្យមានការចូលរួម ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយវិចារណញ្ញាណ ដើម្បីធានានូវតុល្យភាពបរិស្ថាន ព្រមទាំងផ្តល់ឱកាសដល់កូនចៅជំនាន់ក្រោយទទួលបានផលប្រយោជន៍ពីធនធានទាំងអស់នេះ។

ព្រៃសហគមន៍សង្ឃរុក្ខវ័នមិនត្រឹមតែរក្សាលំនឹងបរិស្ថានធម្មជាតិដែលមានសម្រស់ស្រស់បំព្រងពណ៌បៃតង និងរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ព្រមទាំងបម្រើដល់វិស័យទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែបានផ្សារភ្ជាប់ទៅនឹងអំពើហិង្សា និងប្រវត្តិនៃការកាប់សម្លាប់ដ៏ឃោរឃៅរបស់ក្រុមខ្មែរក្រហម។ របបខ្មែរក្រហមមិនត្រឹមធ្វើឲ្យប៉ះពាល់ទៅដល់មនុស្ស ធម្មជាតិ និង សង្គមប៉ុណ្ណោះទេ ប៉ុន្តែបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរទៅដល់វប្បធម៌ និងសាសនា ហើយដែលបន្តរហូតមកដល់សព្វថ្ងៃ។ ដូចគ្នានឹងយន្តការនៃការការពារ ការអភិរក្សព្រៃឈើ និងការបង្ហាញពីសារសំខាន់នៃព្រៃសហគមន៍សង្ឃរុក្ខវ័ន ប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមក៏យើងគួរត្រូវលើកយកពិភាក្សា និងរៀនសូត្រ។

ខ្សែភាពយន្តឯកសាររឿង«ឆ្នាំព្រៃ» និងប្លង់គោលស្រុកអន្លង់វែង នឹងជួយឲ្យខេត្ត ឧត្តរមានជ័យ ទទួលនូវការអភិវឌ្ឍន៍ និងការថែរក្សាប្រវត្តិសាស្ត្រព្រមជាមួយគ្នា។

*សោម ប៊ុនថន*

# ភោគ អ៊ុម ខ្មែរបណ្តាញ សេ.អ៊ី.អា ដកស្រង់ចេញពីឯកសារចម្លើយសារភាព D000៥២

ខ្ញុំឈ្មោះ ភោគ អ៊ុម ហៅ ហ៊ាង អាយុ២៨ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំមានស្រុកកំណើតនៅភូមិតាកួន សង្កាត់ក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ភោគ ហ៊ឹម ចំណែកម្តាយឈ្មោះ មឿង ស៊ាន។ ខ្ញុំរស់នៅធ្វើស្រែចម្ការជាមួយឪពុកម្តាយតាំងពីកុមារភាពរហូតដល់អាយុ ៩ឆ្នាំ ហើយខ្ញុំក៏បានផ្លាស់ទៅនៅវត្តក្រឡាជាមួយលោកគ្រូណាន ដែលជាសមាជិកនៃគណៈកម្មាធិការវត្ត។ នៅពេលដែលខ្ញុំមានអាយុ១៥ឆ្នាំ ខ្ញុំបានទៅធ្វើការជាកម្មករកើបដី ថ្មគ្រួស ឱ្យរាប់ដាក់ឡាននៅទីរួមខេត្តកំពង់ចាម។ ខ្ញុំធ្វើការនៅទីនោះរហូតដល់មានរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ចេញពីតំណែងទើបឈប់ធ្វើការត្រឡប់មករស់នៅជាមួយឪពុកម្តាយវិញ។

អំឡុងដើមទសវត្សរ៍ទី៧០ ខ្ញុំបានចូលបដិវត្តន៍តាមរយៈឈ្មោះ យ៉ាន ដែលជាប្រជាជនរស់នៅក្នុងភូមិជាមួយគ្នា។ ក្រោយមកឈ្មោះ ម៉ន ដែលជាអនុប្រធានសិល្បៈភូមិភាគខត្តរ បានចាត់តាំងខ្ញុំឲ្យទៅនៅសិល្បៈភូមិភាគ។ ម៉ន បានខទ្មេសនាមខ្ញុំឲ្យឈ្មោះ កែវ ដែលជាប្រធានសិល្បៈនៅភូមិភាគខត្តរ ទទួលស្គាល់ខ្ញុំជាខ្សែចាត់តាំងរបស់គាត់។ បន្ទាប់មកទៀត ម៉ន បានណែនាំខ្ញុំឲ្យចូលធ្វើជាបណ្តាញ សេ.អ៊ី.អា នៅមន្ទីរក-២៣ ដែលមានឈ្មោះ ឃួនជាអ្នកគ្រប់គ្រង។



ការសម្តែងសិល្បៈ របស់កងសិល្បៈខ្មែរក្រហម

ខ្ញុំទទួលបានការអប់រំជាច្រើន ទាក់ទងនឹងការប្រឆាំងបដិវត្តន៍ ហើយតាមរយៈការអប់រំនេះ បានធ្វើឲ្យខ្ញុំមានទំនោរសតិអារម្មណ៍ទៅខាងក្រុម សេ.អ៊ី.អា។ ពេលនោះ ខ្ញុំយល់ថា កងទ័ព លន់ នល់ នឹងទទួលបានជ័យជម្នះជាមិនខាន។ ក្រោយមក ម៉ន បានប្រាប់ឲ្យខ្ញុំស្គាល់ពីខ្សែចាត់តាំងរបស់គាត់ ដើម្បីងាយស្រួលធ្វើការងារជាមួយគ្នា។ ក្រុមខ្សែបណ្ដាញទាំងនោះមានឈ្មោះដូចជា ផន ប្រធានក្រុមយោធាស្រុកចម្ការលើ។ សុង អនុប្រធានក្រុមយោធាស្រុកចម្ការលើ។ លី ជាសមាជិកគណៈសេដ្ឋកិច្ចស្រុកចម្ការលើ។ បន្ទាប់ពីណែនាំឲ្យស្គាល់គ្នារួចហើយ ផន បានកោះប្រជុំកម្លាំងដើម្បីរៀបចំផែនការធ្វើសកម្មភាពនៅស្រុកចម្ការលើ។ នៅទីនោះ ក្រុមរបស់ខ្ញុំដែលរួមមាន ផន, សុង និង លី បាននាំគ្នាដើរបំភ្លៃមាគ៌ានយោបាយរណសិរ្ស។ ក្រៅពីនេះខ្ញុំក៏បានបំផ្លាញសេដ្ឋកិច្ចរបស់អង្គការដោយបានធ្វើឲ្យបែកចាន ឆ្នាំង ស្លាបព្រា និងវែកអស់ជាច្រើន។ ក្រោយមកទៀត ម៉ន ដែលជាប្រធានយោធាក្នុងកងអនុសេនាតូច ភូមិភាគខត្តរ សមរភូមិរលួស ត្រូវបានអង្គការបញ្ជូនឲ្យមកធ្វើជាគណៈស្រុកនៅចម្ការលើវិញ។ ពេលនោះគាត់បានដកខ្ញុំមកជាមួយ ដោយគាត់បានឲ្យខ្ញុំធ្វើជានីរសាររត់សំបុត្រឲ្យគាត់។ បងម៉ន បានបញ្ចុះបញ្ចូលខ្ញុំឲ្យខំតស៊ូក្នុងន័យស្នេហាជាតិ ប្រជាជន និងខ្លួនឯង។ គាត់បានលើកពីចំណុចខ្សោយបដិវត្តន៍ ដោយគាត់លើកឡើងអំពីកម្លាំងរបស់សម្ដេច នរោត្តម សីហនុ ដែលមានប្រជាជនស្គាល់ច្រើនចំណែកអង្គការគ្មានប្រជាជនណាស្គាល់ទេ។ ជាពិសេសខ្មែរក្រហមបានដឹកនាំតាមបែបលទ្ធិកុម្មុយនីស្ដដែលប្រជាជនស្អប់ និងប្រឆាំងរបបនេះ ជាយូណាស់មកហើយ។ គាត់បានលើកសរសើរពីចំណុចខ្លាំងរបស់ប្រទេសអាមេរិកថា ការដឹកនាំនយោបាយរបស់គេមានលក្ខណៈប្រជាធិបតេយ្យ ប្រជាជនរស់នៅមានសិទ្ធិសេរីភាព សម្បូរសប្បាយ មានការរីកចម្រើនខ្លាំងខាងបច្ចេកទេសយោធា និងជាមហាអំណាចនៅលើសកលលោក។ បងម៉ន ក៏បាននិយាយប្រាប់ខ្ញុំទៀតថា មានអ្នកដឹកនាំជាច្រើនបានបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ ហើយក្រុមរបស់គាត់នឹងពង្រីកកម្លាំងក្នុងជួរបដិវត្តន៍ និងប្រជាជនឲ្យបានច្រើនបន្ថែមទៀត។ បន្ទាប់ពីទទួលបានការអប់រំបែបនេះហើយ កាន់តែធ្វើឲ្យខ្ញុំពេញចិត្តក្នុងការធ្វើការងារមួយនេះទៀត។ ក្រុមរបស់ខ្ញុំមាន ម៉ន, ឃួន, ផន, លីម និង កែវ បានប្រជុំធ្វើសកម្មភាពនៅខេត្តកំពង់ធំ ក្នុងស្រុកស្ទោង, ស្រុកសន្ទុក និងកំពង់ស្វាយ។ ក្រុមខ្ញុំមានផែនការបំផុសប្រាប់ប្រជាជន ពីចំណុចខ្សោយរបស់បដិវត្តន៍ និងលើកពីចំណុចខ្លាំងរបស់កងទ័ព លន់ នល់ ដែលមានអាវុធ និងសម្ភារសម្បូរបែប និងទំនើបៗ។ ការបំផុសនេះក្នុងគោលដៅឲ្យប្រជាជនអស់ជំនឿលើកម្លាំងបដិវត្តន៍ និងរត់ចូលតំបន់ លន់ នល់។

នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំបានចូលជាសមាជិកយុវជននៅតំបន់៣២ ដែលមានឈ្មោះ ឌឿន ជាប្រធានគ្រប់គ្រង។ ក្រោយមក ឃួន បានប្រាប់ ឌឿន ថា ខ្ញុំបានចូល សេ.អ៊ី.អា តាំងពីនៅមន្ទីរភូមិភាគខត្តរ។ ពេលដឹងថាខ្ញុំជាខ្សែបណ្ដាញ សេ.អ៊ី.អា ហើយ ឌឿន បានចាត់តាំងខ្ញុំឲ្យទៅនៅបុស្សខ្នុរដែលជាមន្ទីរសេដ្ឋកិច្ចតំបន់៣២ ដើម្បីដឹកជញ្ជូនស្បៀង។ ឌឿន បញ្ជូនបុរសម្នាក់ទៀតឈ្មោះ សុង ឲ្យមករស់នៅជាមួយខ្ញុំ។ ខ្ញុំ និង សុង ត្រូវបានអង្គការប្រើឲ្យដឹកជញ្ជូនអង្ករ អំបិល ប្រហុក ត្រីងៀត យកទៅមន្ទីរពេទ្យយោធាពិការ។ ពេលនោះខ្ញុំ បានរៀបចំផែនការដឹករបស់ហូបណាដែលខូចគុណភាពបរិភោគមិនកើតយកទៅឲ្យយោធាពិការ ដែលនៅសម្រាកមន្ទីរពេទ្យ ដើម្បីឲ្យក្រុមទាំងនោះយល់ថា អង្គការមិនយកចិត្តទុកដាក់ចំពោះខ្លួន។ ក្រោយមក ឌឿន បានផ្លាស់ខ្ញុំឲ្យទៅនៅការដ្ឋានកាប់ព្រៃនៅតំបន់៣២ នៅសង្កាត់ក្បាលដំរី ស្រុកសណ្ដាន់វិញ។ នៅទីនោះប្រជាជនមានការភ័យខ្លាចជំងឺគ្រុនចាញ់ ព្រោះប្រសិនបើឈឺហើយកម្រនឹងមានអ្នកគេចផុតពីការស្លាប់ណាស់។ ប្រជាជនជាច្រើន បានស្លាប់បាត់បង់ជីវិតដោយសារជំងឺនេះ។ ស្ថិតក្នុងសភាពការណ៍បែបនេះ ខ្ញុំបានបំផុសប្រជាជនដែលធ្វើការនៅការដ្ឋានកាប់ព្រៃទាំងនោះ រត់ចោលការដ្ឋានការងារ។ អ្នកណាក៏ខ្លាចដែរនៅពេលឮអំពី

ជំងឺគ្រុនចាញ់ ហើយពីមួយថ្ងៃទៅមួយថ្ងៃមានប្រជាជនជាច្រើនបានរត់ចោលការដ្ឋាន។

ក្រោយមកឈ្មោះ ឌឿន បានផ្លាស់ខ្ញុំឲ្យទៅនៅខាងសិល្បៈឃោសនាការនៅភូមិភាគឧត្តរ។ តាមការចាត់តាំងរបស់អង្គការ ខ្ញុំបានទៅដល់វិទ្យុរណសិរ្សនៅវៀតណាមខាងជើងជាមួយនារី២នាក់ទៀតឈ្មោះ វ៉ត់ និង អ៊ុម។ នៅទីនោះក្រុមរបស់ខ្ញុំមានតួនាទីត្រូវធ្វើការទាក់ទងនឹងសិល្បៈជាមួយជនជាតិវៀតណាម។ ឆ្លៀតឱកាសនោះ ក្រុមរបស់ខ្ញុំមានផែនការធ្វើយ៉ាងណាឲ្យមានវិបត្តិជាមួយបរទេសដើម្បីបំផ្លាញបដិវត្តន៍។ បន្ទាប់ពីធ្វើការនៅប្រទេសវៀតណាមបានមួយរយៈ អង្គការបានចាត់តាំងក្រុមខ្ញុំ ឲ្យមកនៅសិល្បៈឃោសនាការភ្នំពេញវិញ ហើយខ្ញុំ បានជួបជាមួយខ្សែបណ្តាញប្រឆាំងបដិវត្តន៍ចាស់ដែលមានឈ្មោះ ម៉ម, ឃួន និង កែវ។ យើងបានប្រជុំគ្នា ដើម្បីបន្តផែនការបំផ្លាញបដិវត្តន៍តទៅទៀត។ នៅក្នុងក្រសួងឃោសនាការ ក្រុមរបស់ខ្ញុំបានរៀបចំផែនការឃោសនាបំផុសប្រជាជនឲ្យចូលរួមប្រឆាំងបដិវត្តន៍។ នៅឡុងពេលនោះ អង្គការបានចាប់ខ្លួន ហ៊ូ នឹម ហៅ ភាស់ ដែលជាគណៈក្រសួងឃោសនាការ។ ក្រោយមកទៀត អង្គការក៏បានចាប់ខ្លួនមេដឹកនាំក្រុមរបស់ខ្ញុំទាំងអស់ជាបន្តបន្ទាប់។ ខ្ញុំមានការភិតភ័យចំពោះការចាប់ខ្លួនអ្នកទាំងនោះ។ រហូតមកដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៧៧ ខ្ញុំក៏ត្រូវបានអង្គការចាប់ខ្លួនពីបទជាប់ទាក់ទងខ្សែបណ្តាញ សេ. អ៊ី .អា។

**ផាត ចាន់សុនិតា**

*កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់ដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានឡើយថា ចម្លើយរបស់អ្នកទោស ភោគ អ៊ុម ហៅ ហ៊ាង នេះពិតប្រាកដយ៉ាងណានោះទេ។*



កងសិល្បៈខ្មែរក្រហម នៅប្រាសាទបន្ទាយស្រី ខេត្តសៀមរាប

# មជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា៖ កន្លែងតម្កល់ឯកសារ តាំងពិព័រណ៍ និងសម្តែងសិល្បៈ

មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំនូវកម្មវិធីសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅតាមបណ្តាខេត្តផ្សេងៗនៃប្រទេសកម្ពុជា។ នាពេលថ្មីៗនេះ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ត្រូវបានសម្តែងនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ដែលជាតាំងមួយនៃមជ្ឈ-មណ្ឌលឯកសារភូមិភាគបូព៌ាបង្កើតឡើងដោយក្រសួងអប់រំយុវជននិងកីឡាសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ មជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា បានតម្កល់ទុកឯកសារជាង១លានទំព័រ ក្នុងនោះមានឯកសារថតចម្លងប្រភេទជាក្រដាសជាង៨.000ទំព័រ ទាក់ទងនឹងភូមិភាគបូព៌ា និងឯកសារដែលផ្ទុកក្នុងទិន្នន័យកុំព្យូទ័រ រួមមាន៖ រូបភាព សំឡេង វីដេអូ និងបទសម្ភាសន៍ទាក់ទងនឹងរបបខ្មែរក្រហម។ មជ្ឈមណ្ឌលនេះ ក៏មានដាក់តាំងពិព័រណ៍រូបថតចល័ត និងអបិរក្រ្ទ័យរបស់មេដឹកនាំភូមិភាគបូព៌ាដែរ។ ប្រជាជននៅតាមមូលដ្ឋាន សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវនៅតាមបណ្តាខេត្តអាចស្វែងរកឯកសារ និងទស្សនាការតាំងពិព័រណ៍ នៅមជ្ឈ-មណ្ឌលឯកសារភូមិភាគបូព៌ា។

នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ព្រៃវែងគឺជាខេត្តមួយស្ថិតក្នុងចំណោមខេត្តបួនផ្សេងទៀត ដែលត្រូវបានមេដឹកនាំរបបខ្មែរក្រហម ចាត់ចូលទៅក្នុងរចនាសម្ព័ន្ធនៃភូមិភាគបូព៌ា។ ភូមិភាគមួយនេះ ត្រូវបានខ្មែរក្រហមបែងចែកចេញជាប្រាំតំបន់គឺតំបន់២០ តំបន់២១ តំបន់២២ តំបន់២៣ និងតំបន់២៤។ តំបន់ទាំងអស់នេះត្រូវបានបែងចែកចេញជា៣០ស្រុក ហើយស្រុកនីមួយៗត្រូវបានបែងចែកចេញជាឃុំ និងភូមិជាច្រើនទៀត។ ភូមិភាគបូព៌ាមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាមនៅប៉ែកខាងកើត និងទន្លេមេគង្គនៅប៉ែកខាងលិច។ មួយភាគធំនៃភូមិភាគបូព៌ាជាដីស្រែដែលពឹងផ្អែកទៅលើប្រភពទឹកទន្លេមេគង្គ ក្នុងការស្រោចស្រពដំណាំ។ ភូមិភាគបូព៌ាស្ថិតក្រោមការគ្រប់គ្រងរបស់ សោ ភឹម ដែលជាលេខាបក្សភូមិភាគ។ អំឡុងពេលដែលមានការប៉ះទង្គិចនៅតាមព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមកាន់តែខ្លាំងឡើង បក្សកុម្មុយនីស្តកម្ពុជាបានចោទប្រកាន់ប្រធានភូមិភាគនេះថា ក្បត់អង្គការ។ បក្សកុម្មុយនីស្តកម្ពុជា បានបញ្ជូនកងទ័ពមជ្ឈិមជាច្រើនដើម្បីទៅបោសសម្អាតកម្មាភិបាល និងកងទ័ពនៅភូមិភាគបូព៌ា។ សោ ភឹម


នៅ សាវ៉ាន គឺជាប្រជាជនដែលបានចូលរួមទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅក្នុងបរិវេណសាលាគរុកោសល្យភូមិភាគព្រៃវែង រៀបរាប់ពីបទពិសោធន៍របស់គាត់នៅក្នុងសម័យខ្មែរក្រហម

ត្រូវបានឡោមព័ទ្ធពីសំណាក់កងទ័ពមជ្ឈិម និងបានសម្រេចចិត្តធ្វើអត្តឃាតខ្លួនឯង។ ចំណែកកម្មាភិបាល និងកងទ័ពនៅក្នុងភូមិភាគនេះត្រូវបានអង្គការចាត់ទុកថាជាខ្មាំង ហើយប្រជាជនត្រូវបានជម្លៀសឲ្យទៅរស់នៅតំបន់ផ្សេង និងត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់។ ប្រជាជននៅភូមិភាគបូព៌ាបានទទួលរងគ្រោះធ្ងន់ធ្ងរ ដោយសារការកាប់សម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សោកនាដកម្មដ៏រន្ធត់នេះនៅតែដិតដាមជាប់ជានិច្ច ក្នុងអារម្មណ៍របស់ប្រជាជន។ ទោះបីរបបខ្មែរក្រហមដួលរលំទៅហើយក្តី ក៏ការស្អប់ និងគំនុំគុំកួននៅតែបន្តកើតមានរវាងជនរងគ្រោះ និងជនដៃដល់មកដល់ពេលបច្ចុប្បន្ន។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំឲ្យមានការសម្តែងល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» ក្នុងគោលបំណងធ្វើឲ្យមានការផ្សះផ្សាគ្នា នៅក្នុងសង្គមកម្ពុជា និងដើម្បីព្យាបាលដោយសារតែការឈឺចាប់ ការបាត់បង់សាច់ញាតិ និងមនុស្សជាទីស្រឡាញ់នៅក្នុងរបបខ្មែរក្រហម។

បន្ទាប់ពីបានចូលរួមទស្សនាការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅក្នុងបរិវេណសាលាគរុកោសល្យភូមិភាគព្រៃវែង រួចមក អ្នកទស្សនាបានបញ្ចេញនូវចំណាប់អារម្មណ៍ និងបទពិសោធន៍នៅក្នុងរបបខ្មែរក្រហមដូចខាងក្រោម៖

១) នៅ សាវ៉ាន ភេទស្រី អាយុ៦៧ឆ្នាំ បច្ចុប្បន្នមានទីលំនៅរស់នៅ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង បានមានប្រសាសន៍ថា នៅពេលរំឭកទៅដល់សម័យខ្មែរក្រហម បានធ្វើឲ្យខ្ញុំនឹកឃើញដល់រឿងរ៉ាវឈឺចាប់ជាច្រើន ដែលខ្ញុំបានជួបប្រទះនៅក្នុងអំឡុងពេលនោះ។ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅកងចល័តលើកទំនប់នៅស្រុកព្រះស្តេច ខេត្តព្រៃវែង។ ប្រធានកងចល័តបានប្រើខ្ញុំឲ្យជីកដី និងរែកដីតាំងពីព្រឹករហូតដល់យប់។ ចំពោះរបបអាហារនៅទីនោះ ខ្ញុំទទួលបានបបររាវពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ។ ដោយសារតែគ្រួសាររបស់ខ្ញុំភាគច្រើន គឺជាមន្ត្រីរាជការនៅក្នុងរបបសង្គមរាស្ត្រនិយម និងរបប លន់ នល់ ដូច្នេះគ្រួសារខ្ញុំត្រូវទទួលរងនូវការធ្វើបាបយ៉ាងខ្លាំង។ នៅឆ្នាំ១៩៧៧ ឪពុករបស់ខ្ញុំត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួនយកទៅដាក់គុកនៅទួលម្រិញ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ គាត់ត្រូវបានចោទប្រកាន់ពីបទជាប់និន្នាការសង្គមចាស់។ ដោយសាររងទារុណកម្មធ្ងន់ធ្ងរពេក ឪពុកខ្ញុំបានធ្លាក់ខ្លួនឈឺហើយក៏បានស្លាប់បាត់បង់ជីវិតទៅ។ ក្រៅពីឪពុកខ្ញុំ នៅមានបងប្អូនថ្លៃរបស់ខ្ញុំបួន


ស្រេង ពិសី គឺជានិស្សិតឆ្នាំទី២ ឯកទេសប្រវត្តិវិទ្យានៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ


សេង ស៊ីណារ៉ាត់ គឺជានិស្សិតឆ្នាំទី៣ ឯកទេសប្រវត្តិវិទ្យានៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ


រ៉ូ សោភ័ណ្ឌ គឺជាគរុសិស្សឆ្នាំទី១ ឯកទេសរូបវិទ្យានៃសាលាគរុកោសល្យភូមិភាគ ខេត្តព្រៃវែង

នាក់ផ្សេងទៀត ដែលត្រូវបានយោធាខ្មែរក្រហមយកទៅសម្លាប់ ដោយសារតែសាច់ញាតិរបស់ខ្ញុំទាំងនោះ ជាអតីតអ្នករដ្ឋការជំនាន់ចាស់។ ប្រធានដែលគ្រប់គ្រងនៅកងចល័តរបស់ខ្ញុំឈ្មោះ ម៉ែន។ គាត់បានធ្វើបាប និងកាប់សម្លាប់ទៅលើប្រជាជនស្លូតត្រង់អស់ជាច្រើន។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ ម៉ែន ត្រូវបានសាច់ញាតិជនរងគ្រោះសម្លាប់ដើម្បីសងសឹកវិញ។ ខ្ញុំតែងតែនិយាយពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមទាំងនេះប្រាប់ទៅដល់កូនចៅជំនាន់ក្រោយ ប៉ុន្តែកូនចៅរបស់ខ្ញុំមិនជឿនូវអ្វីដែលកើតឡើងទាំងនោះទេ។ នៅពេលដែលខ្ញុំបានទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ធ្វើឲ្យខ្ញុំមានអារម្មណ៍នឹកឃើញទៅដល់រឿងរ៉ាវឈឺចាប់ ដែលខ្ញុំបានឆ្លងកាត់នៅក្នុងសម័យខ្មែរក្រហម។ ជាពិសេសធ្វើឲ្យខ្ញុំនឹកឃើញដល់សិល្បៈនៅសម័យនោះ ដោយសារខ្ញុំធ្លាប់បានព្យុតែបទចម្រៀងបដិវត្តន៍ចាក់តាមមេក្រូ ដែលបម្រើឲ្យគោលនយោបាយរបស់អង្គការខ្មែរក្រហម។ បើទោះបីជាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» បានធ្វើឲ្យខ្ញុំនឹកឃើញដល់រឿងរ៉ាវរន្ធត់ដែលបានកើតនៅក្នុងអំឡុងពេលនោះ ប៉ុន្តែខ្ញុំមានការសប្បាយចិត្តដោយសារតាមរយៈអត្ថន័យនៃសាច់រឿងបានឆ្លុះបញ្ចាំងឲ្យក្មេងជំនាន់ក្រោយបានដឹងពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដើម្បីឲ្យអ្នកទាំងនោះ ចូលរួមទប់ស្កាត់របបនេះមិនឲ្យកើតឡើងសាជាថ្មី។ ជាពិសេសតាមរយៈល្ខោននេះបានអប់រំឲ្យមានការអន់ខិនឲ្យគ្នាទៅវិញទៅមករវាងជនរងគ្រោះនិងជនដៃដល់។ ចំពោះខ្លួនខ្ញុំផ្ទាល់ បើទោះបីជាយោធាខ្មែរក្រហមបានសម្លាប់ឪពុក និងបងប្អូនរបស់ខ្ញុំអស់ច្រើន ប៉ុន្តែខ្ញុំមិនដែលមានគំនិតគុំកួន ឬសងសឹកចំពោះឃាតករទាំងនោះឡើយ។

២) ស្រេង ពិសី ភេទប្រុស អាយុ២៥ឆ្នាំ គឺជានិស្សិតឆ្នាំទី២នៃដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានលើកឡើងថា បន្ទាប់ពីបានទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»រួច ខ្ញុំពិតជាមានអារម្មណ៍សោកសង្រេងយ៉ាងខ្លាំងចំពោះរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ តាមរយៈអត្ថន័យនៃសាច់រឿងនេះបានរំលេចនូវរឿងរ៉ាវជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលជារបបមួយដ៏សាហាវយង់ឃ្នង់សម្លាប់ប្រជាជនខ្មែរអស់ជាច្រើនលាននាក់។ លើសពីនេះទៅទៀតល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអប់រំយុវជនជំនាន់ក្រោយ ឲ្យបានយល់ដឹងកាន់តែប្រសើរឡើងពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ម្យ៉ាងវិញទៀតល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» បានជួយជំរុញឲ្យប្រជាជនខ្មែរដែលធ្លាប់បានឆ្លងកាត់របបនោះ ហ៊ាននិយាយពីភាពឈឺចាប់ដែលខ្លួនបានជួបប្រទះ ព្រមទាំងរឿងរ៉ាវអាថ៌កំបាំងផ្សេងៗទៀតដែលបានកើតឡើង ដើម្បីចែករំលែកបទពិសោធន៍ទាំងនេះទៅដល់អ្នកជំនាន់ក្រោយបានដឹង និងទប់ស្កាត់របបនេះមិនឲ្យកើតឡើងវិញ។

៣) សេង ស៊ីណារ៉ាត់ ភេទស្រី អាយុ២០ឆ្នាំ ជានិស្សិតនៃដេប៉ាតេម៉ង់ប្រវត្តិវិទ្យាមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានលើកឡើងថា ខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ដែលមានឱកាសបានចូលរួមទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»។ តាមរយៈការសម្តែងរបស់តួអង្គបានធ្វើឲ្យខ្ញុំដែលជាអ្នកទស្សនានឹកស្រមៃទៅដល់ទុក្ខលំបាកដែលបានកើតឡើងចំពោះប្រជាជនខ្មែរនាអំឡុងពេលនោះ។ លើសពីនេះទៅទៀត នៅក្នុងឈុតឆាកនៃការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» បានផ្តល់នូវតម្លៃអប់រំឲ្យយុវជនជំនាន់ក្រោយចេះគិតពិចារណា ចង់ចេះចង់ដឹងពីរឿងរ៉ាវអតីតកាលដែលបានកើតឡើងចំពោះប្រទេសជាតិរបស់ខ្លួន។ ជាពិសេសអប់រំឲ្យមនុស្សដែលប្រព្រឹត្តខុសចេះសារភាពនូវទោសកំហុសដែលខ្លួនបានធ្វើ និងអប់រំឲ្យមនុស្សឲ្យចេះអត់ឱនយោគយល់ អធ្យាស្រ័យចំពោះគ្នាទៅវិញទៅមក។ សម្រាប់ខ្លួនខ្ញុំផ្ទាល់ មិនចង់ជួបរឿងរ៉ាវដ៏សែនឈឺចាប់ដូចរបបខ្មែរក្រហមនេះទេ ហើយខ្ញុំគិតថាការសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រ អាចជួយបញ្ចៀសរបបប្រល័យពូជសាសន៍នេះមិន

ឲ្យកើតឡើងនៅក្នុងប្រទេសកម្ពុជាម្តងទៀត។

៤) រ៉ូ សោភ័ណ្ឌ ភេទប្រុស អាយុ២២ឆ្នាំ ជាគរុសិស្សឯកទេសរូបវិទ្យានៃសាលាគរុកោសល្យភូមិភាគព្រៃវែងបានលើកឡើងថា ក្រោយពីបានទស្សនាល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់»រួច ខ្ញុំពិតជាមានការចាប់អារម្មណ៍ចំពោះការសម្តែងទាំង៨ឈុត ដែលបានឆ្លុះបញ្ចាំងពីជីវិតរស់នៅរបស់ប្រជាជនខ្មែរ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តាមរយៈអត្ថន័យនៃល្ខោននិយាយបានធ្វើឲ្យខ្ញុំយល់ដឹងស៊ីជម្រៅបន្ថែមទៀត ពីរបបខ្មែរក្រហម ដែលបានកាប់សម្លាប់ទៅលើជនជាតិខ្មែរគ្នាឯង។ ជាពិសេសធ្វើឲ្យសិស្សានុសិស្សបានសិក្សាកាន់តែច្បាស់នូវប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីបង្កាកុំឲ្យរបបនេះកើតឡើងវិញ។

ការសម្តែងល្ខោនមិនត្រឹមតែនាំមកនូវការពិភាក្សា និងការផ្សះផ្សាប៉ុណ្ណោះទេ ប៉ុន្តែនឹងផ្តល់នូវការអប់រំអំពីរបបខ្មែរក្រហមដល់សិស្ស និស្សិតដែលបានចូលរួមទស្សនាថែមទៀតផង។

**ផាត ចាន់សុនិតា**



សិស្សានុសិស្សទស្សនាការតាំងពិព័រណ៌រូបថតមេដឹកនាំខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា

# ភូមិភាគបូព៌ាផ្សាភ្ជាប់អតីតកាល និង បច្ចុប្បន្ន ទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម

ខេត្តព្រៃវែង គឺជាខេត្តមួយដែលស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា ហើយជាខេត្តមួយដែលមានសក្តានុពលខាងវិស័យកសិកម្មដែរ។ ខេត្តព្រៃវែង ស្ថិតនៅក្នុងចំណោមខេត្តដែលកើតមាននូវចលនាកុម្មុយនីស្តដំបូងៗ សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា ហើយបុគ្គលមានអំណាចទី៤ បន្ទាប់ពី ប៉ុល ពត, នួន ជា និង អៀង សារី។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ សោ ភឹម ត្រូវបានចោទប្រកាន់ថា ក្បត់នឹងបក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់ពីមានព្រឹត្តិការណ៍នេះកើតឡើង ប្រជាជនភូមិភាគបូព៌ាបានក្លាយជាមុខសញ្ញានៃការរើសអើង និងយកទោសម្លាប់ពីសំណាក់មេដឹកនាំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងការលើកកម្ពស់ដល់ការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីប្រវត្តិសាស្ត្រអតីតកាល មូលហេតុដែលបានកើតឡើង និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាស្ថាប័នឯករាជ្យ បានធ្វើការសិក្សាស្រាវជ្រាវនិងចងក្រងឯកសារប្រវត្តិសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យធំជាងគេបង្អស់ក្នុងប្រទេសកម្ពុជា។ ដោយស្វែងយល់ពីតម្រូវការរបស់ប្រជាជនមូលដ្ឋាន និងបទពិសោធន៍... 

ដោយស្វែងយល់ពីតម្រូវការរបស់ប្រជាជនមូលដ្ឋាន និងបទឧក្រិដ្ឋតែងកើតមាននៅមូលដ្ឋានមជ្ឈ-មណ្ឌលឯកសារកម្ពុជាជា បានបង្កើតនូវមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា។ មជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា មានទីតាំងស្ថិតនៅក្នុងបរិវេណនៃសាលាគរុសល្យភូមិភាគព្រៃវែងហើយក៏ត្រូវបានដាក់ឈ្មោះតាមតំបន់ដែល សោ ភឹម ធ្លាប់បានគ្រប់គ្រងក្នុងគោលបំណងចងចាំប្រវត្តិសាស្រដ៏សែនសោកសង្រេងដែលមិនត្រូវបានបំភ្លេចៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យភូមិភាគបូព៌ា រួមមាន៖ ខេត្តព្រៃវែង ស្វាយរៀង និងផ្នែកខ្លះនៃខេត្តកំពង់ចាម ដែលស្ថិតនៅត្រើយខាងកើតនៃទន្លេមេគង្គទាំងអស់, ផ្នែកខ្លះដែលកាត់ចេញពីខេត្តក្រចេះគឺ ស្រុកឆ្លូង និងផ្នែកខ្លះដែលកាត់ចេញពីខេត្តកណ្តាល ដែលរួមមាន ស្រុកខ្សាច់កណ្តាល ល្វាឯម និងមុខកំពូល។ មជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា បានជួយប្រជាជននៅតាមមូលដ្ឋាន និងសិស្សនិស្សិតនៅតាមបណ្តាខេត្ត អាចស្វែងរកឯកសារទាក់ទងនឹងប្រធានបទរបស់ខ្លួននៅក្នុងខេត្តរបស់ខ្លួនផ្ទាល់ ដោយមិនមែនប្រមូលផ្តុំតែនៅក្នុងទីក្រុងភ្នំពេញ។ នៅក្នុងនោះមជ្ឈមណ្ឌលឯកសារភូមិភាគ


ពិព័រណ៍រូបថតនៅមជ្ឈម

បូព៌ា បានរក្សាទុកឯកសារជាច្រើន រួមមានៈ រូបភាព សំឡេង វីដេអូ បទសម្ភាសន៍។ មិនត្រឹមតែប៉ុណ្ណោះ កាលពីដើមខែឧសភា មជ្ឈមណ្ឌលឯកសារកម្ពុជា បាននាំយកនូវល្ខោននិយាយដែលមានចំណងជើងថា «ទម្លាយភាពស្ងៀមស្ងាត់» ទៅសម្តែងជូនប្រជាជន សិស្ស និស្សិត នៅក្នុងខេត្តព្រៃវែង ទស្សនា។ ល្ខោននេះក៏ជាវេទិកាសម្រាប់ពិភាក្សារវាងអ្នកគាំទ្រ និងអ្នកដែលមិនគាំទ្ររបបខ្មែរក្រហម។

កែម យន ដែលមានអាយុ ៧២ឆ្នាំ រស់នៅក្នុងស្រុកកំពង់ត្របែក បានបង្ហាញនូវសេចក្តីរំភើបនៅពេលបានទស្សនាល្ខោននិយាយនេះ និងបាននឹកឃើញពីជីវិតដែលគាត់ធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម។ យន បានបង្ហាញពីអារម្មណ៍របស់ម្តាយអាណិតកូននៅក្នុងសាច់រឿងល្ខោន។ កាលនោះ កូនប្រុសរបស់គាត់ដែលមានអាយុប្រហែល២ឆ្នាំ គ្មានអាហារ


...ណ្ឌលឯកសារភូមិភាគបូព៌ា

សម្រាប់ហូបឡើយ។ យន បានទៅសុំរបបអាហារពីចុងភៅនៅរោងបាយរួមឲ្យកូន ប៉ុន្តែប្រធានរោងបាយបានបដិសេធ ហើយថែមទាំងចោទគាត់ថា យកអាហារទៅចិញ្ចឹមខ្មាំងទៀតផង។ កូនរបស់ យន បានយំរហូតខ្សោះខ្លួន ដោយសារតែស្រេកឃ្លានខ្លាំង។ យន បានបន្ថែមថា «ក្មេងជំនាន់ក្រោយដូចជាកូនស្រីរបស់ខ្ញុំកើតមិនទាន់របបខ្មែរក្រហមឡើយ ហើយពេលខ្ញុំនិយាយប្រាប់ ក៏កូនរបស់ខ្ញុំមិនជឿដែរ»។ យន ចង់ឲ្យក្មេងជំនាន់ក្រោយបានទស្សនាល្ខោននេះ។

ភួង សុគន្ធ អាយុ៣២ឆ្នាំ មានស្រុកកំណើតនៅក្រុងព្រៃវែង មានចិត្តសប្បាយរីករាយដែលបានឃើញមជ្ឈមណ្ឌលឯកសារកម្ពុជាយកការសម្តែងនេះជាការអប់រំ។ ល្ខោននេះបានធ្វើឲ្យយុវជនកម្ពុជាដែលកើតក្រោយឆ្នាំ១៩៧៩ ដឹងពីការលំបាក និងទុក្ខវេទនារបស់ ឪពុកម្តាយ និងប្រជាជនកម្ពុជា។ ភួង បានចាប់អារម្មណ៍ចំពោះឈុតចុងក្រោយដែលមានយុវជនម្នាក់គឺជាក្មេងជំនាន់ក្រោយ ដែលជាអ្នកមិនបានឆ្លងកាត់របបខ្មែរក្រហមឡើងសួរសំណួរ។ ភួង បានលើកឡើងថា ឪពុកម្តាយដែលបានឆ្លងកាត់នូវរបបខ្មែរក្រហមត្រូវតែចែករំលែកបទពិសោធ៍ដែលខ្លួនបានឆ្លងកាត់ទៅកាន់កូន ព្រោះកូនៗ ក៏មានសិទ្ធិក្នុងការស្វែងយល់នូវប្រវត្តិសាស្ត្រដែលបានកើតឡើងដែរ ហើយវាគឺជាវិធីសាស្ត្រក្នុងការដោះស្រាយ និងទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងម្តងទៀត។ ភួង មានភាពរីករាយដែលមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា បង្កើតមជ្ឈមណ្ឌលឯកសារភូមិបូព៌ានៅក្នុងខេត្តព្រៃវែង ព្រោះបានធ្វើឲ្យប្រជាជន សិស្ស និស្សិត និងអ្នកស្រាវជ្រាវដែលរស់នៅក្នុងមូលដ្ឋាន មានភាពងាយស្រួលក្នុងការអានឯកសារ។

អ៊ុង ស្រីមុំ គឺជាគរុសិស្សនៅខេត្តព្រៃវែង ចង់ឲ្យមានការរៀបចំកម្មវិធីសម្តែងបែបនេះជារៀងរាល់ឆ្នាំ ព្រោះបានបង្ហាញនូវតម្លៃអប់រំដល់យុវជនជំនាន់ក្រោយដែលមិនបានឆ្លងកាត់នូវភាពលំបាកវេទនា។ ស្រី មុំ ចាប់អារម្មណ៍ ក្នុងឈុតដែលមានក្មេងស្រីម្នាក់ដែលបានលួចអង្កររបស់គ្រួសារ

ដែលកំពុងតែខ្វះខាត។ ប៉ុន្តែម្តាយមិនបានចាប់កំហុសរបស់កូនទេ ហើយក្តីស្រឡាញ់របស់ម្តាយមិនប្រែប្រួលចំពោះកូនដែរ។

លោកបួយ វុទ្ធី ដែលជានាយកគរុកោសល្យភូមិភាគខេត្តព្រៃវែង បានសម្តែងក្តីរីករាយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្សព្វផ្សាយសម្រាប់ក្មេងជំនាន់ក្រោយដែលមិនបានឆ្លងកាត់ លោកបានលើកឡើងថា «គ្មានប្រជាជនកម្ពុជាណាម្នាក់ដែលមិនបានបាត់បង់សមាជិក ឬសាច់ញាតិរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមឡើយ»។ ក្មេងជំនាន់ក្រោយត្រូវតែចងចាំ និងរៀនសូត្រពីប្រវត្តិសាស្ត្រ ដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត។ លោកក៏បានលើកទឹកចិត្តឲ្យសិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនចូលមកអាន និងស្រាវជ្រាវឯកសារនៅមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ាដែរ។

**ដារ៉ារដ្ឋ មេត្តា**


ភ្នំឈើកាច់ នៅក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង

# សន្និសីទស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

សន្និសីទស្តីពីអំពើប្រល័យពូជសាសន៍ នឹងមានការអញ្ជើញចូលរួមពីលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យមកពីសាកលវិទ្យាល័យរដ្ឋ និងឯកជនចំនួន៥០នៅទូទាំងប្រទេសកម្ពុជា រួមជាមួយអ្នកជំនាញផ្នែកប្រវត្តិសាស្ត្រអន្តរជាតិជាច្រើនរូបទៀត ដើម្បីពិភាក្សាអំពី «អំពើប្រល័យពូជសាសន៍នៅកម្ពុជា និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រសកលលោក»។ សន្និសីទនេះនឹងប្រព្រឹត្តទៅរយៈពេលបីថ្ងៃ នៅក្នុងខែមេសា ឆ្នាំ២០១៩ នៅសាលសិល្បៈសហសម័យវិទ្យាស្ថានស្ទឹករីត អគារ H ក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ក្រោមការរៀបចំរបស់ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងមានការចូលរួមជាគណអធិបតីពីលោកជំទាវ ទន់ សាអ៊ឹម អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ លោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកតំណាងរបស់សហភាពអឺរ៉ុបប្រចាំនៅកម្ពុជា។

គោលបំណងចម្បងនៃសន្និសីទនេះគឺដើម្បីពង្រីកចំណេះដឹង និងពង្រឹងជំនាញវិជ្ជាជីវៈរបស់សាស្ត្រាចារ្យសាកលវិទ្យាល័យនៅកម្ពុជា។ ដោយមានការចូលរួមពីលោកគ្រូ-អ្នកគ្រូ សាស្ត្រាចារ្យ ព្រមទាំងអ្នកជំនាញផ្នែកប្រវត្តិសាស្ត្រ អប់រំ និងច្បាប់ ដូច្នេះមជ្ឈមណ្ឌលឯកសារកម្ពុជារំពឹងថា សន្និសីទនេះ នឹងផ្តល់ផលប្រយោជន៍ច្រើនដល់អ្នកចូលរួម។ សន្និសីទនេះ ក៏ជាផ្នែកមួយនៃគម្រោងស្តីពីការចងចាំ សន្តិភាព និងការផ្សះផ្សានៅកម្ពុជាតាមរយៈការសិក្សាឆ្លុះបញ្ចាំង និងការពិភាក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយក៏ស្ថិតនៅក្នុងគម្រោងសំណងតាមផ្លូវតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដែលត្រូវបានស្នើឡើងដើម្បីប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះក្នុងសំណុំរឿង ០០២/២» ដែរ។ ទោះបីសន្និសីទនេះពិភាក្សាទៅលើប្រធានបទប្រវត្តិសាស្ត្រខ្មែរក្រហម ប៉ុន្តែគោលដៅសំខាន់នៃសន្និសីទគឺពង្រីកការយល់ដឹងបន្ថែមសម្រាប់សាស្ត្រាចារ្យសាកលវិទ្យាល័យ ស្តីពីអំពើប្រល័យពូជសាសន៍ និងការសម្លាប់



១) លោកគ្រូអ្នកគ្រូ និងសាស្ត្រាចារ្យប្រវត្តិសាស្ត្រសួរសំណួរទៅវាគ្មិននៅក្នុងសន្និសីទស្តីពីអំពើប្រល័យពូជសាសន៍ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

វគ្គាលនៅក្នុងប្រវត្តិសាស្ត្រសកលលោក។

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា សន្និសីទនេះនឹងអាចជួយបង្កើតការយល់ដឹងរបស់អ្នកចូលរួមពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រជាតិរបស់ខ្លួន ពីភាពស្រដៀងគ្នា និងខុសប្លែកគ្នាជាមួយបទពិសោធន៍រឿងរ៉ាវដែលធ្លាប់បានកើតឡើងនៅប្រទេសផ្សេងៗទៀត ដូចជា នៅប្រទេសអាឡឺម៉ង់ រ៉្វាន់ដា បូស្នី និងប្រទេសអាម៉េនី។

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នឯករាជ្យ និងមិនមែនរាជរដ្ឋាភិបាលដែលធ្វើដំណើរឆ្ពោះទៅរកការជំរុញឲ្យមានការចងចាំ យុត្តិធម៌ និងនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា។ សន្និសីទនេះ ប្រព្រឹត្តទៅបានដោយមានការគាំទ្រពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា និងសហភាពអឺរ៉ុប តាមរយៈការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាកម្មគម្រោងជាពិសេស ការគាំទ្រផ្នែកហិរញ្ញវត្ថុពីសំណាក់ទីភ្នាក់ងារអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិហៅកាត់ថា USAID។

នៅក្នុងសន្និសីទស្តីពីអំពើប្រល័យពូជសាសន៍នេះនឹងមានការធ្វើបទបង្ហាញទៅលើប្រធានបទផ្សេងៗដោយសាស្ត្រាចារ្យអ្នកជំនាញមកពីសាកលវិទ្យាល័យល្បីៗនៅក្នុងប្រទេស និងក្រៅប្រទេស។ បណ្ឌិត ហ័ង ធីញ៉ាហុង សាស្ត្រាចារ្យមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រនៃសាកលវិទ្យាល័យជាតិវៀតណាម ក៏បានធ្វើបទបង្ហាញស្តីពី «ប្រតិបត្តិការរបស់កងទ័ពវៀតណាមដើម្បីផ្តួលរំលំរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩»។ លោក ឡាយ សួនចៀន ភារធារីនៃស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា ក៏បានធ្វើបទបង្ហាញអំពី«ទស្សនៈរបស់វៀតណាម ចំពោះជ័យជម្នះរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥»។ សាស្ត្រាចារ្យ ម៉ីលតុន អូស្សុន អ្នកជំនាញប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ បានធ្វើបទបង្ហាញស្តីពី«អំពើប្រល័យពូជសាសន៍ក្រោមរបបខ្មែរក្រហម»។ លោកសាស្ត្រាចារ្យ ភីអូត្រ អូស្តាហ្វស្គី អតីតសាកលវិទ្យាធិការរងនៃសាលាសេដ្ឋកិច្ចវ័រសរ បានធ្វើបទបង្ហាញអំពី«មនោគមន៍វិជ្ជាទាំងឡាយដែលនាំឲ្យមានអំពើប្រល័យពូជសាសន៍»។ លោក នីកូឡាស គាំចាន់ សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានធ្វើបទបង្ហាញអំពី«អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»។ លោកស្រី ខេលី វ៉តសុន នាយកកម្មវិធីអប់រំរបស់វិទ្យាស្ថានសិទ្ធិមនុស្សសម្រាប់គ្រូបង្រៀន បានធ្វើបទបង្ហាញស្តីពី «ការបូជាភ្លើងៈការសិក្សាប្រៀបធៀបពីអំពើប្រល័យពូជសាសន៍»។ គ្រីស្តូហ្វើ ឌៀរីង អ្នកនិពន្ធ និងកែសម្រួលសៀវភៅ «អំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រសកលលោក» បានធ្វើបទបង្ហាញអំពីសៀវភៅរបស់លោក។ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើបទបង្ហាញដោយផ្តោតលើ «ហេតុការណ៍សង្គម នយោបាយ សាសនា ច្បាប់ និងអប់រំដែលរួមចំណែកដល់ដំណើរការ នៃការផ្សះផ្សានៅប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ២០០៧ មុនពេលមានតុលាការខ្មែរក្រហម។ លោកស្រី រស់ វណ្ណា អ្នកនិពន្ធសៀវភៅ «ព្រលឹងមាសម្តាយ» បានរៀបរាប់គំនិតដែលនាំឲ្យស្រីសរសេរសៀវភៅនេះ និងអំពីបទពិសោធន៍របស់លោកស្រីនៅក្នុងរបបខ្មែរក្រហម។ លោក ម៉ន ម៉ៅ និង លោក ខៀន ពុំ នឹងធ្វើបទបង្ហាញស្តីពីបទពិសោធន៍ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

នៅក្នុងសន្និសីទខាងលើ ក៏មានការចាក់បញ្ចាំងខ្សែភាពយន្តឯកសារអប់រំខ្លីៗដែលផលិតដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ខ្សែភាពយន្តឯកសាររបស់វៀតណាម «ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូវៀតណាមក្នុងរបបខ្មែរក្រហមនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៥», ខ្សែភាពយន្តឯកសារអាឡឺម៉ង់ស្តីពី «ចលនាខ្មែរក្រហមនៅតាមបណ្តោយព្រំដែនកម្ពុជាថៃនៅក្នុងទសវត្សរ៍ ឆ្នាំ១៩៨០», ខ្សែភាពយន្ត«សាក្សីដំបូងដែលជាភាពយន្តឯកសារអំពីមន្ទីរស-២១» និង ខ្សែភាពយន្ត «ឆ្នាំព្រៃ»។ នៅក្នុងថ្ងៃបញ្ចប់នៃសន្និសីទនេះក៏មានការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ដែរ។

**ដាត ចាន់សុនិតា**

# ថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ»

វេទិកាថ្នាក់រៀន ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) ត្រូវបានរៀបចំឡើងនៅតាមបណ្តាវិទ្យាល័យនានាទូទាំងរាជធានី ខេត្ត ក្រុងនៃប្រទេសកម្ពុជា។ ថ្មីៗនេះ ក្រុមការងារនៃកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍ខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការរៀបចំកម្មវិធីនេះឡើងនៅវិទ្យាល័យពារាំង ស្ថិតក្នុងស្រុកពារាំង ខេត្តព្រៃវែង ដែលមានសិស្សថ្នាក់ទី១២ ចូលរួមចំនួន៨០នាក់។ លោក ផេង ពង្សរ៉ាស៊ី ជានាយកនៃកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើបទបង្ហាញរយៈពេលប្រមាណ២ម៉ោង ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យបង្រៀនដល់សិស្សានុសិស្សបានសិក្សាស្វែងយល់។

គោលបំណងនៃការបង្កើតកម្មវិធីនេះឡើងគឺ ដើម្បីជួយ


ទិដ្ឋភាពវិទ្យាល័យពារាំង


ពិព័រណ៍រូបថតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅវិទ្យាល័យពារាំង


សិស្សវិទ្យាល័យពារាំងកំពុងបំពេញសំណួរស្ទាបស្ទង់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម


សិស្សានុសិស្សនៅវិទ្យាល័យពារាំងចូលរួមវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រ ដែលរៀបចំឡើងគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ពង្រីកចំណេះដឹងរបស់សិស្សក្នុងការយល់ដឹងកាន់តែលម្អិតអំពីរបបប្រល័យពូជសាសន៍។ របបខ្មែរក្រហមបានប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម និងបានសម្លាប់ប្រជាជនខ្មែរអស់ប្រមាណជាងពីរលាននាក់។ ការបណ្តុះបណ្តាលវគ្គសិក្សានេះមានគោលដៅ ឲ្យក្មេងជំនាន់ក្រោយបានយល់ច្បាស់អំពីរបបប្រល័យពូជសាសន៍ ដើម្បីបង្កើនការគិតស៊ីជម្រៅពីការកសាងសន្តិភាព ការផ្សះផ្សា ព្យាបាលរបួសផ្លូវចិត្ត និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា មិនឲ្យកើតឡើងសាជាថ្មីម្តងទៀតនៅពេលអនាគត។

ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅពេលនេះគឺ លើកឡើងពីដើមកំណើតរបស់បក្សកុំមុយនីស្តកម្ពុជា ការឡើងកាន់អំណាចរបស់ខ្មែរក្រហម ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិប តេយ្យ ប្រព័ន្ធរដ្ឋបាលគ្រប់គ្រង ស្ថានភាពជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មន្ទីរសន្តិសុខ ទំនាក់ទំនងការបរទេស និងការដួលរលំនៃរបបប្រល័យពូជសាសន៍។

បន្ទាប់ពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ សិស្សបានបញ្ចេញមតិយោបល់ និងការចាប់អារម្មណ៍ដូចខាងក្រោម៖

១) សុផល លីសា ភេទស្រី អាយុ១៧ឆ្នាំ ជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យពារាំង បានលើកឡើងថា បន្ទាប់ពីខ្ញុំបានទទួលព័ត៌មានពីនាយកសាលាប្រកាសឲ្យចូលរួមកម្មវិធីវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យហើយខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ ព្រោះខ្ញុំរំពឹងទុកថានឹងទទួលបានចំណេះដឹងច្រើនទាក់ទងនឹងរបបខ្មែរក្រហម។ បន្ទាប់ពីការធ្វើបទបង្ហាញរបស់វាគ្មិនចប់ បានធ្វើឲ្យខ្ញុំយល់ដឹងបន្ថែមទៀតទៅលើចំណេះដឹង ដែលខ្ញុំធ្លាប់មានកន្លងមកតាមរយៈការសិក្សានៅសាលា។ ពីមុនមក ខ្ញុំធ្លាប់បានឮជីដូនជីតាខ្ញុំ និយាយប្រាប់ពីជីវិតដ៏លំបាកវេទនារបស់គាត់ ដែលបានជួបប្រទះនៅក្នុងអំឡុងសម័យខ្មែរក្រហម។ ខ្ញុំគិតថាវេទិការនេះមានសារសំខាន់ណាស់សម្រាប់ខ្ញុំ និងសិស្សានុសិស្សផ្សេងទៀត។ ក្នុងនាមខ្ញុំជាក្មេងជំនាន់ក្រោយ ខ្ញុំនឹងសិក្សាពីរបបប្រល័យពូជសាសន៍ប៉ុល ពត ដើម្បីការពារទប់ស្កាត់កុំឲ្យរបបនេះកើតឡើងម្តងទៀត។

២) សម្បត្តិ រក្សា ភេទស្រី អាយុ១៦ឆ្នាំ ជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យពារាំងបានលើកឡើងថា ខ្ញុំមានអារម្មណ៍រីករាយណាស់នៅពេលដែលបានរៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ។ បន្ទាប់ពីចូលរួមកម្មវិធីវេទិកាស្តីអំពីការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរួច ខ្ញុំបានទទួល ចំណេះដឹងទាក់ទងនឹងរបប ប៉ុល ពត បន្ថែមពីលើការសិក្សារបស់ខ្ញុំទៅលើមុខវិទ្យាប្រវត្តិសាស្ត្រនៅក្នុងសាលា។ តាមរយៈខ្លឹមសារនៃមេរៀន បានធ្វើឲ្យខ្ញុំយល់ដឹងពីជីវិតរស់នៅដ៏លំបាកវេទនារបស់ប្រជាជនកម្ពុជានៅក្នុងសម័យខ្មែរក្រហម ដែលកើតឡើងនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។

៣) អាត ស្រីនិច ភេទស្រី អាយុ ១៨ឆ្នាំ ជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យពារាំង បានលើកឡើងពីការយល់ឃើញរបស់ខ្លួនថា វេទិកាសិក្សាស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះមាន សារសំខាន់ណាស់ចំពោះរូបខ្ញុំ និងមិត្តភក្តិផ្សេងទៀត។ រឿងរ៉ាវនៃរបបខ្មែរក្រហមបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ហើយវាក៏ជាផ្នែកមួយដែលខ្ញុំ និងមិត្តភក្តិឯទៀតចង់ដឹងដែរ។ ខ្ញុំតែងតែឆ្ងល់ថា ហេតុអ្វីបានមានការកាប់សម្លាប់ ជនជាតិខ្មែរនាសម័យនោះ? ហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមប្រើឲ្យធ្វើការហួសកម្លាំង និងបង្អត់អាហារចំពោះប្រជាជនខ្មែរនៅទូទាំងប្រទេស? ទាំងនេះជាអ្វីដែលខ្ញុំចាំបាច់ត្រូវតែដឹងនិងរៀនសូត្របន្ថែម ដើម្បីជាការការពារទប់ស្កាត់កុំឲ្យមានការកាប់សម្លាប់កើតឡើងសារជាថ្មី។ ចុងក្រោយខ្ញុំសូមអរគុណក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបាន ចែកសៀវភៅប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យព្រមទាំងបង្រៀនពីរបបខ្មែរក្រហមដល់ខ្ញុំ។

**មិន សាណាស និង ផាត ចាន់សុនិតា**

# និស្សិតមកពីសាកលវិទ្យាល័យកាតូលិកអូស្ត្រាលី ទស្សនកិច្ចសិក្សានៅវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត

ការកើតឡើងនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា (ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) គឺជាគ្រោះមហន្តរាយមនុស្សជាតិដ៏សោកសង្រេងមួយ ដែលបានបន្តឲ្យប្រជាជនកម្ពុជាស្លាប់បាត់បង់ជីវិតប្រមាណជាង២លាននាក់។ ទោះបីអំពើប្រល័យពូជសាសន៍នេះបានរលត់ផុតទៅអស់រយៈកាល ៤០ឆ្នាំហើយក្តី ប៉ុន្តែការចងចាំនៅតែបន្តមាន និងជាប្រធានបទដ៏សំខាន់សម្រាប់អ្នកសិក្សាធ្វើការស្រាវជ្រាវ។

នៅព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ មាននិស្សិតអន្តរជាតិចំនួន១៥នាក់ ផ្នែកជំនាញការអភិវឌ្ឍន៍អន្តរជាតិ នៃសាកលវិទ្យាល័យកាតូលិកអូស្ត្រាលី (ACU) បានចាប់អារម្មណ៍ធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីស្វែងយល់អំពីប្រវត្តិនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ឬរបបខ្មែរក្រហម។ ក្នុងដំណើរទស្សនកិច្ចសិក្សានេះ និស្សិតទាំងអស់បានទស្សនាការតាំងពិព័រណ៍សិល្បៈនៅក្នុងវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ពិព័រណ៍ទាំងនេះ ត្រូវបានដាក់តាំងបង្ហាញទៅតាមប្រធានបទផ្សេងៗ រួមមាន ៖ ប្រសិនបើគ្មានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា «មិនផុតរលត់» និង«សំណល់សង្គ្រាម»។ ពិព័រណ៍សិល្បៈទាំងនេះបានបើកជាសាធារណសម្រាប់សាធារណជនដែលចង់ស្វែងយល់អំពីព្រឹត្តិការណ៍ ដែលធ្លាប់បានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ បន្ទាប់ពីទស្សនាការតាំងពិព័រណ៍សិល្បៈរួចមក និស្សិតទាំងនេះក៏បានទស្សនាខ្សែភាពយន្តឯកសារដែលមានចំណងជើងថា «កុំស្មានបងភ្លេច» ដែលជាផ្នែកមួយក្នុងការបំពេញបន្ថែមនូវចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជា។ ខ្សែភាពយន្តឯកសារនេះ គឺជាខ្សែភាពយន្តនិយាយអំពីតន្ត្រី



និស្សិតមកពីសាកលវិទ្យាល័យកាតូលិកអូស្ត្រាលី ជួបប្រជុំជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រ៉ក អេន រ៉ូល និងសិល្បៈក្នុងអំឡុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ ដែលខ្មែរបានបាត់បង់ក្នុងអំឡុងពេលប្រទេសកើតសង្គ្រាម។ តន្ត្រីមួយនេះបានចម្លងចេញពីបស្ចិមប្រទេសដោយរួមបញ្ចូលឫសគល់នៃតន្ត្រីដើមរបស់ខ្មែរ ហើយបង្កើតតន្ត្រីមួយបែបថ្មីខុសពីតន្ត្រីដទៃទៀត។ សិល្បៈករខ្មែរបានបង្កើតតន្ត្រីមួយបែបនេះ ចេញពីក្បួនខ្នាតដ៏សំខាន់នៃតន្ត្រីរ៉កផ្សេងៗរបស់ អាមេរិក អង់គ្លេស និងបារាំង ដោយដាក់បញ្ចូលសំឡេង និងចង្វាក់តន្ត្រីប្រពៃណីខ្មែរតែមួយគត់របស់ខ្លួន។ សំឡេងដ៏ពិរោះរបស់អ្នកចម្រៀងស្ត្រីដ៏ល្បីឈ្មោះ បានក្លាយជាចំណុចទាក់ទាញ ហើយធ្វើឲ្យតន្ត្រីច្នៃប្រឌិតមួយនេះទទួលបានការពេញនិយមយ៉ាងខ្លាំងពីសំណាក់សាធារណជន។ ប៉ុន្តែនៅពេលដែលសង្គមខ្មែរ ជាពិសេសតន្ត្រីវ័យក្មេងដែលទទួលយកវប្បធម៌បស្ចិមប្រទេស ហើយបានវិវឌ្ឍន៍ខ្លួនក្រោមឥទ្ធិពលនៃវប្បធម៌នេះ ប្រទេសកម្ពុជាបានធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាមយ៉ាងឆាប់រហ័ស។ «កុំស្មានបងភ្លេច» ខ្មែរបាត់បង់តន្ត្រីរ៉ក បានដឹកកកាយនូវធាតុផ្សំរបស់តន្ត្រីខ្មែរដែលបានប្រែក្លាយទៅជាតន្ត្រី រ៉ក អេន រ៉ូល ហើយបានរីកចម្រើនឆ្ពោះទៅមុខ ប៉ុន្តែស្ទើរត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងនៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ខ្សែភាពយន្តឯកសារនេះបានផ្ដល់គំហើញថ្មីស្ដីពីប្រទេសមួយដែលធ្លាប់តែពុះពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍។ ខ្សែភាពយន្តនេះ នឹងនាំទស្សនិកជនបានយល់ដឹងអំពីសិល្បៈតន្ត្រីពីអតីតកាល រហូតមកដល់បច្ចុប្បន្ន។ បន្ទាប់ពីទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» រួចមក មាននិស្សិតមួយចំនួនបានបញ្ចេញនូវចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដូចខាងក្រោម៖

កញ្ញា អ៊ែរ សិន គឺជានិស្សិតផ្នែកការអភិវឌ្ឍន៍អន្តរជាតិនៃសាកលវិទ្យាល័យកាតូលិកអូស្ត្រាលី (ACU) បានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេសចំពោះការអប់រំស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមរយៈការតាំងពិព័រណ៍សិល្បៈ ក្នុងការបញ្ជ្រាបការយល់ដឹង និងការពិភាក្សាផ្សេងៗ។

កញ្ញា លានី ហ៊ូ គឺជានិស្សិតផ្នែកការអភិវឌ្ឍន៍អន្តរជាតិនៃសកលវិទ្យាល័យកាតូលិកអូស្ត្រាលី (ACU) បានរៀបរាប់ថា «នាងខ្ញុំពិតជាទទួលបានចំណេះដឹងជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជា តាមរយៈការទស្សនាការតាំងពិព័រណ៍ និងទស្សនាខ្សែភាពយន្តឯកសារ នៅក្នុងវិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថិករីត។

ព្រាំ គិតម៉ាន់



និស្សិតមកពីសាកលវិទ្យាល័យកាតូលិកអូស្ត្រាលី ទស្សនាការដាក់តាំងពិព័រណ៍នៅ វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្វីករីត (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌល ឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រនៅវិទ្យាល័យគេដោសែនត្រពាំងតាវ ដែលជាអតីតចម្ការមីន

វិទ្យាល័យគេដោសែនត្រពាំងតាវដែលទើបបង្កើតឡើងនៅស្រុកអន្លង់វែង អតីតតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហមគឺជាវិទ្យាល័យទីមួយដែលត្រូវបានជ្រើសរើសសម្រាប់វេទិកាថ្នាក់ រៀនប្រវត្តិសាស្ត្រ។ អ្វីដែលគួរកត់សម្គាល់បំផុតនោះគឺការប្រែក្លាយទីតាំងសាលានេះ ដែលធ្លាប់ជា ចម្ការមីនដ៏គ្រោះថ្នាក់សម្រាប់ប្រជាជនមូលដ្ឋាន និងអ្នកចំណូលថ្មីឲ្យទៅជាកន្លែងអប់រំសម្រាប់យុវជន-យុវនារី។

នៅក្នុងខែឧសភា ឆ្នាំ២០១៩ វេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) របស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំធ្វើនៅវិទ្យាល័យគេដោសែនត្រពាំងតាវ។ វេទិកានេះបានចូលរួមចំណែកផ្តល់ចំណេះដឹងប្រវត្តិសាស្ត្រដល់សិស្សានុសិស្ស។ ក្រុមការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនឹងបន្តបើកវេទិកាថ្នាក់រៀន ប្រវត្តិសាស្ត្រ នៅតាមអនុវិទ្យាល័យ៥ផ្សេងទៀតក្នុងស្រុកអន្លង់វែង។

ដោយមានកិច្ចសហការដ៏ល្អជាមួយក្រសួង មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានរៀបចំវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រនៅវិទ្យាល័យគេដោសែន ត្រពាំងតាវ នេះ ដើម្បីជួបជាមួយសិស្សានុសិស្សចំនួន៦៦នាក់ ដែលក្នុងចំណោមសិស្សានុសិស្ស ទាំងនោះមានស្រី១៨នាក់។ វិទ្យាល័យនេះមានអគារកម្ពស់បីជាន់ដែលទើបសម្ពោធថ្មី និងមានទេសភាពពណ៌បៃតងស្រស់បំព្រងនៅព័ទ្ធជុំវិញ និងមានដើមធ្នង់ដុះត្រឈឹងត្រឈៃដែលផ្តល់ម្លប់សម្រាប់សិស្សានុសិស្សជ្រក។

ដោយមានស្រុកកំណើតនៅក្នុងខេត្តកំពង់ធំ លោក ហាក់ គឹមថុង បច្ចុប្បន្នជានាយកវិទ្យាល័យគេដោសែនត្រពាំងតាវ បានរៀបរាប់ថា នៅក្នុងឆ្នាំ២០០៤ ខ្ញុំបានធ្វើដំណើរមកកាន់ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្រោយពីបានបញ្ចប់កម្មសិក្សា ផ្នែកគរុកោសល្យ។ ដំបូង ខ្ញុំបានបម្រើការជាគ្រូបង្រៀននៅសាលាបឋមសិក្សាសន្តិភាព ស្ថិតនៅក្នុងឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ក្រោយមកខ្ញុំក៏បានផ្លាស់ពីសាលាបឋមសិក្សាសន្តិភាព មកនៅសាលាបឋម សិក្សាត្រពាំងតាវ ដែលជាអតីតចម្ការមីន។ ប៉ុន្តែមុននឹងសាងសង់សាលានេះ អង្គការ «ដេសាក់» ក៏បានធ្វើការរាវរកអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងធ្វើការបោសសម្អាតដែរ។ បន្ទាប់មកអង្គការនេះក៏បានសាងសង់សាលារៀនមួយខ្នងសម្រាប់សិស្សានុសិស្សរៀននៅក្នុងសហគមន៍នេះរៀនសូត្រ។

លុះមកដល់ឆ្នាំ២០០៨ ប្រធានកម្រងនៃការិយាល័យអប់រំ យុវជន និងកីឡាស្រុកអន្លង់វែង បានជ្រើសតាំងខ្ញុំជានាយកអនុវិទ្យាល័យត្រពាំងតាវ។ អំឡុងពេលនោះ ការខ្វះខាតអគារសិក្សានៅតែជាបញ្ហាសម្រាប់សិស្ស។ ដូច្នេះ ខ្ញុំក៏បានផ្តួចផ្តើមគំនិតបង្កើតសាលារៀនមួយខ្នងធ្វើអំពីឈើប្រក់ស្បូវ ដែលមានការជួយឧត្ថម្ភពីប្រជាជននៅក្នុងភូមិត្រពាំងតាវ ចំណែកគ្រឿងបរិក្ខា និងសម្ភារ សិក្សានៅក្នុងថ្នាក់រៀនយើងនៅខ្វះខាតដដែល ពិសេសគឺបណ្ណាល័យ និងសៀវភៅ។ ម្យ៉ាងទៀត ដោយសារផ្លូវធ្វើដំណើរពីភូមិមានចម្ងាយឆ្ងាយ និងស្ថានភាពគ្រួសាររបស់សិស្សជួបការលំបាក បានធ្វើឲ្យអត្រានៃបោះបង់ចោលការសិក្សារបស់សិស្សានុសិស្សកើនឡើងដែរ។ កាលពីបង្កើតសាលានេះដំបូងមានគ្រូបង្រៀន ២នាក់ និងសិស្សានុសិស្ស ចំនួន២៧នាក់ប៉ុណ្ណោះ។

ចាប់ពីឆ្នាំ២០១៦ ខ្ញុំត្រូវបានតែងតាំងក្នុងក្របខណ្ឌ

ក្រសួងអប់រំ យុវជន និងកីឡា ទៅនាយកនៃវិទ្យាល័យតេជោសែនត្រពាំងតាវ។ រហូតមកដល់ពេលបច្ចុប្បន្ន វិទ្យាល័យតេជោសែន ត្រពាំងតាវ មានអគារសិក្សាចំនួន៩បន្ទប់ សង់អំពីថ្ម ប្រក់ក្បឿង។

បើតាមស្ថិតិនៅដើមឆ្នាំ២០១៩ វិទ្យាល័យតេជោសែនត្រពាំងតាវមានសិស្សានុសិស្សសរុបចំនួន៣៩៦នាក់ និងគ្រូបង្រៀនចំនួន១៨នាក់។ តាមការសង្កេតក្រោយពេលសាលានេះដំឡើង ទៅជាវិទ្យាល័យតេជោសែនត្រពាំងតាវ ចំនួនសិស្សានុសិស្សដែលបោះបង់ការសិក្សាមានការថយចុះដែរ។ ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់អគារចំនួនមួយខ្នងបន្ថែមទៀត ដែលស្មើ នឹង២០បន្ទប់សម្រាប់គ្រូបង្រៀន និងសិស្សានុសិស្សដែលធ្វើដំណើរមកតំបន់ឆ្ងាយៗស្នាក់នៅ។

ខ្ញុំយល់ថា ការបង្កើតវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្ររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាគម្រោងដ៏ល្អសម្រាប់ការយល់ដឹង និងបំពេញបន្ថែមចំណេះដឹងរបស់សិស្សានុ-សិស្សអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។ តាមការសង្កេតមើលចំពោះសិស្សានុសិស្សវិទ្យាល័យតេជោសែន ត្រពាំងតាវ មានការចោទជាសំណួរបែបស៊ីជម្រៅ និងមានការពិភាក្សាលើមេរៀនប្រវត្តិសាស្ត្រដែលសិស្សទាំងនោះ បានចងចាំនៅក្នុងកម្មវិធីសិក្សារបស់រដ្ឋ។ សិស្សានុសិស្សនៅឃុំត្រពាំងតាវភាគច្រើន គឺជាកូនអតីតយោធាខ្មែរក្រហម ហើយមួយចំនួនទៀតជាកូនរបស់ប្រជាជនដែលចំណូលថ្មី។

ញឹម នន អាយុ៧០ឆ្នាំ អតីតសមាជិកម្នាក់នៃចលនាខ្មែរក្រហម បានយល់ស្របជាមួយ គឹមថុង ដោយបានលើកឡើងថា នៅពេលដែលខ្លួនមកដល់ទីនេះដំបូង ពុំទាន់មានសាលារៀនសម្រាប់សិស្សានុសិស្សទេ គឺមានតែរោងឈើមួយខ្នងប្រក់ស្បូវប៉ុណ្ណោះ។ សាលានេះ គឺហ៊ុមព័ទ្ធទៅដោយដើមឈើធំៗ ហើយពុំមានប្រជាជនរស់នៅទីនេះច្រើនទេ។ បើគិតមកទល់ពេលបច្ចុប្បន្នអគារសិក្សាបានកើនឡើងសម្រាប់សិស្សានុសិស្ស ហើយចៅរបស់ខ្ញុំផង ក៏កំពុងរៀននៅសាលារៀនត្រពាំងតាវនេះដែរ។

លោង គ្រឹះស្នា ភេទស្រី អាយុ១៦ឆ្នាំ ជាសិស្សវិទ្យាល័យតេជោសែនត្រពាំងតាវបានបង្ហាញពីចំណាប់អារម្មណ៍ថា៖ ខ្ញុំពិតជាមានសេចក្តីរីករាយយ៉ាងខ្លាំងសម្រាប់ការសិក្សាពីប្រវត្តិសាស្ត្រនៅថ្ងៃនេះ ដែលអាចឲ្យខ្ញុំដឹងកាន់តែច្រើនថាតើប្រវត្តិសាស្ត្ររបស់ជាតិ មានលក្ខណៈខុសគ្នាដូច ម្តេចខ្លះទៅនឹងការនិយាយតៗគ្នារបស់ប្រជាជន។ ខ្ញុំយល់ថា ប្រវត្តិសាស្ត្រនេះ ក៏អាចឲ្យយើងក្លាយជាមគ្គុទ្ទេសក៍មួយរូបយ៉ាងស្ទាត់ជំនាញប្រចាំសហគមន៍អន្លង់វែងបានដែរ។ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពិតជាមានទំនាក់ទំនងជាមួយសហគមន៍របស់ខ្ញុំ សាច់ញាតិ ក្រុមគ្រួសារ និងមនុស្សផ្សេងទៀតដែរ។

ស្រដៀងគ្នានេះ រិន យូឡុង ភេទប្រុស អាយុ១៦ឆ្នាំ បានរៀបរាប់ពីចំណាប់អារម្មណ៍ថា៖ ខ្ញុំសប្បាយរីករាយ ដែលបានរៀនសូត្រនៅវិទ្យាល័យតេជោសែនត្រពាំងតាវ ដែលមានអគារ ធំៗខ្ពស់ៗ។ ខ្ញុំយល់ឃើញថា ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ធ្វើឲ្យខ្ញុំយល់ដឹងពីជីវិតរបស់ប្រជាជនក្នុងរបបខ្មែរក្រហមបានកាន់តែច្រើន។ ការសិក្សាពីប្រវត្តិ សាស្ត្រនៃសង្គមជាតិរបស់ខ្លួនក្នុងភាពច្បាស់លាស់ ក៏ជាផ្នែកមួយដែលផ្សាភ្ជាប់ទៅនឹងគោលបំណង របស់ខ្ញុំដែលចង់បម្រើការជាមន្ត្រីនគរបាលនាពេលអនាគតដែរ។

វេទិកាថ្នាក់រៀន បានគូសបញ្ជាក់ពីសកម្មភាពសិស្សានុសិស្សដែលចូលរួម និងទទួលបាននូវការយល់ដឹងច្រើនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជាពិសេសការយល់ដឹងបញ្ហារំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នេះជាប្រវត្តិសាស្ត្រដ៏អន្ធការ ដែលយើង ត្រូវចៀសវាង។ ជាជំនួសវិញ ការអធ្យាស្រ័យ ការរួបរួមសាមគ្គី និងការផ្សះផ្សា មានភាពចាំបាច់ យ៉ាងខ្លាំងដើម្បីបុព្វហេតុសន្តិភាព។

ស្ងួត វិចិត្រ

# ជនជាតិជនខ្នងភ្នំនៅស្រុកវាលវែង

ជនជាតិជនខ្នងភ្នំបានប្រមូលផ្តុំគ្នា និងរស់នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ តាំងពីយូរលង់ណាស់មកហើយ។ ជនជាតិជនប្រកបមុខរបរដាំស្រូវ និងធ្វើចម្ការនៅក្នុងព្រៃ។ ជនជាតិជនប្រើភាសាខ្មែរ ដោយគ្រាន់តែមានសំនៀងខុសប្លែកគ្នាជាមួយជនជាតិខ្មែរបន្តិច។ កាលដើមឡើយមានការតំណាលតៗគ្នាមកថា ជនជាតិជនខ្នងភ្នំ គឺជាខ្មែរដើម។ នៅក្នុងសម័យអាណានិគមបារាំង ជនជាតិជនដែលមានវ័យចាប់ពី១៨ឆ្នាំឡើងទៅ ក៏ត្រូវបារាំងបង្ខំឲ្យបង់ពន្ធប្រចាំឆ្នាំដូចជនជាតិខ្មែរដែរ ដូច្នេះជនជាតិជនដែលមិនមានប្រាក់ក៏នាំគ្នារត់ចូលរស់នៅក្នុងព្រៃជ្រៅជាមួយសត្វខ្លាដំរីដើម្បីគេចខ្លួនពីបារាំង។ ជនជាតិជនដែលបានទៅរស់នៅក្នុងព្រៃដំបូងបានប្រមូលផ្តុំគ្នា និងរស់នៅជាក្រុមតូចៗដែលមានសមាជិកចាប់ពី២០ ទៅ៣០គ្រួសារ។ ក្រោយមកជនជាតិជនបានកើនឡើងរហូតដល់រាប់រយគ្រួសារ និងបានបង្កើតចេញជាភូមិផ្សេងៗនៅក្នុងស្រុកវាលវែងដែលជាតំបន់ភ្នំដាច់ស្រយាលពិបាកក្នុងការធ្វើដំណើរ និងមានចម្ងាយប្រមាណ១៥០គីឡូម៉ែត្រពីទីរួមខេត្តពោធិ៍សាត់។

ឡាង ទូញ អាយុ៦៨ឆ្នាំ មានប្តីឈ្មោះ សោម អាយុ៨៣ឆ្នាំ គឺជាជនជាតិជនខ្នងភ្នំ រស់នៅភូមិអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិសាត់ បានរៀបរាប់ថា កាលពីសម័យបារាំង ជនជាតិជនខ្នងភ្នំមានជីវភាពខ្វះខាត និងជួបការលំបាកយ៉ាងខ្លាំងក្នុងការប្រកបមុខរបររកស៊ី និងធ្វើដំណើរ។ ជនជាតិជនទាំងនោះត្រូវចំណាយពេលបួនទៅប្រាំថ្ងៃទើបទៅដល់ផ្សារនៅក្នុងទឹកដីថៃ ឬផ្សារនៅទីរួមខេត្តពោធិ៍សាត់ដើម្បីទិញរបស់របរប្រើប្រាស់ និងអាហារ។ ខ្ញុំមានមានកូន៧នាក់ ស្រី២នាក់ ប្រុស៥នាក់ ប៉ុន្តែកូនរបស់



រូបរាប់ពីខាងស្តាំ ៖ ឡាង ទូញ កំពុងផ្តល់បទសម្ភាសន៍ដល់លោក សុខ វណ្ណៈ បុគ្គលិកជម្រុមណ្ឌលផ្សះផ្សាវាលវែង
(រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំចំនួន៥នាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម និងក្រោយពេលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ ខ្ញុំមានឪពុកឈ្មោះ ស៊ុំ ម្តាយឈ្មោះ ម៉ុយ មានស្រុក កំណើតនៅភូមិត្រពាំងខ្នា ឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង។ ខ្ញុំបានរស់នៅជាមួយឪពុកម្តាយរបស់ខ្ញុំតាំងពីតូចរហូតដល់ធំពេញវ័យនៅក្នុងព្រៃ។ ឪពុករបស់ខ្ញុំបានប្រកបរបរធ្វើស្រែចម្ការចិញ្ចឹមសត្វ និងរស់នៅក្នុងព្រៃជាមួយជនជាតិជងជាច្រើនគ្រួសារទៀត។ នៅក្នុងភូមិរបស់ខ្ញុំមិនមានផ្លូវធំសម្រាប់ធ្វើដំណើរទេ គឺមានតែផ្លូវថ្មើរជើងតូចៗប៉ុណ្ណោះ។ នៅសម័យសង្គមរាស្ត្រនិយម ខ្ញុំបានចូលនៅសាលាបឋមសិក្សាក្នុងភូមិត្រពាំងខ្នា រហូតដល់ថ្នាក់ទី៨ (ចាស់)។ បន្ទាប់ពីឈប់រៀន ខ្ញុំបានជួយមើលប្អូនៗនៅផ្ទះ និងជួយឪពុកម្តាយកាប់ដីចម្ការដាំស្រូវសម្រាប់ហូបក្នុងគ្រួសារ។ ចំណែកជនជាតិជងប្រុសៗដែលមានវ័យចំណាស់ភាគច្រើនបានចូលព្រៃចៀរជ័រ រកខ្លឹមចន្ទ បោចវល្លិ៍ រកដើមក្រវាញ ឬផ្លែក្រវាញយកទៅលក់នៅប្រទេសថៃ ដើម្បីយកប្រាក់ទិញអំបិលប្រហុកយកមកហូប។ ជនជាតិជង បានប្រមូលភោគផលព្រៃឈើរយៈពេលពីរខែទៅបីខែទើបយកទៅលក់ម្តង។ មុននឹងចេញទៅលក់ភោគផលទាំងនោះ ជនជាតិជងត្រូវប្រមូលសមាជិកចាប់ពី ១០ គ្រួសារឡើងទៅ បន្ទាប់មកនាំគ្នាធ្វើដំណើរដោយថ្មើរជើង ឬជិះដំរីរហូតដល់ស្រុកថៃ។ ប៉ុន្តែខ្ញុំមិនដែលបានទៅជាមួយអ្នកទាំងនោះទេ។

កាលពីខ្ញុំនៅក្មេង ខ្ញុំធ្លាប់ឃើញជនជាតិបារាំងជិះសេះចូលមកក្នុងភូមិដែរ។ នៅពេលឃើញ ជនជាតិបារាំងទាំងនោះចាស់ៗ និងយុវជននៅក្នុងភូមិក៏នាំគ្នាគេចចូលទៅ នៅក្នុងព្រៃ ព្រោះខ្លាចបារាំងចាប់បង់ពន្ធ។ អ្នកទាំងនោះបានសម្ងំនៅក្នុងព្រៃ និងរង់ចាំរហូតដល់បារាំងចេញទៅវិញអស់ទើបនាំគ្នាចូលមកភូមិវិញ។

នៅឆ្នាំ១៩៦៦ ឪពុកម្តាយ និងចាស់ទុំនៅក្នុងភូមិបានរៀបចំទុកដាក់ឲ្យខ្ញុំមានប្តី ហើយកូនកម្លោះក៏មិនក៏មែនជាអ្នកភូមិឆ្ងាយដែរ គឺគាត់រស់នៅក្នុងព្រៃក្បែរខ្ញុំដែរ។ ពិធីរៀបការរបស់ខ្ញុំប្រព្រឹត្ត តាមទំនៀមទម្លាប់ប្រពៃណីខ្មែរ និងតាមព្រះពុទ្ធសាសនា។ កាលនោះប្តីរបស់ខ្ញុំមិនមានបណ្ណាការជូនខ្ញុំដូចសព្វថ្ងៃទេ គឺខាងប្តីរបស់ខ្ញុំមានតែជ្រូក មាន់ ទា សម្រាប់ធ្វើម្ហូបហូបជុំគ្នាប៉ុណ្ណោះ។ បន្ទាប់ពីរៀបការរួច យើងបាននាំគ្នាសង់ផ្ទះតូចរស់នៅបែកពីឪពុកម្តាយ និងប្រកបមុខរបរកាប់ដីចម្ការដាំដំណាំខ្លួនឯង។ កាលពីសម័យនោះ ដើមឈើមានទំហំធំៗដុះនៅក្នុងព្រៃ ប៉ុន្តែជនជាតិជងគ្មានសម្ភារ និងឧបករណ៍ដើម្បីកាប់ដើមឈើទាំងនោះយកមកសង់ផ្ទះទេ។ រីឯសត្វព្រៃវិញក៏សម្បូរដែរ ប៉ុន្តែជនជាតិជងបរបាញ់សម្រាប់តែចែកគ្នាហូបប៉ុណ្ណោះ គឺមិនបរបាញ់យកទៅលក់ដូរទេ។

នៅពេលមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ នៅឆ្នាំ១៩៧០ ជនជាតិជងបានរស់នៅ និងប្រកបរបរដាំដំណាំនៅក្នុងព្រៃធម្មតា។ បន្ទាប់មក ទើបមានកងកម្លាំងរំដោះខ្មែរក្រហម ចូលមកឃោសនានៅក្នុងភូមិ ហើយយន្តហោះទម្លាក់គ្រាប់បែកក៏មកទម្លាក់ដែរ ប៉ុន្តែសំណាងល្អយន្តហោះនោះទម្លាក់តែក្នុងព្រៃជ្រៅ និងភ្នំទើបមិនបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជនជាតិជង។ ខណៈនោះមានជនជាតិជងមួយចំនួនបានស្ម័គ្រចូលបម្រើយោធាខ្មែរក្រហម ហើយខ្លះទៀតបានចូលបម្រើកងទ័ព លន់ នល់។

នៅពេលយោធាខ្មែរក្រហមបានឡើងកាន់អំណាច នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រកាស ប្រាប់ប្រជាជនក្នុងភូមិប្រមូលទ្រព្យសម្បត្តិមកដាក់រួម ធ្វើការងាររួម និងហូបបាយរួមនៅតាមសហករណ៍។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាប្រធានសហករណ៍ ចំណែកប្តីរបស់ខ្ញុំធ្វើជា ប្រធានកងឈ្លប។ ការងាររបស់ខ្ញុំគឺដឹកនាំប្រជាជនក្នុងភូមិធ្វើការ និងដឹកនាំការប្រជុំ។ ជំនាន់នោះប្រជាជនត្រូវធ្វើការងារធ្ងន់ធ្ងរ និងមិនមានអាហារហូបគ្រប់គ្រាន់ឡើយ ទើបបណ្តាលឲ្យអ្នកខ្លះស្លាប់ និងកើតជំងឺហើម។ នៅក្នុងអំឡុងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ប្រជាជន ១៧ មេសា ត្រូវបាន យោធាខ្មែរក្រហមធ្វើបាប ចោទប្រកាន់ និងយកទៅសម្លាប់ចោលអស់ជាច្រើន។

នៅឆ្នាំ១៩៧៧ ដដែល អង្គការបានផ្លាស់ខ្ញុំពីប្រធាន

សហករណ៍ឲ្យទៅធ្វើការជាមួយប្តីរបស់ ខ្ញុំដែលត្រូវបានចាត់តាំងទៅជាសមាជិកស្រុកថ្មបាំង ខេត្តកោះកុង ក្នុងតំបន់៣៧ ភូមិភាគបស្ចិម ដែលមានឈ្មោះ ប៉ន គឺជាគណៈតំបន់ និងឈ្មោះ ចាន់ ស៊ី គឺជាគណៈភូមិភាគ។

នៅឆ្នាំ១៩៧៩ ខ្ញុំនិងប្តីបានរត់បែកពីកូន ឪពុកម្តាយ ចូលព្រៃជាមួយខ្មែរក្រហម។ ខ្ញុំជួបការ លំបាកវេទនាយ៉ាងខ្លាំងទំរាំទៅដល់ព្រំដែនថៃ នៅឆ្នាំ១៩៨០។ នៅឆ្នាំ១៩៨១ ខ្ញុំបានមករស់នៅស្រុកសំឡូត ខេត្តបាត់ដំបងវិញ។ ខ្ញុំមិនហ៊ានត្រឡប់មកភូមិកំណើតជួបកូននិងឪពុកម្តាយទេ ព្រោះខ្លាច កងទ័ពវៀតណាម។ ខ្ញុំនិងជនជាតិជងខ្នងភ្នំដ៏ទៃទៀតបានរស់នៅជាក្រុមចាប់ពី១០គ្រួសារទៅ២០ គ្រួសារ នៅក្នុងព្រៃ និងដាំស្រូវហូប។ ពេលនោះ យើងបានរស់នៅដាច់ដោយឡែកពីយោធាខ្មែរក្រហម ដែលនៅបន្តធ្វើសង្គ្រាមប្រឆាំងនឹងកងទ័ពវៀតណាម។ នៅឆ្នាំ១៩៨៩ នៅពេលទទួលដំណឹងថា កងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជា ខ្ញុំនិងបងប្អូនជនជាតិជងមួយចំនួនបានត្រឡប់មកភូមិកំណើតវិញ។ ប៉ុន្តែដោយសារដីនៅភូមិកំណើតមិនអំណោយផលការដាំដុះ និងរស់នៅ ទើបជនជាតិជងខ្លះសម្រេចចិត្តទៅរស់នៅភូមិផ្សេងវិញ ដូចជា ភូមិអូរសោម ភូមិកណ្តាល ភូមិគៀនជ្រុក និងភូមិឆាយលូក ជាដើម។

នៅឆ្នាំ១៩៩៣ អង្គការសហប្រជាជាតិបានរៀបចំឲ្យមានការបោះឆ្នោតដោយសេរីនៅទូទាំងប្រទេសកម្ពុជា ប៉ុន្តែជនជាតិជងនៅភូមិអូរសោម និងភូមិផ្សេងទៀតក្នុងស្រុកវាលវែងមិនបានចូលរួម ក្នុងការបោះឆ្នោតនោះទេ។ ជនជាតិជងនៅភូមិអូរសោមបានបន្តរស់នៅជាមួយក្រុមខ្មែរក្រហមផង និងខាងរដ្ឋាភិបាលផង រហូតដល់មានពាក្យមួយឃ្លាថា ដែលប្រជាជននៅអូរសោមនិយាយថា «ជើងម្ខាងនៅក្នុងទឹក ជើងម្ខាងនៅលើគោក» ដែលមានមានន័យថា ភាគីខាងណាក៏ដោយ ក៏ប្រជាជន អាចរស់នៅជាមួយបានដែរ។

នៅឆ្នាំ១៩៩៨ បន្ទាប់ពីយោធាខ្មែរក្រហមនៅទូទាំងប្រទេសបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ទើបប្រជាជននៅអូរសោមរស់នៅបានសេចក្តីសុខ និងមានជីវភាព ប្រសើរឡើង។ នៅឆ្នាំ២០០០ ខ្ញុំត្រូវបានប្រជាជនបោះឆ្នោតជ្រើសរើសឲ្យធ្វើជាមេឃុំអូរសោម។ មកដល់ឆ្នាំ២០១៧ ខ្ញុំបានលាលែងឈប់ធ្វើជាមេឃុំដោយសារខ្ញុំមានវ័យចំណាស់ និងមានការ លំបាកពេលជិះម៉ូតូទៅប្រជុំនៅសាលាស្រុកម្តងៗ ដែលមានចម្ងាយប្រហែលជា៦៥គីឡូម៉ែត្រពីផ្ទះ។ សព្វថ្ងៃ មានប្រជាជនចំណូលថ្មីជាច្រើនបានចូលមករស់នៅ ប្រកបរបររកស៊ី លក់ដូរនៅផ្សារនៅក្នុងឃុំអូរសោមនេះ។ ចំណែកខ្ញុំ និងក្រុមគ្រួសារបានប្រកបមុខរបរធ្វើស្រែ និងចម្ការដើម្បីចិញ្ចឹមជីវិត។

*សុខ វណ្ណៈ*



*ផ្ទះរបស់ជនជាតិជង ស្ថិតនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# បទពិសោធន៍របស់អ្នករស់រានជីវិត បានធ្វើឲ្យសិស្សានុសិស្ស និងយុវជនកាន់តែយល់ដឹងច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហម

ខេត្តបាត់ដំបង ស្ថិតនៅភាគពាយ័ព្យ នៃប្រទេសកម្ពុជា គឺជាទីកន្លែងចុងក្រោយ នៃការសម្តែងល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» នៅក្នុងឆ្នាំ២០១៩ បន្ទាប់ពីបានធ្វើការសម្តែងនៅតាមបណ្តាខេត្តផ្សេងរយៈពេល ១០ឆ្នាំកន្លងមក។ ល្ខោននិយាយ ទម្លាយភាពស្ងៀនស្ងាត់ រៀបរាប់ពីជីវិតពិតរបស់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហម ហើយក៏វេទិកាពិភាក្សាររវាងជនរងគ្រោះ និងជនដៃដល់ និងដំណើរការផ្សះផ្សានៅក្នុងប្រទេសកម្ពុជាដែរ។ ក្រៅពីការសម្តែងល្ខោននេះ ជារៀងរាល់ខែ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀន«ស្តីអំពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ» ដល់សិស្សានុសិស្សតាមបណ្តាវិទ្យាល័យនានាប្រមាណជាជាង៣០០កន្លែង នៅខេត្តក្រុងនៃប្រទេសកម្ពុជា។ ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅហើយក្តី យ៉ាងហោចណាស់នៅមានប្រជាជនកម្ពុជា ដែលនៅរស់រានមានជីវិតប្រមាណជា៥លាននាក់ រៀបរាប់ប្រាប់កូនចៅរបស់គាត់ អំពីបទពិសោធន៍ដែលបានឆ្លងកាត់របបខ្មែរក្រហម។ ហេតុការណ៍រន្ធត់នៅក្នុងរបបខ្មែរក្រហម ប្រៀបដូចជាសុបិន្តអាក្រក់ និងបានជះឥទ្ធិពលដល់អ្នករស់រានមានជីវិតក្រោយពីរបបខ្មែរក្រហម។ ប្រជាជនកម្ពុជាដែលមានអាយុចាប់ពី៥០ឆ្នាំឡើងទៅភាគច្រើនកើតនូវជំងឺបាក់ស្បាតដែលបណ្តាលមកពីភាពរន្ធត់ ភ័យខ្លាច ទារុណកម្ម ការបង្ខិតបង្ខំដែលបានជួបប្រទះក្នុងរបបខ្មែរក្រហម។ ជំងឺបាក់ស្បាតនេះ បានបន្តដល់កូនចៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងមនុស្សជំនាន់ក្រោយៗ។ ទោះបីជំងឺបាក់ស្បាតជះឥទ្ធិពលអវិជ្ជមាន និងដែលកើតឡើងចំពោះជនរងគ្រោះរយៈពេលប្រមាណ៤០ឆ្នាំកន្លងមកហើយ ក៏ជំងឺនេះក៏មាន



គរុសិស្សកំពុងរង់ចាំទស្សនាការសម្តែងល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់»
(រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភាពវិជ្ជមានសម្រាប់កូនចៅជំនាន់ក្រោយ ក្នុងការត្រិះរិះពិចារណាថា មូលហេតុបានជាជំងឺនេះកើតឡើងចំពោះឪពុកម្តាយរបស់ខ្លួននិងត្រូវដោះស្រាយជាមួយជំងឺនេះយ៉ាងណាៗ យើងសង្កេតឃើញថា ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» លើកដំបូងកាលពីឆ្នាំ២០០៨ មានភាពខុសគ្នាជាមួយពេលបច្ចុប្បន្ន គឺលើកដំបូងអ្នកដែលចូលរួមទស្សនាល្ខោននេះភាគច្រើនគឺជនរងគ្រោះ និងឆ្លងកាត់របបខ្មែរក្រហមៗ បន្ទាប់ពីទស្សនាការសម្តែងល្ខោននេះរួចមក អ្នកទាំងនោះតែងងើបឈរ ដើម្បីចែករំលែកភាពឈឺចាប់សោកសង្រេងរបស់ខ្លួនទៅកាន់អ្នកចូលរួមៗ ១០ឆ្នាំក្រោយមក អ្នកមកទស្សនាល្ខោននិយាយនេះ ភាគច្រើនគឺជាយុវជនសិស្សនិងនិស្សិតៗ ផ្ទុយពីការរៀបរាប់រឿងរ៉ាវសោកសង្រេងនិងវន្ទត់ សិស្សានុសិស្ស និងយុវជនទាំងនេះបានខិតខំស្វែងយល់ និងលើកជាសំណួរទាក់ទងនឹងរឿងរ៉ាវជាច្រើនបានកើតឡើងចំពោះប្រជាជនកម្ពុជា និងសាច់ញាតិរបស់ខ្លួនៗ សិស្សានុសិស្ស និងយុវជនទាំងនេះ បានជជែកវែកញែកឡើងវិញពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមៗ មានយុវជនខ្លះ បានយកភាពលំបាករបស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់របបខ្មែរក្រហមធ្វើជាគំរូក្នុងការប្រឈមជាមួយឧបសគ្គដែលខ្លួនបានប្រឈមៗ

ម៉ៃ ណែត អាយុ២២ឆ្នាំ គឺជាគរុសិស្ស ដែលមានស្រុកកំណើតនៅក្នុង ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបងថា យាយរបស់គាត់ដែលមានអាយុ៧៨ឆ្នាំ តែងតែនិយាយអប់រំគាត់និងចៅៗផ្សេងទៀតឲ្យចេះសន្សំសំចៃ នៅពេលមានហូបចុកគ្រប់គ្រាន់និងរស់នៅស្រួល ខុសពីសម័យខ្មែរក្រហមដែលប្រជាជនជួនការលំបាកៗ បន្ទាប់ពីស្តាប់ការរៀបរាប់របស់យាយរួចមក ណែត បានយល់ថា រឿងរ៉ាវយាយរបស់គាត់ដែលរស់នៅលំបាក ដូចទៅនឹងរឿងរ៉ាវរបស់ប្រជាជនកម្ពុជាដែលបានរស់រានមានជីវិតផ្សេងទៀតៗ

គរុសិស្សឈ្មោះ ស៊ីប ឌីណា មានអាយុ២០ឆ្នាំ មានស្រុកកំណើតឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបងបានរៀបរាប់ថា តា និងលោកយាយក៏បានឆ្លងកាត់របបខ្មែរក្រហមដែរៗ ប៉ុន្តែ តានិងយាយរបស់គាត់ធ្លាប់បាននិយាយតិចតួចអំពីបទពិសោធន៍រស់នៅក្នុងរបបខ្មែរក្រហម ព្រោះគាត់គិតថា របបខ្មែរក្រហមមានតែការចងចាំដែលមិនល្អ ហើយក៏មិនចង់ឲ្យចៅរបស់គាត់គិតពីអតីតកាលដែរៗ ទោះបីយ៉ាងណានៅពេលណាដែលគាត់អប់រំចៅៗ គាត់តែងតែលើកអំពីបទពិសោធន៍លំបាក ដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមប្រាប់ទៅចៅៗៗ ខ្ញុំនៅចាំការរៀបរាប់របស់តាប្រាប់ខ្ញុំថា កាលនោះ ប្រហែលជានៅឆ្នាំ១៩៧៣ មានការទម្លាក់គ្រាប់បែកយ៉ាងច្រើនៗ ពេលនោះយាយបានពរឪពុករបស់ខ្ញុំ ដែលមានអាយុបាន២ឆ្នាំ ចំណែកតាដឹកដៃកូនបងនិងកាន់របស់របរប្រើប្រាស់ដើរកាត់ជ្រលងភ្នំៗ ពេលដែលខ្ញុំគិតទៅដល់អំពីភាពលំបាករបស់យាយតា ធ្វើឲ្យខ្ញុំមានអារម្មណ៍អាណិតគាត់និងមានកំហុសដែលមិនអាចជួយគាត់បានៗ តាមរយៈបទពិសោធន៍របស់យាយតា បានធ្វើឲ្យខ្ញុំគោរពគាត់យ៉ាងខ្លាំងៗ រឿងរ៉ាវរបស់យាយតាខ្ញុំ គឺមេរៀនដើម្បីប្រឈមជាមួយបញ្ហាដែលខ្ញុំត្រូវដោះស្រាយៗ

រ៉ុក សីលា មានអាយុ២០ឆ្នាំ មានស្រុកកំណើតនៅ ឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប បានរៀបរាប់ថា នៅពេលទំនេរពីការងារឪពុកម្តាយ ខ្ញុំតែងនិយាយអំពីបទពិសោធន៍នៅក្នុងរបបខ្មែរក្រហមប្រាប់ខ្ញុំៗ ក្រោយពីបានស្តាប់ឪពុកម្តាយនិយាយប្រាប់ និងបានយល់ពីភាពឈឺចាប់របស់គាត់ ក៏បានធ្វើឲ្យខ្ញុំខិតខំរៀនសូត្រដែរៗ

នៅពេលដែលយុវជន និងក្មេងៗជំនាន់ក្រោយបានសិក្សាស្វែងយល់ពីភាពឈឺចាប់ទុក្ខវេទនា បទពិសោធ៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមរយៈការរៀបរាប់របស់ក្រុមគ្រួសារ ការទស្សនាល្ខោននិយាយ ទម្លាយភាពស្ងៀមស្ងាត់ និងវេទិកាថ្នាក់រៀន «ស្តីអំពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ» ធ្វើឲ្យយុវជនទាំងនេះកាន់តែរឹងមាំថែមទៀតៗ

**ដារ៉ារដ្ឋ មេត្តា**

# ការចងចាំពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមតាមរយៈការទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»

*ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» បានសម្តែងនៅតាមបណ្តាខេត្តជាច្រើន ដូចជា ខេត្តត្បូងឃ្មុំ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ចាម ខេត្តព្រៃវែង និងក្រុងភ្នំពេញនៃប្រទេសកម្ពុជា។ កន្លងផុតទៅថ្មីៗនេះ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ត្រូវបានដាក់សម្តែងជាលើកចុងក្រោយសម្រាប់ឆ្នាំ២០១៩ នៅក្នុងបរិវេណវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង ដោយមានការចូលរួមពីសំណាក់លោកគ្រូអ្នកគ្រូ គរុសិស្ស និងប្រជាជនចំនួនប្រមាណជាង ៤០០នាក់ដែលរស់នៅក្នុងទីរួមខេត្តបាត់ដំបង។ ខ្លឹមសារនៃសាច់រឿងល្ខោន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំពីអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា បង្កើតឲ្យមានការពិភាក្សា និងចងចាំពីរបបខ្មែរក្រហម។ ការសម្តែងល្ខោននិយាយនេះក៏មានគោលបំណងដើម្បីជំរុញឲ្យមានការផ្សះផ្សារបួសផ្លូវចិត្តរវាងជនដៃដល់ និងជនរងគ្រោះដែលនៅរស់រានមានជីវិត។ បន្ទាប់ពីបានទស្សនាល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» អ្នកចូលរួមបានរៀបរាប់ពីចំណាប់អារម្មណ៍ និងរឿងរ៉ាវផ្ទាល់ខ្លួនដែលបានកើតឡើងដូចខាងក្រោម៖*

*១) ប្លែក ភី ភេទស្រី អាយុ៦៨ឆ្នាំ មានទីលំនៅបច្ចុប្បន្ន រស់នៅភូមិស្វាយជ្រុំ ឃុំព្រែកច្រម៉ិញ ស្រុកឯកភ្នំ ខេត្តបាត់ដំបង បានរៀបរាប់ទាំងទឹកភ្នែកថា៖ នៅពេលទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ក្នុងបរិវេណវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបងនេះ បានធ្វើឲ្យខ្ញុំចងចាំទៅដល់ការឈឺចាប់ដែលបានកើតឡើងក្នុងពេលអតីតកាល ហើយការឈឺចាប់នេះនៅតែបន្សល់ទុកហូតមកដល់ពេលសព្វថ្ងៃ ព្រោះខ្ញុំបានបាត់បង់ឪពុកម្តាយ បងប្អូន និងសាច់ញាតិជាច្រើន។ ម្តាយរបស់ខ្ញុំឈ្មោះ ហេង ឆា ចំណែកឯឪពុករបស់ខ្ញុំមានឈ្មោះ ឡុច ពោ។ នៅក្នុងរបបខ្មែរក្រហមគ្រួសារខ្ញុំមានសមាជិក៧នាក់ បានរស់នៅក្នុងខ្ទមជាមួយគ្នា ប៉ុន្តែត្រូវចេញទៅធ្វើការងារនៅសហករណ៍ផ្សេងៗដើម្បីទទួលបានរបបអាហារសម្រាប់ហូប។ ឪពុកម្តាយរបស់ខ្ញុំខិតខំធ្វើការងារខ្លាំងណាស់ ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់។ ឪពុករបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅកន្លែងផលិតដែកគោល។ កន្លែងធ្វើ*



ប្លែក ភី (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការរបស់ខ្ញុំមានស្ថានភាពលំបាកទាំងការងារ និងការហូបចុក។ អ្នកធ្វើការងារជាមួយឪពុករបស់ខ្ញុំតែងតែបបួលឪពុករបស់ខ្ញុំរត់ចូលទៅក្នុងទឹកដីថៃប៉ុន្តែឪពុករបស់ខ្ញុំបានបដិសេធ ព្រោះឪពុករបស់ខ្ញុំព្រួយបារម្ភខ្លាចពេលដែលគាត់រត់ចេញទៅ ខ្មែរក្រហមនឹងធ្វើបាបប្រពន្ធកូន។ ឪពុករបស់ខ្ញុំសុខចិត្តស្លាប់នៅក្នុងភូមិបើសិនអង្គការយកគាត់ទៅសម្លាប់ ដើម្បីឲ្យប្រពន្ធកូនបានដឹង។ ចំណែកខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការងារនៅសហករណ៍ដាំដំឡូងនៅតំបន់៤ ក្នុងភូមិភាគពាយ័ព្យ ដែលជាតំបន់មួយមានការគ្រប់គ្រងតឹងរ៉ឹង។ ខ្ញុំពុំមានអាហារហូបចុកគ្រប់គ្រាន់ឡើយ។ ក្នុងមួយថ្ងៃខ្ញុំទទួលបានបបរតែពីរពេលប៉ុណ្ណោះ ដោយបបរក្នុងមួយខ្ទះធំមានអង្ករ២កំប៉ុងប៉ុណ្ណោះ សម្រាប់ប្រជាជនមួយសហករណ៍។

នាពេលព្រលប់ថ្ងៃមួយ នៅចុងឆ្នាំ១៩៧៨ ក្រុមគ្រួសារខ្ញុំបានមកជុំគ្នានៅក្នុងខ្ទមបន្ទាប់ពីធ្វើការងារ ដោយឪពុករបស់ខ្ញុំនៅក្រោមផ្ទះ ចំណែកឯម្ដាយ និងប្អូនៗរបស់ខ្ញុំនៅលើផ្ទះ។ ពេលនោះខ្ញុំឃើញពន្លឺភ្លើងមួយកំពុងតម្រង់មករកខ្ទមរបស់ខ្ញុំ។ ម្ដាយឪពុករបស់ខ្ញុំបាននិយាយថា ពិតជាមានហេតុការអាក្រក់កើតឡើងមិនខាន ឮដូច្នេះខ្ញុំក៏បានប្រាប់ប្អូនៗឲ្យនាំគ្នាចូលដេកមុន។ មិនខុសពីអ្វីដែលឪពុកម្ដាយរបស់ខ្ញុំបានគិតនោះទេ កងឈ្លបម្នាក់បានមកហៅឪពុកខ្ញុំដោយនិយាយថា អង្គការថ្នាក់លើត្រូវការហៅទៅសួរនាំមួយភ្លែត។ ខ្ញុំយំនៅពេលដែលឮកងឈ្លបនិយាយបែបនេះ ព្រោះខ្ញុំដឹងថាឈ្លបមកនាំឪពុកខ្ញុំទៅសម្លាប់ហើយ។ កងឈ្លបនោះបានស្រែកសម្លុតខ្ញុំថា «មិត្តឯងចង់ស្លាប់ណាស់មែនទេ បានជាយំ»។


អាត សុខអេង គឺជាគរុសិស្សឯកទេសប្រវត្តិវិទ្យានៃវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង
(រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


យន ស៊ីវខេង គឺជាគរុសិស្សឯកទេសគីមីវិទ្យានៃវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង
(រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្ដាយរបស់ខ្ញុំនៅអង្គុយស្ងៀមនឹងថ្កល់មួយកន្លែងបាត់មាត់ឈឹង ប្រៀបដូចជាមនុស្សគ្មានវិញ្ញាណ។ ខ្ញុំក៏បានឡើងទៅលើផ្ទះយកសម្លៀកបំពាក់មកផ្លាស់ជូនឪពុករបស់ខ្ញុំ។ មុនពេលកងឈ្លបនាំឪពុកខ្ញុំចេញទៅ គាត់បាននិយាយពាក្យផ្ដែផ្ដាំមកកាន់ខ្ញុំឲ្យជួយមើលថែប្អូនៗ។ ប្អូនពៅរបស់ខ្ញុំពេលនោះទើបមានអាយុប្រហែល៩ឆ្នាំប៉ុណ្ណោះ។ ពេលឪពុកខ្ញុំចេញផុតទៅបានមួយសន្ទុះ ម្ដាយមីងរបស់ខ្ញុំបានមកដល់ខ្ទមរបស់ខ្ញុំ ហើយប្រាប់ម្ដាយខ្ញុំថា ប្ដីរបស់បងត្រូវបានកងឈ្លបនាំយកទៅហើយ។ ម្ដាយរបស់ខ្ញុំនិងមីងបានយំឱបគ្នាទាំងឈឺចាប់នៅកណ្ដាលយប់នោះ។ ក្រោយពីឪពុករបស់ខ្ញុំស្លាប់ទៅ ខ្មែរក្រហម បានជម្លៀសគ្រួសារខ្ញុំឲ្យទៅធ្វើការងារនៅស្រុកថ្មគោល។ គ្រួសារខ្ញុំធ្វើការនៅទីនោះបានប្រហែលជា១០ថ្ងៃ ទើបកងទ័ពវៀតណាមវាយបានវាយចូលមក។ គ្រួសារខ្ញុំក៏បានត្រឡប់មកស្រុកកំណើតនៅឃុំព្រែកម្រិញ ស្រុកឯកភ្នំ ខេត្តបាត់ដំបងវិញ។ ចាប់តាំងពីពេលឈ្លបខ្មែរក្រហមនាំយកឪពុកខ្ញុំទៅសម្លាប់ ម្ដាយរបស់ខ្ញុំពិបាកចិត្តរហូតដល់គាត់ធ្លាក់ខ្លួនឈឺធ្ងន់ៗ អាការៈជំងឺរបស់ម្ដាយខ្ញុំកាន់តែមានស្ថានភាពធ្ងន់ធ្ងរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ក្រោយមកម្ដាយរបស់ខ្ញុំក៏បានស្លាប់ទៀត ដោយបន្សល់ទុកខ្ញុំ និងប្អូនៗរបស់ខ្ញុំបួននាក់ទៀតរស់នៅជាក្មេងកំព្រា។ ខ្ញុំនៅចាំយ៉ាងច្បាស់ពីអ្នកដែលបានមកនាំឪពុកខ្ញុំទៅសម្លាប់ឈ្មោះ ឡេវ ដែលបានរស់នៅក្បែរភូមិរបស់ខ្ញុំបន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ។ ខ្ញុំមិនដែលមានគំនិតចង់សងសឹកជាមួយឈ្មោះ ឡេវ ទេ គឺឲ្យគាត់ទទួលផលកម្មពីអ្វីដែលគាត់បានប្រព្រឹត្ត។ រហូតមកដល់ពេលបច្ចុប្បន្នខ្ញុំនៅតែចងចាំពីរឿងរ៉ាវខ្លោចផ្សានៅក្នុងរបបខ្មែរក្រហម ហើយខ្ញុំតែងនិយាយពីរបបនេះប្រាប់ក្មេងៗជំនាន់ក្រោយឲ្យបានដឹង។

២) ឃន ស៊ីវខេង ភេទស្រី អាយុ១៧ឆ្នាំ ជាគរុសិស្សឯកទេសគីមីវិទ្យានៃវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបងបានលើកឡើងថា៖ បន្ទាប់ពីបានទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»រួចមក បានធ្វើឲ្យខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការសម្ដែងជាពិសេសឈុតទី៦ ដែលនិយាយពីក្មេងស្រីម្នាក់មិននិយាយស្ដីសោះ ដោយសារតែយោធាខ្មែរក្រហមរំលោភ និងធ្វើបាបដែលបណ្ដាលឲ្យប៉ះពាល់ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។ ក្មេងស្រីម្នាក់នោះមិនបាននិយាយរឿងក្នុងចិត្តប្រាប់អ្នកណាទេ បានត្រឹមតែរក្សាការចងចាំដ៏អាក្រក់ទុកនៅក្នុងចិត្តម្នាក់ឯង។ ពីមុនមកខ្ញុំធ្លាប់បានឮយាយរបស់ខ្ញុំរៀបរាប់ប្រាប់ពីរឿងរ៉ាវសម័យខ្មែរក្រហម ការកាប់សម្លាប់ ការបង្អត់អាហារ និងការប្រើឲ្យធ្វើការហួសកម្លាំងជាដើម។ តាមរយៈការទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» និងការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំគិតថា យុវជនជំនាន់ក្រោយគួរចងចាំពីការឈឺចាប់ និងទុក្ខលំបាក ដែលបានកើតឡើងចំពោះប្រជាជនខ្មែរ ដើម្បីបញ្ចៀសកុំឲ្យរឿងរ៉ាវបែបនេះកើតឡើងនៅលើទឹកដីកម្ពុជាម្ដងទៀត។

៣) អាត សុខអេង ភេទប្រុស អាយុ២៣ឆ្នាំ ជាគរុសិស្សឆ្នាំទី១ ឯកទេសប្រវត្តិវិទ្យានៃវិទ្យាស្ថានគរុកោសល្យបាត់ខេត្តដំបងបានលើកឡើងថា៖ បន្ទាប់ពីខ្ញុំបានទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» រួចបានធ្វើឲ្យខ្ញុំស្រមៃទៅដល់ទុក្ខលំបាករបស់ប្រជាជនកម្ពុជា ដែលបានឆ្លងកាត់នូវរបបឃោរឃៅ។ ល្ខោននេះបានផ្ដល់ចំណេះដឹងដល់ខ្ញុំបន្ថែមទៀតពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលខ្ញុំធ្លាប់បានរៀននៅក្នុងសាលា។ សុខ អេង បានបន្តថា មុនពេលមើលការសម្ដែងល្ខោននិយាយនេះ ខ្ញុំក៏បានចូលរួមចូលរួមកម្មវិធីទិវាជាតិនៃការចងចាំដែលបានប្រារព្ធឡើង កាលពីថ្ងៃទី២០ ខែឧសភាឆ្នាំ២០១៩ នៅក្នុងទីរួមខេត្តបាត់ដំបង។ នៅក្នុងកម្មវិធីនេះ មានការចូលរួមជាច្រើនពីសំណាក់ប្រជាជនសិស្សានុសិស្ស លោកគ្រូអ្នកគ្រូ និងព្រះសង្ឃ ដោយមានការប្រារព្ធពិធីសូត្រមន្តប្រគេនចង្ហាន់ព្រះសង្ឃ ដើម្បីឧទ្ទិសកុសលផលបុណ្យជូនដល់ជនរងគ្រោះ ដែលបានបាត់បង់ជីវិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។

***ដាត ចាន់សុនិតា***

# «ឆ្នាំព្រៃ» ជួយជំរុញទឹកចិត្តប្រជាពលរដ្ឋក្នុងខេត្តឧត្តរមានជ័យឲ្យស្រឡាញ់ព្រៃឈើ

ព្រះតេជគុណ ប៊ុត សាលួត គឺជាសកម្មជនការការពារព្រៃឈើដ៏សកម្មមួយព្រះអង្គ ក្នុងចំណោមព្រះសង្ឃ៧០,៨៥៣អង្គ ក្នុងប្រទេសកម្ពុជា។ ព្រះអង្គបានរៀបចំបង្កើតព្រៃសហគមន៍មួយក្នុងខេត្តឧត្តរមានជ័យដែលមានឈ្មោះថា «ព្រៃសហគមន៍សង្ឃរុក្ខវ័ន» នៅក្នុងឆ្នាំ២០០០ ដើម្បីថែរក្សា និងការពារព្រៃឈើ និងសត្វព្រៃដែលនៅសេសសល់។ ព្រៃនេះមានទំហំសរុប ៣០,២៥៦ ហិចតា លាតសន្ធឹងក្នុងស្រុកចំនួនបី រួមមាន ស្រុកសំរោង ស្រុកចុងកាល់ និងស្រុកអន្លង់វែង នៃខេត្តឧត្តរមានជ័យ ដែលកាលពីមុនព្រៃដ៏ក្រាស់នេះគឺជាកន្លែងលាក់ខ្លួនរបស់ចលនាខ្មែរក្រហម និងមានគ្រាប់មីនបង្កប់ជាច្រើន។ រហូតដល់ឆ្នាំ២០០២ ទើបព្រះអង្គប៊ុនសាលួតបានទទួលច្បាប់អនុញ្ញាតជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជាឲ្យថែរក្សា និងការពារ«ព្រៃសហគមន៍សង្ឃរុក្ខវ័ន» ដែលប្រជាជនក្នុងតំបន់នេះភាគច្រើនហៅថា «ព្រៃលោក»។ ព្រៃនេះមិនត្រឹមតែផ្តល់អនុផលព្រៃឈើ និងជីវចម្រុះដ៏សម្បូរបែបដល់ប្រជាជនក្នុងសហគមន៍ប៉ុណ្ណោះទេ គឺថែមទាំងផ្តល់នូវទីកន្លែងដែលទាក់ទាញជាមួយសម្រស់ធម្មជាតិសម្រាប់អ្នកដែលចូលមកទស្សនា។

តាមរយៈគំនិតផ្តួចផ្តើម និងការខិតខំប្រឹងប្រែងរបស់ព្រះអង្គក្នុងការដឹកនាំការងារអភិរក្សព្រៃឈើ និងសត្វព្រៃ



សហការីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ជិះគោយន្តទស្សនាព្រៃសហគមន៍សង្ឃរុក្ខវ័ន នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩ (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បានធ្វើឲ្យប្រជាជនខ្មែរ និងជនបរទេសកាន់តែច្រើនស្គាល់«ព្រៃសហគមន៍សង្ឃរុក្ខវ័ន»។ នាពេលថ្មីៗនេះ ខ្សែភាពយន្តឯកសាររឿង«ឆ្នាំព្រៃ»ដែលនិយាយអំពីតួនាទីនិងសកម្មភាពរបស់ព្រះតេជគុណ ប៊ុន សាលូត ទាក់ទងនឹងព្រៃឈើ ក៏ត្រូវបានផលិតឡើង។ នៅក្នុងកម្មវិធីសម្ពោធការបញ្ចាំងខ្សែភាពយន្តឯកសាររឿង«ឆ្នាំព្រៃ»នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ កន្លងទៅ ឯកឧត្តម ហួន វ៉ាន់និត អភិបាលរងខេត្តឧត្តរមានជ័យ បានមានប្រសាសន៍ថា «ព្រៃសហគមន៍សង្ឃរុក្ខវ័ន គឺជាព្រៃដែលនៅសេសសល់ចុងក្រោយគេបង្អស់ នៅក្នុងចំណោមព្រៃសហគមន៍ចំនួន១៣ ស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ»។

ហ៊ិន សឹយ ភេទស្រី អាយុ៥៩ឆ្នាំ មានស្រុកកំណើត នៅសង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ បង្ហាញនូវអារម្មណ៍សប្បាយរីករាយនៅពេលឃើញក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើរផ្សព្វផ្សាយការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង«ឆ្នាំព្រៃ»។ សឹយ បានមានប្រសាសន៍ថា ខ្ញុំធ្លាប់បានទៅដកផ្សិត និងនេសាទត្រីនៅក្នុង«ព្រៃលោក» ដែលព្រះសង្ឃអនុញ្ញាតិសម្រាប់យកមកហូបនៅក្នុងគ្រួសារ។ នៅពេលដែលខ្ញុំចូលទៅបង់សំណាញ់នៅក្នុងព្រៃនេះ ខ្ញុំបានឃើញដើមឈើធំៗ ដូចជា ដើមគគីរ ដើមធ្នង់ ដើមស្រឡៅ និងដើមឈើជាច្រើន។ ដើមឈើធំៗទាំងនេះបានទាក់ទាញចិត្តខ្ញុំយ៉ាងខ្លាំង។ ខ្ញុំចង់ឲ្យមានការថែរក្សាដើមឈើនៅក្នុងព្រៃសហគមន៍នេះ។ ប្រសិនបើមិនមានព្រៃឈើ ប្រាកដជាធ្វើឲ្យអាកាសធាតុកាន់តែក្តៅឡើង ហើយយើងក៏ពុំអាចរស់បានដែរ។ ខ្ញុំចង់ឲ្យប្រជាជនក្នុងភូមិចេះសាមគ្គីគ្នា និងចូលរួមទប់ស្កាត់រាល់បទល្មើសដែលបានកើតឡើងនៅក្នុងព្រៃសហគមន៍។

ស្ងួន សុចន្ទី ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១១ នៃវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ មានស្រុកកំណើតនៅសង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ បានរៀបរាប់ថា ខ្ញុំបានដឹងព័ត៌មាន ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ«ឆ្នាំព្រៃ» តាមរយៈព្រះតេជគុណដែលបង្រៀនម៉ោងវប្បធម៌ទូទៅ និងម៉ោងព្រះពុទ្ធសាសនានៅសាលារៀន។ នេះគឺជាលើកទីមួយរបស់ខ្ញុំដែលបានទស្សនាខ្សែភាពយន្តឯកសារនេះ។ ខ្ញុំមានអារម្មណ៍សប្បាយរីករាយ ហើយពេញចិត្តចំពោះសកម្មភាពរបស់ព្រះអង្គប៊ុន សាលូត។ ខ្ញុំធ្លាប់បានទៅទស្សនា«ព្រៃលោក» ចំនួនពីរលើករួចមកហើយ និងបានឃើញព្រះសង្ឃនៅការពារព្រៃឈើនោះ។ នៅពេលដែលខ្ញុំបានចូលទៅក្នុងព្រៃម្តងៗ ខ្ញុំបានឃើញដើមឈើធំៗ។ ខ្ញុំចង់ឃើញដើមឈើធំ ទាំងនោះនៅឋិតថេរ។ ខ្ញុំមិនចង់ឲ្យមានអ្នកកាប់ដើមឈើទាំងនេះទេ។ ខ្ញុំក៏បានឃើញសត្វស្វា និងឃើញសត្វផ្សេងៗទៀតដែលធ្វើឲ្យខ្ញុំសប្បាយរីករាយយ៉ាងខ្លាំង។ នៅពេលរដូវភ្លៀង ខ្ញុំឃើញប្រជាពលរដ្ឋ បានចូលទៅរកផ្សិតនៅទីនោះមានដូចជា ផ្សិតក្មោក និងផ្សិតប៉ក់។ ខ្ញុំបានរៀនពីសារសំខាន់នៃព្រៃឈើនៅក្នុងថ្នាក់ ហើយខ្ញុំក៏ចង់ចែករំលែកជាមួយពូមីង និងអ៊ំ ដែលចូលទៅរកអនុផលព្រៃឈើឲ្យបានយល់ពីសារសំខាន់នៃព្រៃឈើដែរ ដើម្បីការពារការកាប់បំផ្លាញព្រៃឈើទៅថ្ងៃខាងមុខ។ នៅពេលឃើញមានការចាក់បញ្ចាំងខ្សែភាពយន្តឯកសារនេះ ធ្វើខ្ញុំចង់ទៅសិក្សា និងទស្សនកិច្ច«ព្រៃលោក» ម្តងទៀត។ ខ្ញុំសំណូមពរឲ្យប្រជាពលរដ្ឋជួយលើកទឹកចិត្ត ជួយផ្តល់សម្ភារ និងថវិកា ដល់សកម្មជនដែលបានចូលរួមការពារព្រៃឈើក្នុងសហគមន៍នេះ។ «ព្រៃលោក» នឹងក្លាយជាព្រៃគំរូដល់តំបន់ផ្សេងទៀតក្នុងប្រទេសកម្ពុជា។

សម័យ លីហ្សា ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ មានស្រុកកំណើតនៅសង្កាត់សំរោង ក្រុងសំរោង បានឲ្យដឹងថា នៅពេលបានទស្សនាខ្សែភាពយន្តឯកសារនេះ ធ្វើខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំង។ ខ្ញុំចង់ឲ្យប្រជាពលរដ្ឋទៅទស្សនា «ព្រៃលោក» កាន់តែច្រើន។ ចំណែកប្រជាពលរដ្ឋដែលមិនអាចទៅទស្សនាព្រៃសហគមន៍សង្ឃរុក្ខវ័នដោយផ្ទាល់ ក៏គួរចូលរួមទស្សនាខ្សែភាពយន្តឯកសារនេះដែរ។ ខ្ញុំធ្លាប់បានទៅទស្សនាព្រៃលោកដោយផ្ទាល់ ប៉ុន្តែខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ»

បានធ្វើឲ្យខ្ញុំដែលជាអ្នកទស្សនាកាន់តែរំភើបរីករាយនៅពេលបានឃើញសត្វព្រៃៗ វាខុសពីពេលដែលខ្ញុំទៅទស្សនាព្រៃផ្ទាល់ ព្រោះពេលដែលខ្ញុំទៅព្រៃសហគមន៍នៅពេលថ្ងៃ ហើយពេលល្ងាចត្រឡប់មកវិញ ដូច្នេះខ្ញុំមិនបានឃើញសត្វព្រៃទាំងនេះទេ»។ ចំណែកនៅក្នុងខ្សែភាពយន្តឯកសារនេះ ផលិតករបានរង់ចាំថតសត្វព្រៃនៅពេលយប់។ ខ្ញុំគិតថា «ព្រៃលោក» គឺជាទីកន្លែងដែលទាក់ទាញខ្លាំងណាស់។ ខ្សែភាពយន្តឯកសារនេះ បានជំរុញឲ្យខ្ញុំចាប់អារម្មណ៍កាន់តែខ្លាំងចំពោះព្រៃឈើនៅក្នុងខេត្តរបស់ខ្ញុំ។

ស៊ី សុវណ្ណារី អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ ដែលមានស្រុកកំណើតសង្កាត់សំរោង ក្រុងសំរោង បានបញ្ជាក់ថា ខ្ញុំចង់ឲ្យតំបន់ផ្សេងទៀតមានដើមឈើច្រើនដូចព្រៃសហគមន៍នេះ ដូច្នេះទាមទារឲ្យមានការជួយការពារ និងចូលរួមដាំដើមឈើឡើងវិញ។ ខ្ញុំគិតថាខ្សែភាពយន្តនេះល្អខ្លាំងណាស់ ដែលមានព្រះមេគណខេត្ត ប៊ុត សាលួត រៀបរាប់ពីប្រវត្តិព្រៃឈើ និងការបង្កើតជាព្រៃសហគមន៍នេះ។ នៅពេលព្រៃឈើសហគមន៍នៅគង់វង្ស យើងក៏អាចស្គាល់រុក្ខជាតិ និងសត្វរាប់ចាប់ពីប្រភេទតូចៗ រហូតដល់សត្វធំៗដែលរស់នៅក្នុងព្រៃនេះដែរ។ ខ្សែភាពយន្តឯកសារនេះ បង្ហាញទាំងសកម្មភាពបទល្មើសការកាប់បំផ្លាញព្រៃឈើ និងការដាក់អន្ទាក់សត្វព្រៃ។ ខ្សែភាពយន្តនេះ បានជួយអប់រំប្រជាជន និងធ្វើឲ្យពលរដ្ឋរស់នៅខេត្តឧត្តរមានជ័យស្រឡាញ់ព្រៃឈើ ហើយក៏បានជួយជំរុញទឹកចិត្តខ្ញុំឲ្យជួយថែរក្សាព្រៃឈើ និងដាំដើមឈើដែរ។

***ដារ៉ារដ្ឋ មេត្តា***




ព្រះសង្ឃនៅក្នុងខេត្តឧត្តរមានជ័យ និមន្តទស្សនាការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» នៅសួនច្បារវិមានឯករាជ្យ ក្រុងសំរោង នៅថ្ងៃទី២១ ខែមិថុនា (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរន្ធត់ពីម្ដាយខ្ញុំ

ខ្ញុំឈ្មោះ ភួន សុគន្ធ អាយុ៣២ឆ្នាំ បច្ចុប្បន្នគឺជាមន្ត្រីនគរបាល រស់នៅក្នុងភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ក្រោយពីខ្ញុំបាទបានទស្សនាការសម្ដែងល្ខោននិយាយដែលមានចំណងជើង «ទម្លាយភាពស្ងៀមស្ងាត់» កាលពីយប់ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៩ នៅក្នុងបរិវេណសាលាគរុកោសល្យភូមិភាគព្រៃវែង ដែលសម្ដែងដោយក្រុមអម្រឹតាសិល្បៈ សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជារួចមក បានធ្វើឲ្យខ្ញុំនឹកឃើញ និងមានសេចក្ដីរន្ធត់ចិត្តយ៉ាងខ្លាំង ព្រោះសាច់រឿងទាំងនេះ ម្ដាយរបស់ខ្ញុំដែលបានឆ្លងកាត់របបខ្មែរក្រហមតែងនិយាយប្រាប់ខ្ញុំ។ ហេតុការណ៍នៅក្នុងរបបខ្មែរក្រហមដែលខ្ញុំបានស្ដាប់ឮទាំងនោះបានដក់នៅក្នុងចិត្តរបស់ខ្ញុំ ដែលខ្ញុំបានសរសេររៀបរាប់រាប់តាមរយៈការចងចាំនៅក្នុងកំណាព្យដូចខាងក្រោម៖

### គុកឥតជញ្ជាំងកម្ពុជា ១៩៧៥-១៩៧៩

| | | |
|---|---|---|
| ១) | សម័យចិតប្រាំចាំជានិច្ច | ប្រទេសលង់លិចខ្ទេចខ្ទាំខ្ទាំ |
| | របបអាវខ្មៅដៅប្រហារ | ទមិឡឥតសាសនាមហាពិឃាត។ |
| ២) | ភ្នំផ្លឹងស៊ឹងឈាមសមុទ្រទឹក | ខ្មែររស់ក្នុងគុកចោលម្សៀត |
| | ធ្វើទុក្ខបុកម្នេញពេញចង្អៀត | ខ្លះស្លាប់ចោលញាតិធាតុក្នុងព្រៃ។ |
| ៣) | ដេញចេញពីផ្ទះដូចតិរច្ឆាន | នៅទីស្មសាន ឋានប្រល័យ |
| | គ្មានថ្នាំសង្កូវ ម្ហូបចំណី | ដាច់ពោះឈឺក្ស័យ ដូចសត្វធាតុ។ |



ភួន សុគន្ធ



សាធារណជនកំពុងទស្សនាល្ខោននិយាយ រឿង «ទម្លាយភាពស្ងៀមស្ងាត់» នៅក្នុងបរិវេណសាលាគរុកោសល្យភូមិភាគព្រៃវែង (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

៤) បង្ខំធ្វើការគ្មានពេលឈប់ ព្រលឹមព្រលប់យប់អាធាត្រ
ម្ហូបគ្មានត្រីសាច់ ប្រាច់ត្រកៀត សាបគ្មានរសជាតិដូចទឹកស្ទឹង។
៥) គេចងស្លាបសេក ដេកថ្ងូកឈាម បនក្បត់គម្រាមផ្តាច់ព្រលឹង
កូនព្រាត់ឪពុក ទុក្ខស្លក់ស្ទឹង ម្តាយបាត់ដំណឹង ឈឹងសូន្យសោះ។
៦) សម័យអាវខ្មៅខ្មៅមោហា ឃោរឃៅឫស្យាអារកស្រស់
គ្មានក្តីមេត្តាថាខ្មែរសោះ មហាលោភផ្ដោះផស់អគ្គការ។
៧) ដៃកាន់ដងចប ខ្ទបខ្លោចចិត្ត ស្រមៃអតីតពិតសោកា
ធ្លាក់ក្នុងភក់ជ្រាំទ្រាំក្ដៅផ្សា សម័យអគ្គកាអស្ចារ្យណាស់។
៨) របបរងកម្មចាំដាប់ពិត មិនគួរជីវិតដូចក្រដាស
វាចោទថាខ្មាំងប្រឆាំងផ្ដាស ដកចេញរហ័សច្បាស់ប្រល័យ។
៩) កាលនោះរងគ្រោះរស់ភ័យភិត ព្យុះកម្មជីវិតពិតស្ទើរក្ស័យ
ធ្វើការនឿយហត់អត់តម្លៃ ភ័យខ្លាចរាល់ថ្ងៃក្រៃរន្ធត់។
១០) សាហាវខ្មៅកន្ទួងបន ពត ពាលាយង់ឃ្នងចងសម្លុត
អស់ជាងបីលាន គ្មានលាក់ពុត ប្រុងផ្ដាច់ឲ្យផុត ជាតិសាសន៍ខ្មែរ។

(ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ដោយ ៖ ភួង សុគន្ធ)

## សមុទ្រទឹកភ្នែក (បទពាក្យ៧)

១) រស់នៅដូចសត្វព្រាត់គ្រួសារ បនពតឫស្យាអន្តិរិយ
សម្លាប់សាសន៍ឯងឥតក្រែងអ្វី របបអប្រិយផ្សៃមោហា។
២) នាមជនភៀសខ្លួនពួនរួចរស់ ខ្មែរស្លាប់រង្គោះព្រោះនរណា?
គរឆ្អឹងដូចភ្នំយំខ្លោចផ្សា ឈាមដាបជលសាកម្ពុជា។
៣) ហែលសមុទ្រឈាមស្ទឹងទឹកភ្នែក យូរពន់សែងវែកបែកបុត្រភ្ញា
រស់គេចភ្នែកខ្មៅដៅពាធា ឆ្លងកាត់សង្សារកទ្រនំ។
៤) ស្បែកដណ្ដប់ឆ្អឹងប្រឹងតស៊ូ ប្រែល្វឹងចត់ដូរកាត់វាលភ្នំ
សំឡេងខ្វងខែកជ្រែកទុក្ខធំ ស្ដាប់កូនតូចយំរកឪពុក។
៥) ជាតិស្ត្រីមេម៉ាយឆ្ងាយគ្រួសារ លំបាកក្រៃណាផ្សាក្ដៅលុក
គ្រងកូនបីនាក់ធ្លាក់បន្ទុក គ្មានឡើយក្ដីសុខរងទុក្ខា។
៦) បបរវាលវែកចែកគ្នាហុត ប្រាណភ័យញ័រស្លុតតក្កមា
បែរបន់សំពះអស់ទេព្តា រុករក្សអ្នកគាថាឲ្យជួយ។
៧) រស្មីជីវិតងងឹតសូន្យ ព្រាត់ប្រាស់បងប្អូនកូនភ័យព្រួយ

សង្ឃឹមស្អែកដល់ស្គាល់ជំនួយ កងទ័ពខ្មែរជួយប្រោសជីវីៗ
៨) នេះហើយរបបបនអង្គការ ប្រតិកិរិយាទុក្ខញាំញី
សម្លាប់រង្គោស់ពាសធរណី ធ្វើបាបវក់វីគ្មានល្ហើយល្ហែៗ
៩) កងឈ្លបកិបកាញ់បាញ់សម្លុត ចង់ផ្តាច់ឲ្យផុតពូជសាសន៍ខ្មែរ
ទមិឡឥតកំណើតឆ្អួតតាមខ្មែរ មិនដែលមានទេលើលោកិយៗ
១០) កោតណាស់តែហ៊ានពោលបំពាន គ្មានពាក្យក្រ មាន គ្មានសេរី
សមូហភាពប្រៀបពេញដី អ្នកចំណូលថ្មីចោទគ្នាខ្មាំងៗ
១១) ផ្ទះប៉ិតផ្ទះក្បឿងក្បឿងថ្មឈើ ក្លាយជាទ្រនើខ្ទមស្បូវភ្លាំង
កុដិវត្តវិហារជាទីតាំង រោងដីចូកចាំងផ្ទះជំនុំៗ
១២) ឆ្លងវាលពិឃាតឃ្លាតឆ្ងាយស្រុក ពេញដោយទុក្ខក្តុកគុកដ៏ធំ
ប្រាថ្នាជីវិតពិតជួបជុំ កងឈ្លបគួនគុំប៉ងយាយីៗ
១៣) គុណវីរជនធនស្និទ្ធស្នេហ៍ រំដោះជាតិខ្មែរពីធូលី
នាំសន្តិភាពប្រៀបពេញទី ខេមរាសាមគ្គីពួតហត្ថាៗ
១៤) ២ធ្នូជាជ័យនៃជាតិយើង រណសិរ្សផ្ចើងឡើងប្តេជ្ញា
កម្ចាត់ពូជខ្មាំងច្បាំងហានក្លា ទោះក្ស័យមរណាក៏ហ៊ានប្តូរៗ
១៥) ជ័យោ ជ័យោចិតប្រាំបី! ខេមរាខ្មីឃ្មាតឆ្លៀតតស៊ូ
លុបស្នឹងឈាមខ្មែរដែលស្រក់ហូរ រួចរស់ថ្ងៃថ្នូរទូរដ្ឋាៗ
១៦) ៧ មករា មហាជោគ ទេវតាយាងមកប្រោសសន្ធា
របបក្អែកខ្មៅត្រូវមរណា វិនាសអសន្តរធានៗ
១៧) សម្តេចទាំងបីមានគុណណាស់ រំដោះជាតិផ្លាស់ជាធរមាន
ទប់ស្កាត់សង្គ្រាមលែងឲ្យមាន អភិវឌ្ឍន៍ឈានសាងកិត្យាៗ
១៨) ចម្រើនឧត្តមធំប្រាកដ មានថ្នល់ស្ពានវត្ត កុដិ សាលា
មានសន្តិភាពប្រៀបរដ្ឋា ជោគជ័យផ្លែផ្កាចារនឹ្មៗ

(ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៩ ដោយ ៖ ភួង សុគន្ធ)

## ព្រាត់គ្នាក្នុងគ្រាកលិយុគ (បទពាក្យ៧)

១) ខ្ញុំភួង សុគន្ធ វន្ទារ៉ាយរ៉ាប់ ពាក្យម៉ែឪប្រាប់ធ្លាប់ឆ្លងកាត់
របបអាវខ្មៅដៅបរមត្ថ ប្រើមនុស្សដូចសត្វឥតប្រណីៗ
២) ម៉ែព្រាត់ពីឪទៅសហករណ៍ ហូបតែបបរគល់ចេកខ្ចី

ព្រលិតត្រកួនដួនត្រាវថ្មី អំបិលទាំងល្អីស្ដីឆ្ងាញ់ណាស់ៗ
៣) ឪស្រោចបន្លែថែទំនប់ ស្ដារព្រែកទាំងយប់ ទប់ប្រវាស់
បែកញើសស្រក់ឈាមបៀមបន់ព្រះ ខោអាវគ្មានផ្លាស់ចាស់គ្មានថ្មីៗ
៤) ឪថាអង្គការមហាផ្ដោះ ត្រូវលះឲ្យអស់ប្រពន្ធប្ដី
បបរវាល់វែកដេកផ្ទាល់ដី អ្នកចំណូលថ្មីស្ដីថាខ្លាំងៗ
៥) អង្គការភ្នែកម្នាស់ឈ្មោះរុងរឿង រុះផ្ទះថ្មក្បឿងសង់ខ្ទមភ្លាំង
វត្តវិហារ កុដិកំណត់តាំង ទុកគ្រាន់ឃុំឃាំងខ្លាំងចក្រពត្តិៗ
៦) ទឹកភ្នែកម៉ែស្រក់ដល់ដោគដី នឹកកូនប្រុសស្រីដែលប្រាសព្រាត់
គុកឥតជញ្ជាំងរនាំងបត់ កូនរស់កំសត់អត់មេបាៗ
៧) យប់ឈ្លបលបស្ដាប់ចាប់សួរនាំ ស្លាបសេកបន្ទំផ្សំទោសា
រណ្ដៅជីកស្រាប់ចាប់ប្រហារ បោទក្បត់អង្គការចារតាមដានៗ
៨) របបភ្អែកខ្មៅដៅចិត្តម៉ែ ដាំងសែសិបខែកែឥតស្រាន្ត
លាបពណ៌បន្លំចតិរច្ឆាន ពាលាសាមាន្យខានសុខាៗ
៩) ប្រជារងទុក្ខគុកឥតស្រាក វេទនាលំបាកយ៉ាកអាត្មា
គ្រាន់តែសុំរស់ជួបគ្រួសារ ត្រូវស្មើអង្គការថ្នាក់លើសិនៗ
១០) នេះហើយសម័យដ៏ភ្លឺស្វាង ដឹកព្រែកស្ដារអាងទាំងសង្កិន
គ្មានបុណ្យចូលឆ្នាំ ឬភ្ជុំបិណ្ឌ ព្រះសង្ឃក៏មិនស្គាល់សាសនាៗ
១១) គ្មានសិទ្ធិសេរីរើសគូគាប់ ត្រូវចូលធ្វើទ័ពវាយប្រហារ
ចិត្តដាច់ស្នោះត្រង់ស៊ូប្ដេជ្ញា គ្មានក្ដីមេត្តាត្រាសណ្ដោសៗ
១២) ក្មេងប្រើឃ្វាលគោរកជីខ្លះ បំណែកមនុស្សចាស់ប្រើពុះខស
មើលក្មេងក្រែងឈឺភ្លឺត្រូវខុស វេញខ្សែកន្ទុះចុះដកស្ទូងៗ
១៣) បាយរួមមិនឆ្អែតហេតុខ្ជិល ភូតមួលបង្ខិលរុកគួនលួង
ជីវិតគ្មានន័យផ្ដៃគ្រហួង បេះដូងក្រៅទ្រូងរងទុក្ខាៗ
១៤) រស់កំដស្លាប់ប្រាប់ឲ្យដឹង សម័យគ្រាហ្នឹងប្រឹងធ្វើការ
អ្នកបញ្ជាវន្តធ្ងន់ទោសារ កម្មេចសង្ខារដូចសត្វធាតុៗ
១៥) ថ្ងៃទីប្រាំពីរ ខែមករា យុទ្ធជនខេមរាស៊ូខ្មីឃ្មាត
គុណកងទ័ពខ្មែរស្នេហាជាតិ របបពិឃាតខ្ចាត់អន្តរាយៗ
១៦) គុណវីរជនធ្ងន់ឧត្ដម គុណថ្នាក់ដឹកនាំធំវែងឆ្ងាយ
ជួយខ្មែរឲ្យយសរស់សប្បាយ ខ្មែរផុតឃ្លានបាយសាយសុខសាន្តៗ

*(ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៩ ដោយ ៖ ភួង សុគន្ធ)*

# ជីវិតក្នុងព្រៃរបស់អតីតយោធាខ្មែរក្រហម

ខ្ញុំឈ្មោះ រំ ភឿន។ ចាប់តាំងពីខ្ញុំធំដឹងក្តីមក ខ្ញុំបានរស់នៅជាមួយស្រែចម្ការ និងក្នុងព្រៃជាជម្រករហូត។ ឪពុករបស់ខ្ញុំគឺជាអតីតយោធាខ្មែរក្រហម។ នៅពេលដែលឪពុកខ្ញុំហាត់ក្បួនយុទ្ធសាស្ត្រយោធា និងឡើងវាយជាមួយខ្មាំងនៅលើសមរភូមិខ្ញុំតែងតែទៅជាប់ជាមួយគាត់។ ចំណែកម្តាយរបស់ខ្ញុំក៏នៅក្នុងព្រៃជាមួយឪពុកខ្ញុំដែរ។ ដោយសារខ្ញុំរស់នៅក្នុងព្រៃអស់រយៈពេលយូរ រហូតដល់ពេលខ្លះខ្ញុំគិតថាព្រៃឈើគឺជាផ្ទះរបស់ខ្ញុំពិតប្រាកដ។ នៅក្នុងព្រៃខ្មែរក្រហមបានសាងសង់រោងសម្រាប់កុមាររៀនសូត្រ។ ខ្ញុំក៏បានចូលរៀនសូត្រជាមួយកូនៗរបស់អតីតកម្មាភិបាលខ្មែរក្រហមផ្សេងទៀតដែរ។ ខ្ញុំនិងក្មេងទាំងៗទាំងនោះរៀនអានអក្សរ ក, ខ, រៀនប្រកប និងរៀននយោបាយបន្ថែមទៀត។ ខ្ញុំនៅចាំពាក្យមួយឃ្លាដែលខ្ញុំរៀនកាលជំនាន់នោះថា «ប្រសិនបើយើងមិនខិតខំប្រឹងប្រែងតស៊ូទេ យួននឹងយកទឹកដីអស់មិនខាន»។ ទាំងនេះគឺជាពាក្យសំដីរបស់ខ្មែរក្រហម ហើយក៏ជាប្រវត្តិសាស្ត្ររបស់ខ្មែរដែរ។ ខ្ញុំរៀនមិនឆ្លាតទេនៅក្នុងថ្នាក់ ហើយក៏មិនសូវចេះអានអក្សរដែរ។ ប៉ុន្តែខ្ញុំរៀនឆាប់ចេះពីរបៀបរស់នៅ និងយករុក្ខជាតិដែលដុះនៅក្នុងព្រៃមកធ្វើជាអាហារ និងប្រើប្រាស់ប្រចាំថ្ងៃតាមរយៈឪពុករបស់ខ្ញុំ។ នៅពេលខ្ញុំចង់ផ្ញូតទឹកឬចង់កក់សក់ ខ្ញុំបានបេះស្លឹកទ្រមូងមកឈ្លីរហូតដល់ទក់ និង



រំ ភឿន កំពុងសំឡឹងមើលវល្លិ៍អន្ទញនៅដើមឈើ នៅក្នុងព្រៃសហគមន៍សង្ឃរុក្ខវ័ន ក្នុងខេត្តឧត្តរមានជ័យ
(រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចេញពពុះ រួចយកមកកក់សក់ជំនួសសាប៊ូ។ ទ្រមូងមានរសជាតិជូរអាចលាងជម្រះសក់ និងក្អែលដែលជាប់នៅនឹងខ្លួនបាន។ ដើមទ្រមូងធំ មានកម្ពស់រហូតដល់៣០ម៉ែត្រ ហើយស្លឹករបស់វាយើងអាចយកមកស្ងោរ និងផ្សាប់ជាអន្លក់។ ពេលណាដែលខ្ញុំបោកខោអាវខ្ញុំបានកាប់សំបកវល្លិ៍អង្គុញ ឬវល្លិ៍ស្គន់មកត្រដុសលើខោអាវ រហូតមានពពុះដែលអាចឲ្យខ្ញុំបោកខោអាវបានជ្រះ។

ពេលដែលខ្ញុំនៅក្នុងព្រៃ ហើយមិនមានទឹកផឹក ខ្ញុំបានកាប់ដើមវល្លិ៍ឆ្វេងសម្រកយកទឹកដែលហូរចេញពីវល្លិ៍ឆ្វេងមកផឹក។ ទឹកហូរចេញពីវល្លិ៍ឆ្វេងហាក់រមាស់កបន្តិច ប៉ុន្តែក៏អាចជួយឲ្យខ្ញុំបាត់ការស្រេកទឹកបានមួយគ្រាដែរ។ ខ្ញុំស្គាល់វល្លិ៍ឆ្វេងបានដោយសាររុក្ខជាតិនេះ ដុះព័ទ្ធដើមឈើផ្សេងៗពីខាងឆ្វេងដៃនិងវណ្ឌរហូតដល់ចុងឈើ។ ការរស់នៅក្នុងព្រៃមិនមានអង្ករហូបគ្រប់គ្រាន់ទេ ដូច្នេះខ្ញុំតែងតែដើរជីកក្ដួច និងដំឡូងព្រៃមកហូបជំនួសបាយ។ នៅពេលខ្ញុំរកក្ដួចបាន ខ្ញុំមិនអាចយកវាមកហូបភ្លាមៗបានទេ។ ខ្ញុំយកក្ដួចមកចិតជាចំណិតស្ដើងៗ រួចហើយយកវាទៅច្រកចូលបាវ បន្ទាប់យកវាទៅត្រាំក្នុងទឹកស្ទឹងប្រមាណជា២ទៅ៣យប់ទើបអាចយកវាមក ចម្អិនហូបបាន។ មើមក្ដួចមានសារធាតុម្យ៉ាងធ្វើឲ្យអ្នកហូបអាចពុលស្លាប់បាន ប្រសិនបើយើងមិនយកវាទៅត្រាំទឹក។ កាលពីមុននៅក្នុងព្រៃ មានសត្វខ្លាច្រើនណាស់ ហើយប្រសិនបើអ្នកភូមិចង់សម្លាប់សត្វខ្លាដោយសារខ្លាចចូលយកយាយីខ្លួន គឺអ្នកភូមិបានយកមើមក្ដួចមកលាយជាមួយសត្វដែលខ្លួនបរបាញ់ដាក់ឲ្យសត្វខ្លាស៊ី។ បន្ទាប់ពីសត្វខ្លាបានស៊ីសត្វដែលលាយជាមួយមើមក្ដួចនោះរួចមកសារធាតុពុលអាចធ្វើឲ្យសត្វខ្លាងាប់ភ្លាមៗ។

កាលពីមុនឆ្នាំ១៩៧៥ តំបន់អន្លង់វែងដែលខ្ញុំរស់នៅមានព្រៃឈើយ៉ាងក្រាស់។ ប្រជាជននៅតំបន់នេះភាគច្រើនបានគាំទ្រចលនាតស៊ូខ្មែរក្រហម និងបានយកព្រៃស្អាក (ឬមន្ទីរកងកេង) ធ្វើជាកន្លែងឃោសនា និងជ្រើសរើសប្រជាជននៅស្រុកអន្លង់វែងចូលរួមជាមួយបដិវត្តន៍។ ទាំងប្រជាជននិងខ្មែរក្រហមភាគច្រើននៅពេលនោះ ក៏បានរស់នៅដោយអាស្រ័យពីព្រៃឈើ។ ក្រោយពេលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ គ្រួសារខ្ញុំ និងប្រជាជនដែលតស៊ូផ្សេងទៀតបានជម្លៀសទៅរស់នៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប។ នៅទីនោះខ្ញុំបានចូលកងចល័តកុមារទី២ ដែលមានតួនាទីដើរចល័តនៅក្នុងឃុំ។ ខ្ញុំដើរកាប់ដើមទន្រ្ទានខែត្រធ្វើជីសម្រាប់ដាក់ស្រែ និងដំណាំ។ នៅអំឡុងឆ្នាំ១៩៧៧-១៩៧៨ ខ្ញុំត្រូវបានផ្លាស់មកកងធ្វើជីនៅតំបន់៤។ កងធ្វើជីមានសមាជិកប្រមាណ២០ទៅ៣០នាក់។ នៅដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយផ្ដួលរំលំរបបខ្មែរក្រហម ខ្ញុំនិងគ្រួសារបានរត់មកលាក់ខ្លួននៅក្នុងព្រៃស្អាក។ នៅឆ្នាំ១៩៨០ ឪពុកម្ដាយរបស់ខ្ញុំក៏បាននាំខ្ញុំឡើងលើភ្នំដងរែកជាមួយកងពលដែលដឹកនាំដោយ តាផន ហើយខ្ញុំក៏បានចូលធ្វើយោធាខ្មែរក្រហមនៅពេលនោះ។ នៅឆ្នាំ១៩៨៨ ខ្ញុំបានរៀបការប្រពន្ធដែលជាអ្នកស្រុកអន្លង់វែងជាមួយគ្នា។

ក្រោយសង្រ្គាមបានបញ្ចប់នៅឆ្នាំ១៩៩៩ តំបន់ដែលជាសមរភូមិប្រយុទ្ធគ្នារវាងកងទ័ពរដ្ឋាភិបាល និងយោធាខ្មែរក្រហមនៅអន្លង់វែងបានបន្សល់នៅអាវុធយុទ្ធភណ្ឌ និងគ្រាប់មិនទាន់ផ្ទុះជាច្រើន។ ជាញឹកញាប់ប្រជាជននៅតំបន់នេះបានរងគ្រោះថ្នាក់ពីគ្រាប់មីនទាំងនេះ។ នៅក្នុងឆ្នាំ១៩៩៣ ខ្ញុំបានស្ម័គ្រចិត្តជួយព្រះតេជគុណ ប៊ុត សាលួត ដើម្បីស្វែងរកទីតាំងគ្រាប់មីនដែលខ្មែរក្រហមបានបង្កប់នៅតាមព្រៃក្នុងសម័យសង្រ្គាមជាមួយវៀតណាមដើម្បីដោះចេញ។ ក្នុងអំឡុងពេលធ្វើការងាររុករកគ្រាប់មីន ខ្ញុំបានឃើញដើមឈើធំៗ និងមានសត្វព្រៃជាច្រើនរស់នៅ ដែលទាក់ទាញចិត្តរបស់ខ្ញុំចង់ការពារទាំងនោះសម្រាប់មនុស្សជំនាន់ក្រោយៗ។ ក្រោយមក ខ្ញុំក៏បានស្ម័គ្រចិត្តចូលធ្វើជាអ្នកការពារព្រៃឈើនៅព្រៃសហគមន៍សង្ឃរុក្ខវ័ន ក្នុងខេត្តឧត្ដរមានជ័យ ដែលដឹកនាំដោយព្រះតេជគុណ ប៊ុត សាលួត រហូតមកដល់សព្វថ្ងៃ។

**ដារ៉ារដ្ឋ មេត្តា**



សត្វសេក នៅក្នុងព្រៃសហគមន៍សង្ឃរុក្ខវ័ន ក្នុងខេត្តឧត្តរមានជ័យ
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# អង្គជំនុំជម្រះសាលាដំបូង
# សេចក្ដីសង្ខេបសាលក្រមសំណុំរឿង០០២/០២

*(តពីលេខមុន)*

*៣៨. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាមៗ លើសពីនេះទៀត ដោយរម្លឹកអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិដែលកំពុងកើតមាននៅពេលនោះ រវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ ចាប់ពីខែឧសភា ឆ្នាំ១៩៧៥ និងឋានៈទទួលបានការការពាររបស់ជនរងគ្រោះ អង្គជំនុំជម្រះយល់ឃើញថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរជាច្រើនលើអនុសញ្ញាទីក្រុងហ្សឺណែវក៏ត្រូវបានប្រព្រឹត្តផងដែរលើក្រុមនេះ នៅមន្ទីរសន្តិសុខ ស-២១ រួមទាំងការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនា នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនដោយខុសច្បាប់ៗ*

### *១.៣.៤.៣. ពុទ្ធសាសនិក*

*៣៥. ចំពោះការប្រព្រឹត្តលើពុទ្ធសាសនិក ដែលបទចោទទាំងនេះ ត្រូវបានកម្រិតត្រឹមតែសហករណ៍ត្រាំកក់ អង្គជំនុំជម្រះយល់ឃើញថា ព្រះពុទ្ធសាសនាត្រូវបានហាមឃាត់ និមិត្តរូបតំណាងឲ្យព្រះពុទ្ធត្រូវបានបំផ្លិចបំផ្លាញ ហើយវត្តអារាម មិនត្រូវបានអនុញ្ញាតឲ្យប្រើសម្រាប់គោលបំណងសាសនាទៀតទេៗ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ព្រះសង្ឃជាង១០០អង្គត្រូវបានគេប្រមូលដោយចេតនាយកទៅដាក់វត្តអង្គរការនិងបង្ខំឲ្យសឹកៗ ព្រះសង្ឃក៏ត្រូវគេបង្ខំឲ្យសឹកនៅតាមវត្តផ្សេងៗទៀត ហើយករណីនេះឆ្លុះបញ្ចាំងអំពីលំនាំទូទៅនៅទូទាំងស្រុកត្រាំកក់ៗ ថ្វីត្បិតតែភស្តុតាងមិន*



*ព្រះសង្ឃសូត្រមន្តបង្សុកូលឧទ្ទិសដល់វិញ្ញាណក្ខន្ធ*
*(រូបថត ៖ បណ្ណសារមជ្ឈ*

*អនុញ្ញាតឲ្យអង្គជំនុំជម្រះសន្និដ្ឋានឲ្យបានច្បាស់លាស់អំពីចំនួនព្រះសង្ឃ ដែលលាចាកសិក្ខាបទសរុបនៅស្រុកត្រាំកក់ក៏*

ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថាមានភ័ស្តុតាងអាចឲ្យជឿទុកចិត្តបានដែលបង្ហាញថា ព្រះសង្ឃរាប់រយអង្គត្រូវបានគេផ្សឹកនៅតាមឃុំនានា។ ចេតនារើសអើងនៅពីក្រោយដំណើរការនេះ ត្រូវបានបញ្ជាក់ដោយការហៅព្រះសង្ឃថាជា«គេនញ៉ា» ឬជា«ឈ្លើង» សង្គមនិងការប្រកាសបដិសេធព្រះពុទ្ធសាសនា ដោយថាជា អបិយជំនឿសុទ្ធសាធ និងថាព្រះពុទ្ធបដិមា «គ្រាន់តែជាស៊ីម៉ង់ត៍ប៉ុណ្ណោះ»។



ជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម
(មជ្ឈមណ្ឌលឯកសារកម្ពុជា)

៣៦. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ត្រូវបានប្រព្រឹត្តឡើងលើពុទ្ធសាសនិក។

### ១.៣.៤.៤. អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៣៧. ចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលបទចោទប្រកាន់ត្រូវបានកម្រិតត្រឹមសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អង្គជំនុំជម្រះយល់ឃើញថា ក្រុមនេះត្រូវបានគេធ្វើទុក្ខបុកម្នេញនៅតាមទីតាំងឧក្រិដ្ឋកម្មទាំងបួន។ ឧទាហរណ៍ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងស្រុកត្រាំកក់ ភ្លាមៗក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អតីតទាហាន និងនគរបាលនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេសម្រិតសម្រាំងនៅវត្តចម្ប៉ា ហើយក្រោយពីបានប្រាប់អត្តសញ្ញាណរបស់ខ្លួនរួចហើយ ពួកគេជាច្រើនត្រូវបាននាំយកទៅ រួចបាត់ខ្លួន។ ដំណើរការដូចគ្នានេះបានកើតឡើងនៅតាមកន្លែងផ្សេងៗទៀតក្នុងស្រុកត្រាំកក់។ ថ្វីត្បិតតែមានផែនការច្បាស់លាស់ក្នុងការបោសសម្អាត និងសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅស្រុកត្រាំកក់ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏ដោយ ក៏យ៉ាងហោចណាស់នៅពេលមួយនោះ មានការផ្សព្វផ្សាយមិនឲ្យប៉ះពាល់អតីតទាហានចាប់ពីស័ក្តិ ១ ដល់ស័ក្តិ ៥។ អង្គជំនុំជម្រះយល់ឃើញថា ទោះជាយ៉ាងនេះក្តី ក្រោយមកអតីតទាហាននិងអ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ ត្រូវគេកំណត់គោលដៅជាថ្មីម្តងទៀតដើម្បីចាប់ខ្លួននិងសម្លាប់។ គ្រួសារអតីតទាហានជាច្រើនត្រូវបានកម្ទេចនៅឃុំពពេល ក្នុងខែឧសភា ឆ្នាំ១៩៧៧ ហើយប្រតិបត្តិការសម្លាប់ដោយមានការរៀបចំ ត្រូវបានធ្វើឡើងនៅស្រុកត្រាំកក់ ចាប់ពីខែមេសា ឆ្នាំ១៩៧៧ ដោយមនុស្សជាច្រើនត្រូវគេយកទៅមន្ទីរសន្តិសុខក្រាំងតាចាន់។ អង្គជំនុំជម្រះជឿជាក់ថា អ្នកទាំងនេះត្រូវគេកំណត់គោលដៅ ដោយផ្អែកលើតួនាទីពិតប្រាកដរបស់ពួកគេនៅក្នុងរបបមុន ឬតាមការសន្មត។

៣៨. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូល

ហេតុនយោបាយត្រូវបានប្រព្រឹត្តនៅសហករណ៍ត្រាំកក់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងពីដើមឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នៅការដ្ឋានការងារទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

### ១.៣.៥.ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍

៣៩. អង្គជំនុំជម្រះយល់ឃើញថា មានគោលនយោបាយនៅទូទាំងប្រទេសក្នុងការកំណត់បទបញ្ជាលើការកសាងគ្រួសារ និងការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវកម្មាភិបាលបក្សអនុវត្តនៅតាមបណ្តាញរដ្ឋបាល និងអង្គភាពយោធាគ្រប់ជាន់ថ្នាក់។ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតគោលនយោបាយនេះឡើង ដើម្បីឲ្យបក្សអាចជំនួសតួនាទីរបស់ឪពុកម្តាយក្នុងការជ្រើសរើសគូស្រករសមស្រប ហើយបង្ខំបុរសនិងស្ត្រីឲ្យរៀបការនឹងគ្នា និងបង្ខំឲ្យបង្កើតកូនក្នុងគោលបំណងបង្កើនចំនួនប្រជាជននៅក្នុងប្រទេសក្នុងរយៈ-ពេលពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ខាងមុខ។

៤០. អង្គជំនុំជម្រះយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំនៅក្នុងវប្បធម៌កម្ពុជាមានភាពខុសគ្នាពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ ការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំនៅក្នុងវប្បធម៌កម្ពុជា មុនរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើការជឿទុកចិត្តគ្នាទៅវិញទៅមករវាងកូនៗ និងឪពុកម្តាយដែលជាអ្នកជ្រើសរើសគូស្រករឲ្យកូន ហើយមិនមានចំណុចនេះទេ នៅពេលដែលបក្សមកជំនួសតួនាទីជាឪពុកម្តាយ នៅក្នុងការរៀបចំអាពាហ៍ពិពាហ៍នោះ។ ភ័ស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះ បង្ហាញយ៉ាងច្បាស់អំពីការអនុវត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមិនបានឆ្លុះបញ្ចាំងទាល់តែសោះអំពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ដោយគ្រួសាររបស់អនាគតប្តីប្រពន្ធនោះមិនបានចូលរួមទាល់តែសោះនៅក្នុងការចរចារសហគមន៍មិនត្រូវបានឲ្យចូលរួម មិនមានប្រពៃណីនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ហើយសមីខ្លួនយល់ព្រមរៀបការដោយខ្លាចបក្សដាក់ទណ្ឌកម្ម។ អង្គជំនុំជម្រះយល់ឃើញថា អាជ្ញាធររបបកម្ពុជាប្រជាធិបតេយ្យបានរៀបចំអាពាហ៍ពិពាហ៍នៅគ្រប់ពេលវេលាក្នុងរបបនេះ និងនៅតាមទីតាំងភូមិសាស្ត្រជាច្រើននៅទូទាំងប្រទេសកម្ពុជា។ បុគ្គលទាំងឡាយបានរៀបអាពាហ៍ពិពាហ៍នៅក្នុងបរិយាកាសភ័យខ្លាច ហើយនៅក្នុងករណីភាគច្រើនការព្រមព្រៀងនៅមុនពេល ឬក្នុងអំឡុងពិធីរៀបអាពាហ៍ពិពាហ៍ ដែលបានលើកឡើងនោះ មិនមែនជាការយល់ព្រមពិតប្រាកដឡើយ។ អង្គជំនុំជម្រះយល់ឃើញថាក្រោយពិធីរៀបអាពាហ៍ពិពាហ៍ ជាធម្មតាអាជ្ញាធរបានរៀបចំឲ្យប្តីប្រពន្ធថ្មីថ្មោងនោះផ្សំដំណេកជាមួយគ្នានៅក្នុងទីតាំងកំណត់ណាមួយ ក្រោមការតាមដានពីកងឈ្លប ជាពិសេសដើម្បីឲ្យមានការរួមភេទ។ ទាំងបុរស និងស្ត្រីយល់ថាពួកគេត្រូវបានបង្ខំឲ្យរួមភេទជាមួយប្តី ឬប្រពន្ធថ្មីថ្មោងរបស់ពួកគេ ហេតុដូច្នេះ ពួកគេបានធ្វើផ្ទុយនឹងឆន្ទៈរបស់ពួកគេ។ ប្តីប្រពន្ធដែលត្រូវបានរកឃើញថាមិនបានរួមភេទ ត្រូវបានយកមកអប់រំ ឬគំរាមកំហែងថានឹងដាក់ទណ្ឌកម្ម ឬសម្លាប់ចោល។

៤១. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានប្រព្រឹត្តឡើង។

(**នៅមានត**)

***អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

# យុត្តិធម៌នៅក្នុងតុលាការខ្មែរក្រហម តាមរយៈការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២

របបខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបានដួលរលំទៅវិញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ នៅក្នុងអំឡុងពេលដែលរបបមួយនេះកាន់អំណាចប្រជាជនកម្ពុជាប្រមាណមួយភាគបួននៃចំនួនប្រជាជនសរុប ត្រូវបានបាត់បង់ជីវិតដោយការសម្លាប់រង្គាល តាមរយៈ ការឃុំឃាំង ការធ្វើទារុណកម្ម ការបង្អត់អាហារ និងការបង្ខំឲ្យធ្វើការហួសកម្លាំង។ ក្រោយពីរបបខ្មែរក្រហមដួលរលំ មានប្រជាជនកម្ពុជាតែប្រមាណប្រាំលានប៉ុណ្ណោះនៅរស់រានមានជីវិត ហើយក្នុងចំណោមនេះមានប្រជាជនកម្ពុជាមួយចំនួនបានទៅរស់នៅបរទេស។ ទោះបីយ៉ាងណាសង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជានៅតែបន្តកើតឡើងរវាងរដ្ឋាភិបាលក្រុងភ្នំពេញ និងចលនាតស៊ូត្រីភាគីនៅតាមព្រំដែនកម្ពុជា-ថៃ។ រហូតដល់ឆ្នាំ១៩៩៨ ទើបសង្គ្រាមស៊ីវិលបានបញ្ចប់នៅពេលដែលរចនាសម្ព័ន្ធ នយោបាយ យោធារបស់ខ្មែរក្រហមត្រូវបានកម្ទេចចោល។

ចាប់តាំងពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានស្នើទៅអង្គការសហប្រជាជាតិ ដើម្បីសុំជំនួយខបត្តម្ភពីអន្តរជាតិបង្កើតតុលាការកាត់ទោសមេដឹកនាំ


រូបរាប់ពីស្តាំ ៖ ដើមបណ្តឹងរដ្ឋប្បវេណីនៅសាលាក្តីខ្មែរក្រហម យាន រ៉ុ និង ម៉ន ម៉ៅ ផ្តល់បទសម្ភាសន៍ដល់បុគ្គលិកទស្សនាវដ្តីស្វែងរកការពិត (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាន់ខ្ពស់ខ្មែរក្រហម ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះ គឺនៅមុនពេលកងកម្លាំងសេសសល់របស់ខ្មែរក្រហមទាំងអស់ បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល នៅចុងឆ្នាំ១៩៩៨។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ អ្នកជំនាញអង្គការសហប្រជាជាតិ បានលើកសំណើអំពីការបង្កើតតុលាការសិទ្ធិមនុស្សមួយនៅក្រៅប្រទេសកម្ពុជា ដោយយកគំរូតាមតុលាការឧក្រិដ្ឋកម្មប្រទេសដទៃ ព្រោះអ្នកជំនាញយល់ថា ការប្រព្រឹត្តរបស់ក្រុមខ្មែរក្រហមនេះ គឺជាចរិតលក្ខណៈឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អន្តរជាតិ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានបដិសេធសំណើនោះ។ រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំឲ្យតុលាការនេះប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់មន្ត្រីចៅក្រមកម្ពុជា រួមជាមួយមន្ត្រីចៅក្រមអន្តរជាតិ។ កម្ពុជាបានអញ្ជើញសហគមន៍អន្តរជាតិឲ្យចូលរួមសហការក្នុងការកាត់ក្តី ដើម្បីធានាឲ្យមានយុត្តិធម៌ជាលក្ខណៈអន្តរជាតិ ព្រោះកម្ពុជាយល់ឃើញថា ខ្លួននៅមានភាពទន់ខ្សោយផ្នែកប្រព័ន្ធច្បាប់។

នៅឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់មួយដើម្បីបង្កើតតុលាការកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែពុំទាន់ឈានដល់កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជានៅឡើយ។ នៅឆ្នាំ២០០៣ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដែលជាតុលាការចម្រុះរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ កម្ពុជាអាចបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាតាមលំនាំច្បាប់ក្នុងស្រុក ប៉ុន្តែតុលាការនេះប្រព្រឹត្តទៅតាមបែបផែនអន្តរជាតិ ព្រោះមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តខុសយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុក។ រហូតមកដល់ឆ្នាំ២០០៦ ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើង និងចាប់ផ្តើមដំណើរការដោយមានការចូលរួមពីសហគមន៍អន្តរជាតិតាមរយៈអង្គការសហប្រជាជាតិ ដែលនឹងអនុវត្តទៅតាមស្តង់ដារអន្តរជាតិ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់នូវទីតាំងមួយកន្លែងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

គោលបំណងនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជានេះឡើងគឺ ដើម្បីផ្តល់ការជំនុំជម្រះក្តីស្របតាម



យាន រ៉ាំ កំពុងផ្តល់បទសម្ភាសដល់បុគ្គលិកមជ្ឈមណ្ឌលឯក

និយាមយុត្តិធម៌អន្តរជាតិដោយការប្រើប្រាស់ច្បាប់ជាតិ រួមមាន៖ ការធ្វើទារុណកម្ម, អំពើមនុស្សឃាត និងការរើសអើងដោយមូលហេតុសាសនា ដែលចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងច្បាប់អន្តរជាតិ រួមមាន៖ អំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩,

ការបំផ្លាញសម្បត្តិវប្បធម៌ក្នុងអំឡុងពេលសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្ដីអំពីទំនាក់ទំនងការបរទេស។

ច្បាប់នេះរៀបចំឡើងដើម្បីវិនិច្ឆ័យទោសមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។ គោលដៅសំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺនាំមកនូវយុត្តិធម៌ជូនប្រជាជនកម្ពុជា លើកកម្ពស់ការផ្សះផ្សាជាតិ និងពង្រឹងនីតិរដ្ឋនៅកម្ពុជា។


ហារកម្ពុជា (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់តាំងពីអង្គជំនុំជម្រះចាប់ផ្ដើមប្រតិបត្តិការការងាររបស់ខ្លួនមក មេដឹកនាំខ្មែរក្រហមកំពូលៗចំនួន៣រូបត្រូវបានកាត់ទោស និងផ្ដន្ទាទោស។ ក្នុងនោះរួមមាន នួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និងកាំង ហ្គេកអ៊ាវ ហៅឌុច ប្រធានមន្ទីរស-២១ ត្រូវបានផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ទង្វើអមនុស្សធម៌និងការបំពាបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាហ្សឺណែវ ឆ្នាំ១៩៤៩។

លោក នីកូឡា គាំចាន់ សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានលើកឡើងនៅក្នុងកម្មវិធីវគ្គបណ្ដុះបណ្ដាលសាស្ត្រាចារ្យសាកលវិទ្យាល័យស្ដីអំពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រសកលលោកថា មេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តិកំហុសយ៉ាងធ្ងន់ធ្ងរដូចជា ការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងមនុស្សជាតិតាមរយៈការវាយប្រហារជាប្រព័ន្ធទៅលើជនស៊ីវិល។ មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យប្រជាជនរបស់ខ្លួនក្លាយទៅជាទាសករ ដែលមានស្ថានភាពរស់នៅលំបាកវេទនាជាទីបំផុតក្នុងហេតុផលបម្រើផលប្រយោជន៍សេដ្ឋកិច្ចរបស់ជាតិ។ មេដឹកនាំខ្មែរក្រហមទាំងនោះ មិនបានគិតគូពីអាយុជីវិតរបស់ប្រជាជនរបស់ខ្លួនឡើយ ហើយចាត់ទុកការសម្លាប់រង្គាលទៅលើប្រជាជន គឺជារឿងធម្មតានៅក្នុងការដឹកនាំប្រទេស។

មេធាវីការពារក្ដី នួន ជា បានពន្យល់ពីហេតុផលដែលខ្មែរក្រហមប្រព្រឹត្តទៅលើប្រជាជនបែបនេះ ក្នុងគោលបំណងបោសសម្អាតខ្មាំងដើម្បីការពារប្រទេសកុំឲ្យធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់វៀតណាម និងសហរដ្ឋអាមេរិក។ ប៉ុន្តែតាមការពិតជាក់ស្ដែងជនរងគ្រោះភាគច្រើនដែលត្រូវបានសម្លាប់សុទ្ធសឹងតែជាប្រជាជនសាមញ្ញ និងកុមារដែលពុំមានលទ្ធភាពក្នុងការតបត និងការពារខ្លួនឡើយ។ នៅក្នុងច្បាប់អន្តរ

ជាតិយើងមិនអាចសម្លាប់នណាម្នាក់បានទេ ប្រសិនបើគ្មានការវិនិច្ឆ័យទោសត្រឹមត្រូវ។ ការចាប់ខ្លួននៅក្នុងមន្ទីរស-២១ ពុំមានលក្ខណៈស្របច្បាប់នោះទេ ព្រោះជាការចាប់ខ្លួនតគ្នា។ ការសម្លាប់ទៅលើជាតិសាសន៍ណាមួយ ក្នុងចេតនាសម្លាប់ទាំងក្រុមក៏ត្រូវបានចាត់ទុកថា ជាអំពើប្រល័យពូជសាសន៍ដែរ។ នួន ជា និង ខៀវ សំផន ត្រូវបានជាប់ចោទពីបទសម្លាប់ជនជាតិភាគតិចវៀតណាម និងជនជាតិភាគតិចចាមដែលរស់នៅក្នុងប្រទេសកម្ពុជា។ តួនាទីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនគ្រាន់តែកាត់ទោសទៅលើមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ គឺដើម្បីកត់ត្រារឿងរ៉ាវទាំងនោះចងក្រងជាឯកសារទុកឲ្យអ្នកសិក្សាជំនាន់ក្រោយបានស្វែងយល់។ ជាពិសេសតុលាការនេះបានផ្តល់នូវការព្យាបាលរបួសផ្លូវចិត្ត និងការផ្សះផ្សានៅក្នុងសង្គមកម្ពុជា។

យាន រ៉ាំ ភេទប្រុស អាយុ៦០ឆ្នាំ គឺជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់មកពីខេត្តឧត្តរមានជ័យក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២សរុបចំនួន៣៨៦៦នាក់ បានលើកឡើងថា ខ្ញុំបានដាក់ពាក្យបណ្តឹងទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ តាមរយៈអង្គការអាដហុកនៅឆ្នាំ២០០៦។ គោលបំណងនៃការដាក់ពាក្យបណ្តឹងគឺដើម្បីស្វែងរកយុត្តិធម៌ជូនបងប្រុសដែលបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ បងប្រុសរបស់ខ្ញុំឈ្មោះ យាន សារឿន។ គាត់ជាអតីតទាហាន លន់ នល់ ដែលត្រូវបានខ្មែរក្រហមចាប់ខ្លួនយកទៅសម្លាប់ក្នុងឆ្នាំ១៩៧៦ ដោយយោធាខ្មែរក្រហមចោទគាត់ថាជាខ្សែបណ្តាញ ស៊ី.អាយ.អេ។ រហូតមកដល់ពេលនេះខ្ញុំ បានទទួលនូវការព្យាបាលរបួសផ្លូវចិត្តមួយចំនួនធំ ក្រោយពីបានចូលរួមនៅក្នុងដំណើរការកាត់ទោសមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យឲ្យជាប់គុកអស់មួយជីវិត។

ម៉ន ម៉ៅ ជាដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០២/០១ និង០០២/០២ មកពីខេត្តឧត្តរមានជ័យ បានមានប្រសាសន៍ថា ខ្ញុំបានដាក់ពាក្យបណ្តឹងមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមរយៈអង្គការអាដហុក ដែលបានចុះផ្សព្វផ្សាយពីរបបកម្ពុជាប្រជាធិបតេយ្យនៅតាមខេត្ត។ អង្គការនេះបានធ្វើការពន្យល់ណែនាំប្រជាជនឲ្យដាក់ពាក្យបណ្តឹងទៅតុលាការប្រសិនបើបាត់បង់សាច់ញាតិនៅក្នុងខ្មែរក្រហម។ ខ្ញុំបានដាក់ពាក្យបណ្តឹង ដើម្បីស្វែងរកយុត្តិធម៌ជូនឪពុកមាដែលបានស្លាប់។ គាត់ឈ្មោះ ជា ផុង ត្រូវបានខ្មែរក្រហមសម្លាប់នៅខែមិថុនា ឆ្នាំ១៩៧៦ ដោយសារគាត់ជាអតីតទាហានលន់នល់។ តាមរយៈការដាក់ពាក្យបណ្តឹងនេះខ្ញុំទទួលបានសំណងផ្លូវចិត្ត ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការដែលបានកាត់ទោសមេដឹកនាំខ្មែរក្រហមទៅតាមផ្លូវច្បាប់។



សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡា គាំចាន់ ធ្វើបទបង្ហាញ ពីដំណើរការនៃសាលាក្តីខ្មែរក្រហមទៅកាន់វាលគ្មិន (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរួមចំណែកយ៉ាងសំខាន់ ដើម្បីនាំយកយុត្តិធម៌ជូនប្រជាជនកម្ពុជាតាមរយៈការកាត់ទោសមេដឹកនាំខ្មែរក្រហម និងបានផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមដោយផ្ទាល់នៅក្នុងសវនាការ ដែលផ្នែកមួយនៃការផ្សះផ្សា និងជួយព្យាបាលរបួសផ្លូវចិត្តសម្រាប់ជនរងគ្រោះពីរបបខ្មែរក្រហម។

**ផាត ចាន់សុនិតា**

# សាស្ត្រាចារ្យ មីលតុន អស្ប៊ូន ចែករំលែកបទពិសោធន៍ទាក់ទងជនភៀសខ្លួនក្នុងអំឡុងរបបខ្មែរក្រហមជាមួយសាស្ត្រាចារ្យ និងលោកគ្រូអ្នកគ្រូ

លោកសាស្ត្រាចារ្យបណ្ឌិត មីលតុន អស្ប៊ូន បានលើកឡើងថា «អស់រយៈពេល៦០ឆ្នាំកន្លង មកហើយ ដែលខ្ញុំបានមកដល់ប្រទេសកម្ពុជាដំបូង ដោយក្នុងគោលបំណងចូលកាន់តំណែងជាមន្ត្រី ការទូតវ័យក្មេង នៃស្ថានទូតប្រទេសអូស្ត្រាលី ប្រចាំនៅប្រទេសកម្ពុជាដែលមានរយៈពេលជាងពីរឆ្នាំ ចាប់តាំងពីឆ្នាំ១៩៥៩។ ខ្ញុំបានចំណាយពេលវេលានៅទីក្រុងភ្នំពេញ និងបានធ្វើដំណើរទេសចរនៅក្នុងប្រទេសកម្ពុជាដើម្បីធ្វើការសិក្សា និងសរសេរអំពីព្រឹត្តិការណ៍សោកនាដកម្មនៃជម្លោះនយោបាយ និងយោធានៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង៥ទសវត្សរ៍។ ចំណងពាក់ព័ន្ធដែលមានរយៈពេលយ៉ាងយូររបស់ខ្ញុំគឺជាការទទួលបានចំណេះដឹងយ៉ាងជ្រាលជ្រៅនៃរយៈកាលអន្ធការដ៏ ខ្មៅងងឹតនៃរបបផ្ដាច់ការប៉ុល ពត ចន្លោះពីឆ្នាំ១៩៧៥-១៩៧៩។ ជាពិសេស នៅក្នុងអំឡុងពេល ដែលខ្ញុំមកដល់ប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥ ខ្ញុំក៏បានបាត់បង់មិត្តភក្តិជិតស្និទ្ធម្នាក់ ក្នុងចំណោមមិត្តភក្តិជិតស្និទ្ធជាច្រើនផ្សេងទៀត។ នៅពេលនោះ ក្នុងចំណោមមិត្តភក្តិទាំងអស់របស់ខ្ញុំ មានមិត្តភក្តិម្នាក់ដែលបានធ្វើការនៅក្នុងប្រទេសថៃ បានស្លាប់បាត់បង់ជីវិតស្របពេលដែលរបបកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាចដែរ។ ខ្ញុំក៏បានដឹងយ៉ាងច្បាស់ដែរថា មានមិត្តភក្តិរបស់ខ្ញុំពីរនាក់ត្រូវបានខ្មែរក្រហមសម្លាប់ និងអ្នកផ្សេងទៀតត្រូវបានបាត់ខ្លួន។ ដូច្នេះ អំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ខ្ញុំពិតជាមានគោលជំហរយ៉ាងរឹងមាំ ប៉ុន្តែក៏មានផលអវិជ្ជមានដែលធ្លាប់បានកើត ឡើងចន្លោះឆ្នាំ១៩៧៥-១៩៧៩។ នៅខណៈពេលដែលខ្ញុំកំពុងរៀបរាប់នាពេលឥឡូវនេះ ខ្ញុំពិតជាមានអារម្មណ៍ក្តុកក្តួលចំពោះលោកខាងលិច ដែលបានបិទភ្នែក



សាស្ត្រាចារ្យ មីលតុន អស្ប៊ូន ចែករំលែកបទពិសោធន៍ស្តីពីការសរសេរសៀវភៅរបស់លោកជាមួយលោកគ្រូអ្នកគ្រូ និងសាស្ត្រាចារ្យ នៅក្នុងសន្និសីទស្តីពីអំពើប្រល័យពូជសាសន៍ (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅអំឡុងពេលដែលខ្មែរក្រហមកាន់អំណាច។ ប៉ុន្តែខ្ញុំក៏ទទួលស្គាល់ចំពោះទុក្ខសោក និងទុក្ខព្រួយរបស់ខ្ញុំដែលបានបាត់បង់មិត្តភក្តិស្និទ្ធស្នាលអស់ជាច្រើននាក់ បើប្រៀបធៀបទៅនឹងការរងទុក្ខវេទនា និងការបាត់បង់សាច់ញាតិបងប្អូនរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស។ ក្នុងនាមខ្ញុំជាជនបរទេសម្នាក់ ខ្ញុំបានត្រឹមតែសរសេរ និងរៀបរាប់អំពីទុក្ខសោក និងទុក្ខវេទនារបស់ប្រជាជនកម្ពុជាដែលធ្លាប់ទទួលរងគ្រោះនៃរបបខ្មែរក្រហម ប៉ុណ្ណោះ។

ទោះជាយ៉ាងណាក៏ដោយ នៅមានហេតុផលជាក់លាក់មួយចំនួនចំពោះការយល់ដឹងរបស់ខ្ញុំអំពីការបាត់បង់ និងការរងទុក្ខដែលខ្ញុំកំពុងតែលើកឡើង។ ហេតុផលទាំងនេះ គឺស្ដែងចេញមកពីការអានកាសែត និងការអានអត្ថបទផ្សេងៗ។ មិនតែប៉ុណ្ណោះ ខ្ញុំក៏មានបទពិសោធន៍ផ្ទាល់ខ្លួន របស់ខ្ញុំ ក្នុងមុខតំណែងជាប្រឹក្សាយោបល់របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ទាក់ទងនឹង «វិបត្តិជនភៀសខ្លួននៅកម្ពុជា»។ ហេតុដូច្នេះ បានធ្វើឲ្យយល់កាន់តែស៊ីជម្រៅ ចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ បញ្ហាទាំងអស់នេះ បានធ្វើឲ្យសហគមន៍អន្តរជាតិត្រូវប្រឈមមុខ ក្នុងការស្វែងរកដំណោះស្រាយជាមួយជនភៀសខ្លួន កម្ពុជានៅតាមច្រកព្រំដែនកម្ពុជា-ថៃ ដែលត្រូវបានហៅជំរំភៀសខ្លួន«ព្រំដែន» ឬជំរំក្រៅផ្លូវការ នៅតាមកម្ពុជា-ថៃដែលមានជនភៀសខ្លួនកម្ពុជាជាង៣០០.០០០នាក់ ដែលបានបោះបង់ផ្ទះសម្បែងរបស់ខ្លួន ដើម្បីស្វែងរកសិទ្ធិជ្រកកោនពីរដ្ឋាភិបាលដែលត្រូវបានបង្កើតថ្មីគឺរដ្ឋាភិបាលសាធារណរដ្ឋ ប្រជាមានិតកម្ពុជា (PRK)។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានបង្កើតឡើងនៅខែមករា នៅឆ្នាំ១៩៧៩»។

ចំពោះបញ្ហាដែលបង្កឲ្យមានជនភៀសខ្លួននៅកម្ពុជា ដោយសារតែឧក្រិដ្ឋកម្មក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ គឺជាសោកនាដកម្មរបស់មនុស្សជាតិដ៏អាក្រក់បំផុតមួយក្នុងចំណោម សោកនាដកម្មទាំងឡាយនាសតវត្សរ៍ទី២០។ របបនេះបានសម្លាប់ប្រជាជនកម្ពុជាប្រមាណ២លាន់ ហើយបានបន្សល់ទុកនូវស្ត្រីមេម៉ាយ និងកុមារកំព្រារាប់រយពាន់នាក់។ ប្រជាជនខ្មែររាប់សែននាក់ បានរត់ចេញពីប្រទេស ហើយបានក្លាយជាជនភៀសខ្លួន។ គ្រាប់មីនរាប់លានគ្រាប់ត្រូវបានបង្កប់ដោយកងទ័ពខ្មែរក្រហម និងកងកម្លាំងរបស់រដ្ឋាភិបាលដែលបណ្ដាលឲ្យប្រជាជនរាប់ពាន់នាក់ ស្លាប់ និងពិការ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០រហូតមក។

លោកសាស្ត្រាចារ្យបណ្ឌិត មីលតុន អស្បូន គឺជាអ្នកនិពន្ធ និងជាអ្នកអត្ថាធិប្បាយឯករាជ្យ ដែលបានធ្វើការជាអ្នកការទូតអូស្ត្រាលី អ្នកសិក្សាស្រាវជ្រាវ មន្ត្រីសាធារណៈ និងជាមន្ត្រីប្រឹក្សារបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR)។ លោកសាស្ត្រាចារ្យបណ្ឌិត ក៏បាននិពន្ធសៀវភៅចំនួន១១ក្បាលរួចមកហើយ ដែលទាក់ទងនឹងអាស៊ីអាគ្នេយ៍ ជាពិសេសទាក់ទងនឹងប្រទេសកម្ពុជា រួមមានព្រះជីវប្រវត្តិរបស់សម្ដេច នរោត្តម សីហនុ ក្រោម ចំណងជើងថា «ព្រះអង្គម្ចាស់នៃពន្លឺ» និង«ព្រះអង្គម្ចាស់នៃភាពងងឹត» ដែលបានបោះពុម្ពផ្សាយ កាលពីឆ្នាំ១៩៩៤។ ជាងនេះទៅទៀតលោកសាស្ត្រាចារ្យបណ្ឌិតក៏ធ្លាប់បានបោះពុម្ពផ្សាយ សៀវភៅរបស់លោកដែលមានចំណងជើងថា «អាស៊ីអាគ្នេយ៍» គឺជាសៀវភៅដែលទាក់ទងនឹងប្រវត្តិសាស្ត្រ ដែលត្រូវបានបោះពុម្ពផ្សាយជាលើកដំបូងក្នុងឆ្នាំ១៩៧៩ ហើយនាពេលឥឡូវនេះ សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយជាលើកទី១២ ព្រមទាំងបានប្រើប្រាស់យ៉ាងទូលំទូលាយនៅតាមសាកលវិទ្យាល័យ និងសាលារៀននៅលើសកលលោក។ ចំពោះស្នាដៃនៃការនិពន្ធសៀវភៅចុងក្រោយរបស់លោកសាស្ត្រាចារ្យបណ្ឌិត គឺជាសៀវភៅដែលមានចំណងជើងថា «ប៉ុល ពត បានដោះស្រាយបញ្ហាដ៏ធំយ៉ាងធំ» សៀវភៅនេះ បានផ្ដោតសំខាន់ទៅលើការចងចាំពីសម័យអាណានិគមន៍ និងក្រោយអាណាគមន៍ឆ្នាំ១៩៥៦-១៩៨១ ដែលបានបោះពុម្ពផ្សាយកាលពីឆ្នាំមុន។

ហួ ថុនា

# ការចងចាំអំពីរបបខ្មែរក្រហម បង្ហាញអំពីភាពរឹងមាំរបស់ប្រជាជនកម្ពុជា

ពេលវេលាចេះ តែធ្វើដំណើរទៅមុខមិនឈប់ឈរកន្លងអស់រយៈពេលជាង៤០ឆ្នាំ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ប៉ុន្តែការចងចាំ សេចក្តីទឹករពុកនៅតែមានជាដរាបចំពោះទំហំនៃការបាត់បង់ ការប្រឈមមុខនឹងស្ថានភាពដ៏សែនគ្រោតគ្រាត និងសេចក្តីឈឺចាប់របស់ប្រជាជនកម្ពុជាដែលបានបង្កឡើងដោយក្រុមកុម្មុយនីសខ្មែរក្រហមក្នុងអំឡុងពេលនៃសតវត្សរ៍ទី២០។ ទោះបីជារឿងរ៉ាវទាំងឡាយដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមស្ថិតក្នុងរូបភាពសាហាវព្រៃផ្សៃ ជួនពេលខ្លះស្ទើរតែមិនអាចទទួលយកបាននូវហេតុការណ៍ដ៏សែនរន្ធត់ទាំងនោះ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជា ការរំឭកអំពីរឿងរ៉ាវទាំងអស់នេះសារឡើងវិញត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ថែមទាំងទទួលបានការគាំទ្រឲ្យមានការបង្កើតឡើងនូវសកម្មភាពផ្សេងៗទៀតយ៉ាងផុសផុលដល់ការលើកកម្ពស់ និងជំរុញឲ្យមានការស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរ



ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចុះជួប និងធ្វើការងារជាប្រជាជននៅតាមភូមិ
(រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រហម។

ជារៀងរាល់ឆ្នាំនាថ្ងៃទី២០ឧសភា នៅក្នុងប្រទេសកម្ពុជា គឺជាថ្ងៃមួយដែលរដ្ឋាភិបាលកម្ពុជា បានជ្រើសរើសប្រារព្ធពិធីនៃការចងចាំ ដែលត្រូវបានធ្វើឡើងនៅតាមបូជនីយដ្ឋាននានាដូចជា អតីតទីតាំងសម្លាប់ រណ្តៅសាកសព និងអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ក្នុងគោលបំណងរំឭកដល់ទុក្ខវេទនា ការឈឺចាប់ ការកាប់សម្លាប់ ភាពអយុត្តិធម៌ថែមទាំងជាឱកាសនៃការប្រមូលផ្តុំនូវសំឡេងមួយ ដើម្បីលាតត្រដាងពីអំពើឃោរឃៅរបស់ខ្មែរក្រហម ដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា។ រួមជាមួយគ្នានោះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា បានចូលរួមលើកកម្ពស់ថែរក្សាការចងចាំ ការផ្សះផ្សា និងការស្វែងរកយុត្តិធម៌ ដោយទាមទារឲ្យចាប់ផ្តើមធ្វើកិច្ចការងាររបស់ខ្លួននៅតាមថ្នាក់មូលដ្ឋាន ព្រោះឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដែលភាគច្រើនបានបង្កឡើងនៅក្នុងថ្នាក់មូលដ្ឋាន។ ដូចច្នេះហើយ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតឲ្យមាននូវមជ្ឈមណ្ឌលចំនួនពាក់កន្លែងផ្សេងៗគ្នា ស្ថិតនៅលើទីតាំងសំខាន់ៗ ដែលធ្លាប់បានមើលរំលងទៅលើកិច្ចការងារដែលអាចចូលរួមចំណែកមួយយ៉ាងសកម្មដល់ការចងចាំ ផ្សះផ្សា និងការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា។

ទី១) មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ៖ ស្ថិតនៅក្នុងភូមិជនបទដាច់ស្រយាលតូចមួយ នៅភាគខាងជើងនៃប្រទេសកម្ពុជា ដែលបានជ្រើសរើសយកអតីតទីបញ្ជាការរបស់តាម៉ុក នៅលើខ្នងភ្នំដងរែកមកធ្វើជាការិយាល័យធ្វើកិច្ចការងាររបស់ខ្លួន។ អន្លង់វែង គឺជាទីកន្លែងដំបូងដែលត្រូវបានកាន់កាប់ដោយខ្មែរក្រហម និងជាទីបញ្ជាការចុងក្រោយរបស់ខ្មែរក្រហមមុនពេលប្រគល់ខ្លួនដល់រដ្ឋាភិបាលកម្ពុជានៅក្នុងឆ្នាំ១៩៩៩។ ដូច្នេះ ប្រវត្តិសាស្ត្រអន្លង់វែង ត្រូវបានផ្សារភ្ជាប់ជាមួយនឹងប្រវត្តិសាស្ត្រនៃចលនាក្រហមគួរឲ្យកត់សម្គាល់។ គោលបំណងរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺចូលរួមថែរក្សា និងអភិរក្សតំបន់ប្រវត្តិសាស្ត្រនៅក្នុងស្រុកអន្លង់វែងតាមរយៈការរៀបចំឲ្យមានដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងការផ្សះផ្សានៅក្នុងតំបន់នោះ។ ដោយសារតំបន់អន្លង់វែង គឺជាតំបន់ដែលធ្លាប់តែមានការប្រយុទ្ធគ្នា អំពើហិង្សា ការឈឺចាប់ និងគ្រប់គ្រងដោយអតីតយោធាខ្មែរក្រហម ទើបធ្វើឲ្យប្រជាជនមានទស្សនយល់ឃើញផ្សេងៗគ្នាលើប្រវត្តិសាស្ត្រក្នុងតំបន់នេះ និងធ្វើឲ្យមានគម្លាតគ្នាកាន់តែឆ្ងាយរវាងអតីតខ្មែរក្រហម និងជនរងគ្រោះពីរបបនេះ។

កិច្ចការរបស់យើងគឺត្រូវខិតខំពន្យល់រឿងរ៉ាវដែលបានកើតឡើងពីរបបខ្មែរក្រហម ដើម្បីជំរុញឲ្យមានការផ្សះផ្សា និងការព្យាបាលនៅក្នុងប្រទេសកម្ពុជាសម្រាប់ទប់ស្កាត់អំពើឃោរឃៅបែបនេះកុំឲ្យកើតឡើងម្តងទៀត នៅក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោក។ មិនតែប៉ុណ្ណោះ យើងថែមទាំងបានរៀបចំចងក្រងឯកសារអំពីរឿងរ៉ាវរបស់សមាជិកក្រុមខ្មែរក្រហម និងជនរងគ្រោះក្នុងតំបន់ដោយមានគោលបំណងអភិរក្សប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងជំរុញកិច្ចពិភាក្សារវាងជនដៃដល់ខ្មែរក្រហម និងជនរងគ្រោះពីអំពើប្រល័យពូជសាសន៍។

ទី២) មជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា ៖ មានទីតាំងស្ថិតនៅក្នុងសាលាគរុកោសល្យភូមិភាគព្រៃវែង ដែលស្ថិតនៅក្នុងភូមិភាគបូព៌ានៃប្រទេសកម្ពុជា ក្នុងកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ នៅក្នុងរបបខ្មែរក្រហម ភូមិភាគបូព៌ា គឺជាតំបន់មួយដែលត្រូវបានខ្មែរក្រហមកាន់កាប់មុនដំបូងគេបង្អស់ ហើយក៏ជាទីតាំងមួយដែលរបបខ្មែរក្រហមត្រូវបានផ្តួលរលំមុនគេដែរ។ នៅក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ នៃក្នុងរបបខ្មែរក្រហមគឺនៅក្នុងឆ្នាំ១៩៧៨ ប្រជាជនក្នុងតំបន់នេះបានទទួលរងនូវការសម្លាប់យ៉ាងឃោរឃៅបំផុតដោយសារតែតំបន់នេះមានការបះបោរ។ ប្រជាជនកម្មាភិបាល និងយោធានៅក្នុងតំបន់នេះក៏ទទួលរងការធ្វើបន្សុទ្ធកម្មឡើងវិញ ថែមទាំងមានការរៀបចំឲ្យមានអ្នកដឹកនាំថ្មី ដើម្បីទប់ទល់នឹងអ្នកបះបោរប្រឆាំងនឹងការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តខ្មែរក្រហម។ ប្រជាជនត្រូវជម្លៀសចេញទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគផ្សេងៗទៀត ហើយបន្ទាប់មកត្រូវបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរ និងកាប់សម្លាប់

នៅតាមតំបន់ទាំងនោះ។

ការបង្កើតឡើងនូវមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា គឺដើម្បីថែរក្សាការចងចាំ និងស្វែងយល់អំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ថែមទាំងផ្តល់ជូននូវភាពងាយស្រួលចំពោះការប្រើប្រាស់ឯកសារទាំងឡាយដល់សាធារណៈជន។ មជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា ក៏បានចូលរួមចំណែកលើកកម្ពស់ដល់ការផ្សះផ្សាដោយបង្កើតឲ្យមានការពិភាក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់ក្មេងៗជំនាន់ក្រោយ និងបង្កើនឲ្យមានការយល់ដឹងជាសាធារណៈអំពីអំពើប្រល័យពូជសាសន៍ និងបទពិសោធន៍របស់ជនរងគ្រោះដែរ។

ទី៣) មជ្ឈមណ្ឌលផ្សះផ្សាវាលវែល ៖ មានទីតាំងស្ថិតនៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា។ គោលគំនិតសំខាន់នៃការបង្កើតមជ្ឈមណ្ឌលផ្សះផ្សានៅតាមតំបន់ដាច់ស្រយាលនេះ ព្រោះដោយសារតែតំបន់នេះត្រូវបានមើលរំលងអស់រយៈពេលយូរណាស់មកហើយ។ តំបន់វាលវែង គឺជាតំបន់មួយដែលភាគច្រើនគឺជាកន្លែងរស់នៅរបស់អតីតកម្មាភិបាលខ្មែរក្រហមចាប់តាំងពីអំឡុងពេលនៃរបបខ្មែរក្រហមរហូតមកដល់សព្វថ្ងៃនេះ។ ដូចេ្នះ តម្រូវការនៃការផ្សះផ្សា និងការធ្វើកិច្ចការស្រាវជ្រាវត្រូវតែមានជាចាំបាច់ដើម្បីការពារការកើតមានឡើងនៃជម្លោះក្នុងតំបន់ ថែមទាំងលើកទឹកចិត្តឲ្យចូលរួមផ្សះផ្សារវាងអតីតកម្មាភិបាលខ្មែរក្រហម ជនរងគ្រោះ និងក្មេងៗជំនាន់ក្រោយតាមរយៈការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

សម្រាប់ប្រទេសកម្ពុជា ការអនុញ្ញាតឲ្យទទួលបាននូវការស្វែងយល់អំពីប្រទេសរបស់ខ្លួនឲ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ គឺត្រូវបានធ្វើឡើងដោយបើកចំហចំពោះសហគមន៍ជាតិ និងអន្តរជាតិ។ ជាក់ស្តែង ប្រទេសហ្វីលីពីន គឺជាប្រទេសទី២ ដែលបានផ្តល់ទីតាំងធ្វើជាជំរំជនភៀសខ្លួនដល់ប្រជាជនកម្ពុជាជាច្រើននាក់មុននឹងធ្វើដំណើរទៅរស់នៅក្នុងប្រទេសទីពាបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ បានទទួលការសិក្សាស្វែងយល់ជាច្រើនពីប្រទេសកម្ពុជាទាំងផ្នែកប្រវត្តិសាស្ត្រ ក៏ដូចជាវប្បធម៌ជាដើម។ ស្ថានទូតរបស់ប្រទេសកម្ពុជាប្រចាំនៅក្នុងប្រទេសហ្វីលីពីន បានខិតខំធ្វើកិច្ចការងាររបស់ខ្លួនជាច្រើនទាក់ទងទៅនឹងការផ្សព្វផ្សាយអំពីវប្បធម៌ អរិយធម៌ដ៏ត្រចះត្រចង់របស់ប្រទេសកម្ពុជាកាលពីយូរអង្វែងណាស់មកហើយទៅកាន់ប្រជាជននៅក្នុងប្រទេសហ្វីលីពីន និងជនជាតិបរទេសជាច្រើនទៀត តាមរយៈការដាក់តាំងដាក់តាំងពិព័រណ៍ ការរៀបចំសម្តែងសិល្បៈ ការផ្សព្វផ្សាយអំពីចំណីអាហារនៅតាមកម្មវិធីជួបជុំនានា។ នៅក្នុងនោះដែរ ប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ក៏ត្រូវបានលើកឡើងនៅក្នុងកម្មវិធីផ្សេងៗ ដូចជាកម្មវិធីបដិសណ្ឋារកិច្ចការទូតជាមួយបរទេសសិស្ស និងនិស្សិតដែរ។ ប៉ុន្តែគួរឲ្យសោកស្តាយ ស្ថានទូតរបស់ប្រទេសកម្ពុជាប្រចាំនៅក្នុងប្រទេសហ្វីលីពីន មិនមានគម្រោងប្រារព្ធទិវានៃការចងចាំនៅ ថ្ងៃទី២០ ឧសភា ឆ្នាំ ២០១៩ នេះទេ ព្រោះដោយសារតែមានកិច្ចការមមាញឹកជាច្រើនទាក់ទងនឹងកិច្ចការបោះឆ្នោតថ្មីៗ នៅក្នុងប្រទេសហ្វីលីពីន។

ទោះបីយ៉ាងណាការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនឹងជួយប្រជាជនកម្ពុជាឲ្យមានភាពរឹងមាំ មានការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ថែមទាំងចូលរួមចំណែកក្នុងការពារការកើតឡើងវិញរាល់គ្រប់ទម្រង់នៃអំពើប្រល័យពូជសាសន៍ នៅក្នុងប្រទេសកម្ពុជា និងពិភពលោក។

មជ្ឈមណ្ឌលកម្ពុជាសង្ឃឹមថា គម្រោងនៃការបង្កើតមជ្ឈមណ្ឌលទាំង៣ និងកិច្ចការងារទាំងឡាយដែលខ្លួនបានខិតខំធ្វើកន្លងមក និងបន្តធ្វើនាពេលអនាគត គឺជាផ្នែកមួយនៃការចូលរួមដល់ការថែរក្សាការចងចាំ ជូនចំពោះអ្នកដែលបានបាត់បង់ជីវិត និងចូលរួមចែករំលែកសេចក្តីឈឺចាប់ និងទុក្ខកង្វល់របស់ប្រជាជនខ្មែរ ថែមទាំងជាផ្នែកមួយនៃការថែរក្សាសន្តិភាពសម្រាប់ប្រទេសកម្ពុជា និងពិភពលោកទាំងសមូលដែរ។

*អ៊ុន សុដារី*

# សាច់ញាតិរបស់ខ្ញុំដែលបែកគ្នាក្នុងរបបខ្មែរក្រហម

នាងខ្ញុំឈ្មោះ យិន សុភានី បច្ចុប្បន្នប្តូរមកឈ្មោះ ពេជ្រ ដានី មានម្តាយឈ្មោះ ឡុង គីមលុយ កាលពីមុនរបបខ្មែរក្រហមមានមុខរបរជាមេផ្ទះ និងបង្រៀនគួរភាសាចិន ចំណែកឪពុករបស់ខ្ញុំឈ្មោះ យិន សុចៀន គឺជាអតីតនាយកសាលាវិទ្យាល័យបឹងត្របែក។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់។ បងប្រុសទី១) ឈ្មោះ យិន ណារិត បងប្រុសទី២) ឈ្មោះ យិន ណារិន ទី៣) ខ្ញុំ (យិន សុភានី), ប្អូនស្រីទី៤) ឈ្មោះ យិន សុគន្ធា និង ប្អូនប្រុសទី៥) ឈ្មោះ យិន ណារ៉េត។ បច្ចុប្បន្នខ្ញុំរស់នៅសង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប។

នាងខ្ញុំបានរៀនត្រឹមថ្នាក់ទី២។ បងប្រុស យិន ណារិត បានរៀនត្រឹមថ្នាក់ទី៥។ បងប្រុស យិន ណារិន បានរៀនត្រឹមថ្នាក់ទី៦ ចំណែកប្អូនស្រីរបស់ខ្ញុំឈ្មោះ យិន សុគន្ធា បានរៀនត្រឹមថ្នាក់ទី១នៃសាលាបឋមសិក្សាមួយនៅជិតផ្សារមាន់អាំងខណ្ឌទួលគោក។ មុនឆ្នាំ១៩៧៥ គ្រួសារខ្ញុំរស់នៅចម្ងាយប្រមាណជា១គីឡូម៉ែត្រពីអង់តែនទួលគោក។ នៅមុខផ្ទះរបស់ខ្ញុំមានដើមចន្ទគិរីមួយដើមយ៉ាងធំ។

មុនខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អ៊ំរបស់ខ្ញុំឈ្មោះ ឡុង មួយគា និងស្វាមីរបស់គាត់ដែលមានមុខរបរជាគ្រូពេទ្យនៅមន្ទីរពេទ្យចិនរស់នៅម្តុំផ្សារថ្មី បានជិះយន្តហោះចាកចេញពីទីក្រុងភ្នំពេញដោយបាននាំយកបងប្រុសទី១របស់ខ្ញុំឈ្មោះ យិន ណារិត ទៅជាមួយ ព្រោះគាត់ទាំងពីរនាក់មិនមានកូន។ ប៉ុន្តែខ្ញុំមិនដឹងថាអ៊ំរបស់ខ្ញុំចាកចេញទៅ



រូបរាប់ពីខាងស្តាំ ៖ យិន សុភានី ជាមួយបងថ្លៃនៅអង្គរវត្ត ឆ្នាំ១៩៨៤



រូបទីពីររាប់ពីឆ្វេង ៖ យិន សុភានី និង ស្វាមី ថតនៅថ្ងៃមង្គលការប្អូនថ្លៃ ក្នុងអំឡុងឆ្នាំ១៩៨៣ និង ១៩៨៤

ប្រទេសណាឡើយ។ អ៊ំរបស់ខ្ញុំហាក់បីដូចជាដឹងថា ប្រទេសនឹងធ្លាក់ចូលគ្រោះមហន្តរាយមិនខានឡើយ។ មិនបានប៉ុន្មានថ្ងៃផង យោធាខ្មែរក្រហមបានចូលដល់ទីក្រុងភ្នំពេញ។ ពេលនោះគ្រួសាអ៊ំ ឡុង សារុម មួយគ្រួសារទៀតដែលរស់នៅម្តុំគីឡូម៉ែត្រលេខ៦ បានដិះឡានមកផ្ទះរបស់ខ្ញុំ និងបានបបួលក្រុមគ្រួសាររបស់ខ្ញុំដិះឡានចាកចេញពីទីក្រុងភ្នំពេញជាមួយគ្នា។ នៅតាមផ្លូវយោធាខ្មែរក្រហមបានស្រែកប្រាប់ប្រជាជនឲ្យ «ទៅស្រុកលើៗ» ប៉ុន្តែយើងមិនដឹងថា «ស្រុកលើ» នៅទីណានោះទេ។ យើងបានធ្វើដំណើរលើផ្លូវរទេះគោ រដិបរដុប និងតូចចង្អៀតរហូតដល់ឡានទៅមុខលែងរួចទើបយើងឈប់។ ខ្មែរក្រហមបានប្រាប់យើងឲ្យយកអីវ៉ាន់ចុះ ហើយចាប់តាំងពីពេលនោះមកគ្រួសារខ្ញុំ និងគ្រួសារអ៊ំ ឡុង សារុម រួមជាមួយកូនរបស់គាត់ពាក់ទៀតបានបែកគ្នារហូត។ គ្រួសាររបស់ខ្ញុំ, តា (ឡុង) និងយាយរបស់ខ្ញុំបានរស់នៅជុំគ្នា។ គ្រួសាររបស់ខ្ញុំ



យិន សុភានី និងស្វាមីនៅឆ្នាំ១៩៨៤

បានរស់នៅយ៉ាងលំបាក ព្រោះយើងជាប្រជាជន១៧ មេសា។ នៅឆ្នាំ១៩៧៦ គ្រួសារខ្ញុំត្រូវបានបញ្ជូនទៅរស់នៅម្តុំភ្នំលៀប ក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ កាលនោះខ្ញុំនិងប្អូនស្រីរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅក្នុងកងកុមារ ចំណែកសមាជិកគ្រួសារផ្សេងទៀតក៏ត្រូវបានចាត់តាំងឲ្យធ្វើការរៀងៗខ្លួនដែរ។ នៅទីនោះខ្វះទឹកខ្លាំងណាស់។ ខ្ញុំមិនបានខ្វល់ថាទឹកដែលខ្ញុំរកបាននៅក្នុងក្រឡុកដានជើងគោក្របី និងល្អក់យ៉ាងណានោះទេ គឺខ្ញុំផឹកទាំងអស់ដើម្បីបំបាត់ការស្រេកមួយគ្រា។

នៅក្នុងឆ្នាំ១៩៧៧ តារបស់ខ្ញុំបានបាត់បង់ជីវិតដោយជំងឺ និងអត់អាហារ ហើយបងប្រុសទី២ និងប្អូនប្រុសទី៥ក៏បានស្លាប់ជាបន្តបន្ទាប់ដែរ។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានស្នើម្តាយរបស់ខ្ញុំទៅកាប់ឆ្ការព្រៃនៅភ្នំលៀប ដោយម្តាយរបស់ខ្ញុំធ្វើការនៅទីនោះរាប់ខែ ទើបត្រឡប់មកផ្ទះវិញ។ ក្រោយមកខ្មែរក្រហមបានស្នើម្តាយខ្ញុំទៅកាន់ព្រៃនៅភ្នំលៀបម្តងទៀតដែលកាលនោះមានប្រជាជនប្រមាណជា២០នាក់ទៀតដែលភាគច្រើនជាប្រជាជនថ្មីទៅជាមួយម្តាយខ្ញុំដែរ។ លើកនេះខ្ញុំមិនបានឃើញម្តាយរបស់ខ្ញុំត្រឡប់មកវិញទេ។ ចំណែកខ្ញុំនិងប្អូនស្រីធ្វើការនៅក្នុងកងកុមារដដែល គឺដើររើសអាចម៍គោកាប់ដើមទន្រ្ទានខែត្រសម្រាប់ធ្វើ និងដើររើសកួរស្រូវ។ នៅឆ្នាំ១៩៧៩ពេលកងទ័ពស្ម័គ្រចិត្តវៀតណាមចូលមកប្រទេសកម្ពុជា ខ្ញុំនិងប្អូនស្រីរបស់ខ្ញុំម្នាក់ឈ្មោះ យិន សុគន្ធា បានធ្វើដំណើរត្រឡប់មកផ្ទះនៅភ្នំពេញវិញ។ យើងបានធ្វើដំណើរមកដល់ស្ពានគំរូ ស្ថិតនៅភូមិភ្នំលៀប ស្រុកព្រះនេត្រព្រះ ក៏ជួបនឹងកងទ័ពវៀតណាម ដែលរង់ចាំដឹកប្រជាជនភៀសខ្លួនទៅរកកន្លែងដែលមានសុវត្ថិភាព។ នៅទីនោះ ខ្ញុំបានប្រាប់ប្អូនស្រីឈ្មោះ យិន សុគន្ធា ឲ្យនៅរង់ចាំខ្ញុំ ដោយខ្ញុំទៅបុកអង្ករជាមួយចាស់ៗទុកសម្រាប់ហូប។ ខ្ញុំត្រូវដឹកដីរាងជាគ្រលុករួចដាក់ស្រូវចូលបុករហូតដល់របកសំបកទើបយកមកអុំយកអង្ករ។ មួយរយៈក្រោយមកក៏មានការបាញ់រះឡើង ហើយប្អូនស្រីរបស់ខ្ញុំក៏បានឡើងជិះរថយន្តរបស់កងទ័ពវៀតណាម

ចាកចេញទៅមុនខ្ញុំ ដោយសារតែមានការភ័យខ្លាចៗ ខ្ញុំ និង ប្អូនស្រីរបស់ខ្ញុំក៏បានបែកគ្នារហូតមកៗ នៅពេលនោះខ្ញុំមាន អាយុ១១ឆ្នាំ ចំណែកប្អូនខ្ញុំមានអាយុប្រហែលជា៩ឆ្នាំ មាន សម្បុរសណ្តែកបាយៗ នៅពេលនោះ យើងទាំងពីរនាក់បងប្អូន បានកាត់សក់ត្រឹមក ហើយពាក់ខោអាវខ្មៅៗ ខ្ញុំនឹករឭកម្តាយ ប្អូនស្រី និង អ៊ំខ្លាំងណាស់ៗ

នៅឆ្នាំ១៩៧៩ ខ្ញុំបានមកខេត្តសៀមរាប ហើយត្រូវ បានមីងម្នាក់យកខ្ញុំធ្វើជាកូនចិញ្ចឹមៗ នៅឆ្នាំ១៩៨១ ខ្ញុំបាន សុំម្តាយចិញ្ចឹមឲ្យជូនខ្ញុំមករកផ្ទះនៅជិតអង់តែនទួលគោក វិញៗ ពេលនោះផ្ទះរបស់ខ្ញុំមានសុទ្ធតែកងទ័ពវៀតណាម ស្នាក់នៅៗ ខ្ញុំបានជួបសាស្រ្តាចារ្យម្នាក់ដែលបង្រៀននៅ សាលាបឹងត្របែក និងធ្លាប់ស្គាល់ឪពុករបស់ខ្ញុំ បានសង់ខ្ទម ស្នាក់នៅជិតអង់តែនទួលគោកៗ គាត់បានហៅខ្ញុំឲ្យសង់ខ្ទម ស្នាក់នៅជិតគាត់ដែរ ប៉ុន្តែខ្ញុំត្រូវទៅនៅជាមួយម្តាយចិញ្ចឹម នៅសៀមរាបវិញៗ ប្រហែល៣ឆ្នាំក្រោយមក ខ្ញុំបានត្រឡប់ មកមើលផ្ទះខ្ញុំម្តងទៀតប៉ុន្តែខ្ញុំរកផ្ទះរបស់ខ្ញុំមិនឃើញសោះៗ ចំណែកដើមចន្ទគិរីនៅមុខផ្ទះរបស់ខ្ញុំក៏រកមិនឃើញដែរៗ ខ្ញុំ បានរៀបការនៅឆ្នាំ១៩៨៣ៗ ខ្ញុំតែងនិយាយពីរបបខ្មែរ ក្រហម និងសាច់ញាតិដែលបាត់បង់ជីវិតនៅក្នុងរបបខ្មែរ ក្រហមប្រាប់ទៅដល់កូនៗរបស់ខ្ញុំៗ កូនរបស់ខ្ញុំមានក្តីប្រាថ្នា ចង់ឲ្យខ្ញុំបានជួបជាមួយប្អូនស្រីរបស់ខ្ញុំវិញៗ មកដល់សព្វថ្ងៃ កូនៗរបស់ខ្ញុំនៅតែព្យាយាមស្វែករកសាច់ញាតិរបស់ខ្ញុំដែល យើងគិតថា អាចនៅរស់រានមានជីវិតៗ

**ដារ៉ារដ្ឋ មេត្តា**



យិន សុភានី ហៅ ពេជ្រ ដានី នៅឆ្នាំ១៩៨៤

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

(តពីលេខមុន)

ចាន់ គារ មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅគងពិសី ខេត្តកំពង់ស្ពឺ ជាកូនរបស់ពូ ចាន់ នាង និងមីង ម៉ែន គិត យុទ្ធនារីមន្ទីរ ស-២១ យ មានប្តីឈ្មោះ ស្វាយ សឿន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅមន្ទីរពេទ្យ ២១។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។ ស្វាយ សឿន ជាប្តីត្រូវបានខ្មែរក្រហមចាប់ខ្លួនបញ្ជូនទៅដល់គុកទួលស្លែង១ថ្ងៃមុនការចាប់ប្រពន្ធ និងសម្លាប់នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។

ចាន់ គឹម មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅព្រៃកប្បាស ខេត្តតាកែវ ជាកូនរបស់ពូ ចាន់ ទិត និងមីង ម៉ែន ផន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៥ នៅឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៨ បន្ទប់តូច ៨។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចាន់ កឿន ហៅ គីន មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់ស្វាយ ខេត្តកំពង់ធំ ជាកូនរបស់ពូ ចាន់ ញ៉ាក់ និងមីង ចេក ថាញ់ យុទ្ធនារីពេទ្យ៣១ កងពល ៣១០ មានប្តីឈ្មោះ ឯម ផាត ហៅ កៀម មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៦ នៅកងពល៣១០ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ០៣ បន្ទប់តូច ៦។ ខ្មែរក្រហមបញ្ចូល ចាន់ កឿន ក្នុងគុកទួលស្លែងនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦ ក៏ប៉ុន្តែកាលបរិច្ឆេទនៃការសម្លាប់មានដល់ទៅ២ផ្សេងគ្នា គឺនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ និងថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៨។ ប្តីឈ្មោះ ឯម ផាត ហៅ កៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៦ ក៏ប៉ុន្តែ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាន់ ណាក់ មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅត្បូងឃ្មុំ ខេត្តកំពង់ចាម ជាកូនរបស់ពូ ចាន់ អេន និងមីង បែន នូវ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៦ នៅកោះផុល កៀនស្វាយ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០១០ បន្ទប់ធំ២។ ខ្មែរក្រហមសម្លាប់ ចាន់ ណាក់ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៧៦ ក្រោយជាប់ឃុំឃាំងនៅគុកទួលស្លែងអស់រយៈពេល ៥៨ ថ្ងៃ។

ចាន់ ផុល ហៅ ពោល មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់ពូ គាំ ចាន់ និងមីង កៅ តូ អនុលេខាកងពល ៣៣៥ តំបន់ ១០៦ មានប្រពន្ធឈ្មោះ សាប៊ីន ហៅលាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅតំបន់ ១០៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឃ បន្ទប់ធំ ០១ បន្ទប់តូច ៧។ ខ្មែរក្រហមទំនងជាបញ្ជូន ចាន់ ផុល មកដល់គុកទួលស្លែងនៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៧៧ គឺ៣ថ្ងៃក្រោយការចាប់ខ្លួន និងសម្លាប់ចោលនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៧។ ឪពុកឈ្មោះ គាំ ចាន់ ជាលេខាតំបន់៤៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៧ ហើយទំនងជាបញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់ គាំ ចាន់ នៅឡើយ។

ចាន់ ធឿន មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុក

កំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់ពូ យិន ទ្រី និងមីង សួន វ៉ាន់ ពេទ្យ ៩៨ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាន់ នី មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកណ្តាលស្ទឹង ខេត្តកណ្តាល ជាកូនរបស់ពូ យិត ឈ និងមីង មាង ហៀង មានប្តីឈ្មោះ អ៊ុល សាអឿន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៧ នៅអគ្គភាពសំណង់។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។ ប្តីឈ្មោះ អ៊ុល សាអឿនត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧។

ចាន់ នួន ហៅ ស៊ីនួន អនុប្រធានរោងចក្រស្រា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រស្រា ស-២ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូនចាន់នួន ទៅឃុំឃាំងនៅគុកទួលស្លែងនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាន់ បូរ៉ាន់ មានអាយុ៣១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅខ្សាច់កណ្តាល ខេត្តកណ្តាល ជាកូនរបស់អ៊ំ ចាន់ ខាន់ និងអ៊ំស្រី ថោង រឿន មានប្រពន្ធឈ្មោះ ថោង យាន មានកូនប្រុស៥នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ នៅអគ្គិសនីផ្សារតូច ភ្នំពេញ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆ បន្ទប់ធំ ៥ បន្ទប់តូច ១៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចាន់ ដាន ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅកងពល១៧០។ ខ្មែរក្រហមបញ្ជូល ចាន់ ដាន ទៅក្នុងគុកទួលស្លែងនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៥១ ថ្ងៃ។

ចាន់ ម៉ុល ហៅ តុល មានអាយុ៣៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់អ៊ំ ចាន់ នាត និងអ៊ំស្រី យួន ប្រធានតំបន់៤២ មានប្រពន្ធឈ្មោះ ម៉ក់ ហ៊ឹម ហៅ ឆុន មានកូនស្រី៤នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅភូមិភាគឧត្តរ។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ខ្មែរក្រហមបញ្ចូល ចាន់ ម៉ុល ដល់គុកទួលស្លែងនៅថ្ងៃខុសគ្នា គឺថ្ងៃទី១៩, ២៨, និង២៩ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧។

ចាន់ យ៉ន ហៅ ហាន មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅពាមរ៍ ខេត្តព្រៃវែង ជាកូនរបស់ពូ ចាន់ ធន និងមីង ជិន សន យុទ្ធជនកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

ចាន់ យូរ៉ុន គ្រូបង្រៀនមកពីបារាំងត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូន ចាន់ យូរ៉ុន ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ ក្រោយជាប់ឃុំឃាំងអស់រយៈពេល ៤០ ថ្ងៃ។

ចាន់ រី មានអាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសូទ្រនិគម ខេត្តសៀមរាប ជាកូនរបស់ពូ យន់ និងមីង សួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពាណិជ្ជកម្មផ្សារថ្មី ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៥ បន្ទប់តូច ១២។ ខ្មែរក្រហមសម្លាប់ ចាន់ រី នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ជាប់

ឃុំឃាំងរយៈពេល ៩៧ ថ្ងៃ។

ចាន់ លាង ហៅ នួន មានអាយុ៣៨ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅក្រូចឆ្មារ ខេត្តកំពង់ចាម ជាកូនរបស់អ៊ុំ ស្រ៊ុន និងអ៊ុំស្រី ឡេង មានប្ដីឈ្មោះ ទិត សុន ហៅ ញ៉ែម មានកូនប្រុស៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកាត់ដេរ រដ្ឋ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៥ បន្ទប់តូច ៩។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។ ចំណែកឯប្ដីឈ្មោះ ទិត សុន ហៅ ញ៉ែម ត្រូវបានរកឃើញនៅក្នុងបញ្ជីអ្នកទោសនៅទួលស្លែង ប៉ុន្តែពុំមានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃចាប់ខ្លួន និងការសម្លាប់នៅឡើយ។

ចាន់វ៉ាន់ថន ហៅ ឆាយ មានអាយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅគងពិសី ខេត្តកំពង់ស្ពឺ ជាកូនរបស់អ៊ុំតាំង យូ និងអ៊ុំស្រី សុខ អេង មានប្រពន្ធឈ្មោះ អៀម សុវណ្ណារី ហៅ នាង អូន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅផ្សារតូច ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៧ បន្ទប់តូច ១០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាន់ វុធ ចោរព្រៃ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេជនិលក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ចាន់ វុធ មកដល់គុកទួលស្លែងនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី២៦ ខែឆ្នាំដដែល។

ចាន់ ស៊ីណាត ហៅ កុន ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅអគ្គិសនីចក្រអង្រែ ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ចាន់ ស៊ីថា មានអាយុ៣១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្ដាល ធ្លាប់បួសជាសង្ឃ ជាកូនរបស់អ៊ុំ ចាន់ ញ៉ិល និងអ៊ុំស្រី ហែម ហ៊ន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០១ បន្ទប់តូច ១២។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ខ្មែរក្រហមចាប់បញ្ជូន ចាន់ ស៊ីថា មកដល់គុកទួលស្លែងនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៦។

ចាន់ សាយ ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅកន្លែងរទេះភ្លើងក្នុងឆ្នាំ១៩៧៦។ ចាន់ សាយ ត្រូវជាប្រពន្ធរបស់ ឈួន ឈឿន និងត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកគុកទួលស្លែងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី៣០ ខែឆ្នាំដដែល។

ចាន់សារ៉ាត មានអាយុ៣៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្វាយទង ខេត្តមាត់ជ្រូក ជាកូនរបស់អ៊ុំ ចៅ កាន់ និងអ៊ុំស្រី នាង សួន មានប្រពន្ធឈ្មោះ សេង សុនរី ហៅ នាង សួន មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរសន្តិបាល ថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៨ បន្ទប់ធំ ៤។ ខ្មែរក្រហមសម្លាប់ ចាន់ សារ៉ាត នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៦។

ចាន់ សុក ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា មានឈ្មោះ ចាន់ សុក រហូតដល់ទៅ ៤នាក់។ ដោយសំអាងលើទីកន្លែងចាប់ខ្លួន ចាន់ សុក ម្នាក់នេះត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកគុកទួលស្លែងនៅថ្ងៃទី១៩ ឬ២៤ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៦។ **(នៅមានត)**

**វ៉ាន់ ថាន់ពៅដារ៉ា និង ឡុង ដានី**

# អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ

## បញ្ជីអដ្ឋិធាតុដែលរកឃើញនៅក្រោមបល្ល័ង្កព្រះពុទ្ធរូបក្នុងវត្តលង្កា, ទីក្រុងភ្នំពេញ

*រៀបរៀងដោយ៖ ចាន ប្រាថ្នា, សា ហ្វាទីលី, សុភ័ក្រ្ត ភាណា និង អ៊ុន សុដារី*
*វិទ្យាស្ថានស្លឹករឹត, ខែកុម្ភៈ ឆ្នាំ២០១៥*

(តចប់)

| ល.រ | លេខកូដ | ឈ្មោះ ជាភាសាអង់គ្លេស | ឈ្មោះ | ភេទ | អាយុ | ថ្ងៃមរណភាព | ទំព័រក្នុង សៀវភៅ |
|---|---|---|---|---|---|---|---|
| ៤៥៥ | ៩១១២ | Um Chann (No 1532, Ressey Keo Village) | អ៊ុំ ចាន់ (ផ្ទះលេខ ១៥៣២, ភូមិឬស្សីកែវ) | ប្រុស | ? | ? | ២៥៧ |
| ៤៥៦ | ៩១១៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៥៧ |
| ៤៥៧ | ៩១២០ | Kap Davy | កប ដាវី | ស្រី | ២៨ ឆ្នាំ | ១៥/០៣/១៩៨៨ | ២៥៨ |
| ៤៥៨ | ៩១២៣ | Phatt Tauch | ផាត់ តូច | ប្រុស | ៦០ ឆ្នាំ | ២៩/០៦/១៩៨៨ | ២៦១ |
| ៤៥៩ | ៩១២៥ | Sok Sathara | សុខ សត្ថារ៉ា | ស្រី | ? | ១៩៩០ | ២៥៨ |
| ៤៦០ | ៩១២៧ | Ing Sokha | អ៊ឹង សុខា | ? | ៣១ ឆ្នាំ | ? | ២៥៨ |
| ៤៦១ | ៩១៣០ | Taem Yy | តើម យី | ? | ៥១ ឆ្នាំ | ? | ២៦១ |
| ៤៦២ | ៩១៣៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៦១ |
| ៤៦៣ | ៩១៣៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៦១ |
| ៤៦៤ | ៩១៤០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២៦៣ |
| ៤៦៥ | ៧៤៥១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨៤ |

# ដំណឹងស្វែងរកប្អូនប្រុស

នាងខ្ញុំឈ្មោះ សំ អន អាយុ៧៤ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិធំ សង្កាត់ពញ្ញាពន ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ នាងខ្ញុំមានឪពុកឈ្មោះ សំ ម្ដាយឈ្មោះ ផាន់ និងមានបងប្អូនបង្កើតចំនួនប្រាំពីរនាក់៖ ទី១) ឈ្មោះ សំ ប៉ុច ភេទស្រី ទី២) ឈ្មោះ សំ អ៊ុក ភេទស្រី ទី៣) ខ្ញុំ (សំ អន) ទី៤) ឈ្មោះ សំ ស៊ីម ភេទប្រុស (បាត់ខ្លួន) ទី៥) ឈ្មោះ សំ សាន់ ភេទប្រុស ទី៦) ឈ្មោះ សំ ម៉ុក ភេទប្រុស និង ទី៧) ឈ្មោះ សំ ស៊ិន ភេទប្រុស។ ប្អូនប្រុសរបស់នាងខ្ញុំ សំ ស៊ីម មានមាឌស្ដើង និងមានសម្បុរសណ្ដែកបាយ។

នាងខ្ញុំសូមប្រកាសស្វែងរកប្អូនប្រុសឈ្មោះ សំ ស៊ីម ដែលបានបែកគ្នានៅក្នុងឆ្នាំ១៩៧៥។ នៅក្នុងរបបសាធារណរដ្ឋខ្មែរ ប្អូនប្រុសរបស់ខ្ញុំ គឺជាកងទ័ពអាកាសនៅទីរួមខេត្តកំពង់ឆ្នាំង។ នៅពេលដែលយោធាខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ នាងខ្ញុំរស់នៅស្រុកកំណើតក្នុងភូមិធំ ស្រុកពញ្ញាឮ ខេត្តកណ្ដាល។ នាងខ្ញុំបានទទួលបានដំណឹងប្អូនប្រុសរបស់ខ្ញុំដែលបានផ្ដាំតាមរយៈឪពុកក្មេកមកប្រាប់ម្ដាយខ្ញុំថា «កុំបារម្ភពីខ្ញុំអី ខ្ញុំឡើងយន្តហោះទៅជាមួយមិត្តភក្តិខ្ញុំហើយ»។ នៅអំឡុងពេលនោះ ប្អូនប្រុសរបស់ខ្ញុំនៅបន្ទាយកំពង់ឆ្នាំង។ នាងខ្ញុំមិនដឹងថា ប្អូនប្រុសរបស់នាងខ្ញុំបានឡើងយន្តហោះទៅជាមួយមិត្តភក្តិរបស់គាត់ ឬយ៉ាងណានោះទេ។


កូនប្រុសរបស់ សំ អន សព្វថ្ងៃរស់នៅភូមិធំ សង្កាត់ពញ្ញាពន ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

សំ ស៊ីម មានប្រពន្ធឈ្មោះ ចក់ ថុន និងមានកូនប្រុសពីរនាក់កូនទី១)ឈ្មោះ រិន (មានអាយុ៥ឆ្នាំនៅក្នុងឆ្នាំ១៩៧៥) និងកូនទី២)ឈ្មោះ រ៉ា (មានអាយុប្រហែល៣ឆ្នាំ នៅក្នុងឆ្នាំ១៩៧៥)។

ចាប់តាំងពីឆ្នាំ១៩៧៥ នាងខ្ញុំមិនបានទទួលដំណឹងអ្វីទាំងអស់ពីប្អូនប្រុស។

អាស្រ័យដូចបានជម្រាបជូនខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ឬធ្លាប់ឮ ឈ្មោះប្អូនប្រុសនាងខ្ញុំឈ្មោះ សំ ស៊ីម សូមមេត្តាផ្ដល់ដំណឹងមកនាងខ្ញុំតាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬតាមរយៈទូរសព្ទលេខ ០២៣ ២១ ៤០ ០៩ ឬ ០១២ ៥៨ ០៤ ៨៦។

សូមអរគុណ!



ឡាង ទូញ ជនជាតិភាគតិចជង់ខ្នងភ្នំ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់


**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 234, June 2019 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M BRK, 30 Ocotber 2018.